ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber

Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរ</u>
# <u>នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"</u>
# <u>សាធារណៈ</u>

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី១៥)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវ៉ែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ បេ៊ត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទូអាត ហ្វដ *(Mr.stuart FORD)*

លោក ប៉ាក់ ច័ន្ទលីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្កេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms.Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យ៉ុង ផានិត

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោក ហ្វីលីព កាណុន

*(Mr. Philippe Cannone)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី** ៖ ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច

សួរដោយ លោក ហុង គឹមសួន ផ្ដើមពី ........................................ទំព័រ ១

សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........................................ទំព័រ ៩

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ........................................ទំព័រ ១០

សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........................................ទំព័រ ២៣

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អាឡិចសាន់ឌឺ ប៊ែត | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែរ៍ | បារាំង |
| ជនជាប់ចោទ | ខ្មែរ-បារាំង |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[០៩:១៤:២៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តសវនាការពិភាក្សាដេញដោលលើអង្គហេតុនៃការបង្កើតមន្ទីរសន្តិបាល ស-២១ និងគុកនៅអតីតមន្ទីរពេទ្យឆ្កួតនៅតាខ្មៅជាបន្ត ។ ក្រឡាបញ្ជីឡើងរាយការណ៍អំពីវត្តមាន និង អវត្តមានភាគីត្រូវចូលរួមនៅក្នុងដំណើរការសវនាការនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ភាគីដែលបានចូលរួមក្នុងដំណើរការនីតិវិធីក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួនហើយ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទមកកាន់តុឈើរាងរង្វង់ក្រចកសេះនៅមុខអង្គជំនុំជម្រះ ។

ដោយកាលពីម្សិលមិញ គឺដល់ឱកាសនៃមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបួន ដែលបានសួរសំណួរដល់ជនជាប់ចោទ ប៉ុន្ដែ នៅសល់នៅសំណួរមួយចំនួនដោយពេលវេលាដល់ពេលត្រូវឈប់សម្រាកនោះគឺមិនទាន់បានសួរអស់ទេ ។ អ៊ីចឹង អង្គជំនុំជម្រះប្រគល់ឱកាសនេះទៅមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបួន ប្រសិនបើនៅមានសំណួរសេសសល់អាចបន្តសំណួរសួរដល់ជនជាប់ចោទបន្តទៀត អំពីអង្គហេតុដែលជាកម្មវត្ថុនៃកិច្ចពិភាក្សាដេញដោលបានកំណត់រួចហើយ ។

សូមអញ្ជើញលោកមេធាវី ។

**សួរដោយ លោក ហុង គឹមសួន៖**

សូមអរគុណបាទ ។

ជាដំបូង ខ្ញុំបាទសូមគោរពលោកប្រធានអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក លោកស្រី លោកចៅក្រម និងអង្គសវនាការជាទីគោរព ។ ខ្ញុំបាទសូមបន្តសំណួរបន្តិចទៀតទៅលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ទាក់ទងនឹងការបង្កើតមន្ទីរស-២១ និងគុកនៅតាខ្មៅ ។ ពីម្សិលមិញ ខ្ញុំបាទបានសួរដល់ទាក់ទងជាមួយនឹងដ្យាក្រាម ប៉ុន្តែថ្ងៃនេះដោយសារលោកចៅក្រម ឡាវែន៍ លោកបានជម្រាបរួចហើយ

ថា ជាឧបសម្ព័ន្ធ ។ អ៊ីចឹង ខ្ញុំបន្តចូលទៅដល់ទាក់ទងនឹងការបង្កើតបន្ទប់តូចៗសម្រាប់ដាក់អ្នកទោសនៅក្នុងអគារនៃមន្ទីរស-២១ ។ ដោយពីថ្ងៃមុនលោក ឌុច បានជម្រាបអង្គសវនាការអំពីការបង្គាប់បញ្ជាដោយសិទ្ធិរបស់លោកផ្ទាល់ទៅឲ្យសមមិត្តហ៊ី ជាអ្នកធ្វើបន្ទប់តូចៗ នេះគ្រាន់តែខ្ញុំសូមរំឭកបន្តិចឡើងវិញ ។

**ស៖** តើលោកបានបង្គាប់ឲ្យសហការីរបស់លោក គឺមិត្តហ៊ី ទៅធ្វើបន្ទប់តូចៗនោះ ជាគម្រោងគូសវាស ការគិតផ្ទាល់របស់លោក ឬមានការណែនាំពីថ្នាក់លើ?

**ជនជាប់ចោទ៖**

**ឆ៖** សូមគោរពលោកប្រធាន! រឿងនេះខ្ញុំបានរាយការណ៍ជូនអង្គសវនាការច្រើនហើយ ឥឡូវគ្រាន់សូមបញ្ជាក់ពីរបីម៉ាត់ដើម្បីច្បាស់លាស់ ។ ខ្ញុំគ្មានបានសុំយោបល់ខាងលើទេ ជាក្របខ័ណ្ឌសិទ្ធិអំណាចរបស់គណៈកម្មាធិការមន្ទីរស-២១ ក្នុងរៀបចំធ្វើបន្ទប់តូចៗនេះ ។ ខ្ញុំជាអ្នកបញ្ជា មិត្តហ៊ី ជាអ្នកធ្វើ ។ គំរូខ្ញុំអត់គូរឲ្យទេ មិត្តហ៊ី ស្គាល់ហើយ*សែលុយអាំងឌីវីឌែល* នៅប៉េហ្ស៊ី ដែលសល់តាំងពីជំនាន់បារាំងមក គេធ្វើតាមនុ៎ង ។ ដូច្នេះសូមចប់ប៉ុណ្ណោះ ។

**ស៖** សូមអរគុណ ។ លោកបានជម្រាបអង្គសវនាការពីថ្ងៃមុនហើយ ទាក់ទងថាលោកមិនដែលទៅមើលតាមអគារដែលលោកបង្គាប់ឲ្យធ្វើបន្ទប់តូចៗនោះទេ ។ តើបន្ទាប់ ឬក្រោយពេលដែលធ្វើបន្ទប់តូចៗហើយនោះ ការអនុ-- (សូមទោស) ការសម្រេចដាក់អ្នកទោសទៅក្នុងបន្ទប់មួយៗនោះ គឺជាការគិត ឬការបង្គាប់របស់លោក ឬក៏ជាការណែនាំផងដែរ? នេះខុសគ្នាពីការបង្គាប់ឲ្យធ្វើបន្ទប់ និងការយកអ្នកទោសទៅដាក់ ។

**ឆ៖** សូមជម្រាបអង្គសវនាការ សូមជម្រាបលោកប្រធាន សូមជម្រាបលោកគឹមស្ហួន ថា បញ្ហានេះពីរដាច់ដោយឡែកពីគ្នា ។ ទីមួយ គឺបញ្ជាឲ្យធ្វើបន្ទប់ ជាការបញ្ជារបស់ខ្ញុំក្នុងក្របខ័ណ្ឌសិទ្ធិអំណាចជាប្រធានមន្ទីរស-២១ ។ ឯចំណែកការដាក់អ្នកទោសសាមញ្ញនៅក្នុង*សែលុយអាំងឌីវីឌែល* តូចៗហ្នឹងក្តីនៅក្នុងបន្ទប់រួមក្តី ជាកាតព្វកិច្ចដែលមិត្តហ៊ី គេដោះស្រាយ គេធ្វើជាប្រចាំរបស់គេ ។ គេម្ចាស់ការទទួលខុសត្រូវចំពោះមុខខ្ញុំដែលជាប្រធាន និងចំពោះមុខបក្ស ធ្វើម៉េចកុំឲ្យតែអ្នកទោសនិយាយឆ្លើយឆ្លងគ្នានៅពេលដែលសំណុំរឿងជាមួយគ្នា ហើយសួរចម្លើយពេលជាមួយគ្នា ។ ដូច្នេះ គេម្ចាស់ការរបស់គេទុកឲ្យគេម្ចាស់ការ ។ នេះជាសិទ្ធិអំណាចដែលខ្ញុំប្រគល់ឲ្យគេធ្វើ ឲ្យគេទទួលខុសត្រូវចំពោះមុខខ្ញុំចំពោះមុខបក្ស ។

**ស៖** សូមអរគុណ ។ សំណួរទីបី ជាទូទៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដូចជាមន្ទីរក្រសួងស្ថាប័ននានាផងដែរ តែងតែមានការអនុវត្តគោលការណ៍ប្រឡងប្រណាំង ។ ដូច្នេះ នៅក្នុងមន្ទីរស-២១ តើមានការលើកទឹកចិត្តពីលោកក្នុងនាមប្រធានម-២១ *(ស៊ុក)* ឲ្យមានការប្រឡងប្រណាំងលើគុណសម្បត្តិតាមផ្នែកនីមួយៗជូនអង្គការ ឬជូនលោកដែរឬទេ?

[០៩:២២:២៤]

**ឆ៖** លោកប្រធានជាទីគោរព! អង្គសវនាការជាទីគោរព! លោក គឹមសួន ជាទីគោរព! ការប្រឡងប្រណាំងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមាន ។ គេប្រឡងប្រណាំងនឹងអ្នកណា? គេប្រឡងប្រណាំងនឹងចលនា ។ លោកអាចឃើញហើយឯកសារដែលខ្ញុំបង្រៀនពួកកម្មាភិបាលសួរចម្លើយ យកគំរូតាមបីតោន ។ កសិករគេខំពុះពារយកឲ្យបានបីតោន យើងអ្នកសួរចម្លើយក៏ខំយកឲ្យបានច្បាស់លាស់ ។ ហ្នឹងគឺប្រឡងប្រណាំងនឹងចលនា យកចលនាជាធំ ។ ការកសាងខ្លួនក៏ដោយ ក៏ត្រូវប្រៀបធៀបនឹងចលនា ។ ការកសាងខ្លួនយើងម្នាក់ៗក៏ត្រូវប្រៀបធៀបនឹងចលនាដែរ ។ សូមចប់ ។

**ស៖** សូមអរគុណ ។ នៅក្នុងសំណួរទីបួន ទាក់ទងជាមួយនឹងភាពស៊ីចង្វាក់ ឬក៏ប្រហាក់ប្រហែលគ្នារវាងម-១៣ និងការបង្កើតគោលការណ៍នៅក្នុងស-២១ ការប្រជុំទិតៀន ស្វ័យទិតៀន ។ តើកម្មាភិបាល ឬថ្នាក់កម្រិតណាដែលធ្វើការប្រជុំទិតៀន ស្វ័យទិតៀនជាមួយលោកជាមេផ្ទាល់?

**ឆ៖** បញ្ហានេះវាជាក្រឹត្យក្រមដែលមានចែងច្បាស់លាស់នៅក្នុងលក្ខន្តិកៈបក្ស ។ ខ្ញុំមិនសូមនិយាយបញ្ហានេះលម្អិតទេ ។ ក្នុងនាមជាគណៈកម្មាធិការបក្សមន្ទីរស-២១ ក្នុងការប្រជុំប្រចាំកន្លះខែម្តងទិតៀន ស្វ័យទិតៀន ត្រូវធ្វើរវាងខ្ញុំបីនាក់ ។ គឺខ្ញុំ មិត្តហ៊ី និងមិត្តហ៊ុយ ។ នេះជាគោលការណ៍ដែលត្រូវតែធ្វើ ក៏ប៉ុន្តែដល់ពេលវារវល់ជាក់ស្តែងខ្លាំងពេកទៅ ហើយមានជំនឿជឿទុកចិត្តគ្នាផង មិនដែលបានធ្វើទេ ។ គ្រាន់តែខ្ញុំឃើញគេខុស ខ្ញុំប្រាប់គេ គេឃើញខ្ញុំខុស គេប្រាប់ខ្ញុំ ។ នេះជាប្រចាំធ្វើអ៊ីចឹង ។ ឯចំណែកទិតៀន ស្វ័យទិតៀន ដាក់ខ្លួនឲ្យអង្គភាពទាំងមូល មានមតិខ្ញុំគឺនៅពេលសន្និបាតគណៈមន្ទីរ--សន្និបាតគណៈកម្មាធិការមន្ទីរ សន្និបាតមន្ទីរទាំងមូលនោះ គណៈមន្ទីរស-២១ ទាំងមូលនោះ ។ ជាឧទាហរណ៍ សន្និបាតមួយដែលខ្ញុំនៅចាំថ្ងៃច្បាស់លាស់ គឺសន្និបាតថ្ងៃ២៧ មេសា ១៩៧៧ ដែលមេខ្ញុំលោកគ្រូ សុន សេន គាត់អញ្ជើញមកនុ៎ង ។ ពេលនឹងដែលខ្ញុំត្រូវដាក់ខ្លួនឲ្យមហាជនក្នុងអង្គភាព គេទិតៀនខ្ញុំ ។ សូមបញ្ជាក់ថា បានជាខ្ញុំចាំថ្ងៃខែពេលនេះច្បាស់ វាជាន់នឹងថ្ងៃកំណើតកូនខ្ញុំ ។ បង ម៉មណៃ អត់បានស្តាប់ទេ ជូនប្រពន្ធខ្ញុំទៅពេទ្យ ដូច្នេះ មានតែសន្និបាតទេ ដែលក្នុងៗអង្គភាពហ្នឹង គេមាន

សិទ្ធិទិតៀនខ្ញុំ ។

[០៩:២៦:០៥]

**ស៖** សូមអរគុណ ។ សំណួរបន្ត ដោយសារតែលោកបានជម្រាបអង្គសវនាការរួចហើយ ទាក់ទងជាមួយការបញ្ចូលបក្ខជនពេញសិទ្ធិ កាលដែលលោកត្រូវបានជាប់ពន្ធនាគារ នៅឆ្នាំ១៩៦៨ លោកថាអ្នកដែលបញ្ចូលបក្សនោះ គឺមិត្តហ៊ា ហ្នឹង ។ តើខ្ញុំស្តាប់ច្រឡំឬយ៉ាងម៉េច? សូមបញ្ជាក់បន្តិច ដើម្បីសួរសំណួរឲ្យចំ?

**ឆ៖** លោក គឹមសួន មិត្តហ៊ា អង្កាល់ដែលយើងខ្ញុំជាប់គុកទាំងពីរណាស់ មិត្តហ៊ា នៅជាយុវកក ទេ ខ្ញុំជាបក្ខជនត្រៀម ។ ខ្ញុំមកចូលបក្សនៅគុកធំ អ្នកទទួលស្គាល់ខ្ញុំបង ទេព សឿន សមាជិកអចិន្ត្រៃយ៍សភា ស សឿន ដល់ពេលគាត់ធ្វើសមាជិកអចិន្ត្រៃយ៍សភា គាត់ដាក់ឈ្មោះ ស សឿន នេះជាកម្មាភិបាលដែលទទួលស្គាល់ខ្ញុំក្នុងឋានៈជាបក្ខជនពេញសិទ្ធិ ។

**ស៖** សូមអរគុណ ។ ដោយសារលោកបានជម្រាបលោកប្រធាន លោកស្រី លោកចៅក្រម និងអង្គសវនាការទាក់ទងអំពីការធ្វើការងារ ឬអនុវត្តគោលការណ៍បក្សកុម្មុយនីស្តកម្ពុជា ក៏ដូចជាតួនាទីរបស់លោកជាប្រធានស-២១ ប្រហាក់ប្រហែលនឹងម-១៣ ។ ដូច្នេះ លោកបានជម្រាបអង្គសវនាការរួចហើយថា បើសិនជាបញ្ហា ឬទិស ឬគោលការណ៍ថ្នាក់លើដាក់មកលោកមិនហ៊ានប្រកែក ឬត្រូវតែធ្វើតាម បើមិនធ្វើតាមកំបុតក ។ អ៊ីចឹង ជាមួយនឹងទិសរបស់ សុន សេន ហើយនិង នួន ជា ក្នុងពេលដែលលោកធ្វើប្រធានស-២១ នេះ ទាំងពីរនាក់នេះ មួយណាដែលមានឥទ្ធិពលខ្លាំងទៅលើលោកមុននឹងភ្ជាប់សំណួរបន្តិចទៀត?

**ឆ៖** ក្នុងឋានៈជាកម្មាភិបាលដឹកនាំ បទបញ្ជារបស់គេ យើងត្រូវតែគោរព នេះជារឿងពិត ។ ក៏ប៉ុន្តែ បុគ្គលពីរនាក់ វាមានលក្ខណៈប្លែកគ្នាហើយស្រេច ។ បុគ្គលលោកគ្រូ សុន សេន ខ្ញុំ វាទៅផ្សេង បុគ្គល ពូនួន គាត់ទៅផ្សេង ។ ពូនួន បញ្ជាមកអត់ពន្យល់ទេ ។ បើជាមួយលោកគ្រូ សុន សេន គាត់និយាយមក យើងអាចមានសិទ្ធិនិយាយអ៊ីចេះ និយាយអ៊ីចុះ លើកហេតុផល ដើម្បីពិភាក្សាជាមួយគាត់ ។ កាលណាលើកហេតុផលផ្ទុយនឹងបញ្ហាគាត់ គាត់ដោះវ៉ែនតាជូតភ្នែក គាត់គិត ដល់គាត់ដាក់វ៉ែនតាវិញ គាត់លើកហេតុផល ហេតុផលអ៊ីចេះៗ ។ ចុងបញ្ចប់ គាត់ថាមិត្តត្រូវតែអនុវត្តបែបនេះ បានវាចំណេញដល់បក្សបដិវត្តន៍ បើមិត្តអនុវត្តបែបនេះវាខាត ។ ដូច្នេះ ជាមួយនឹង សុន សេន ខ្ញុំមានការស្រឡះក្នុងចិត្ត ក្នុងអនុវត្តបទបញ្ជាគាត់ជាងជាមួយ ពូនួន ។ នេះសូមបញ្ជាក់ប៉ុណ្ណឹង ។

[០៩:២៩:២៧]

**សៈ** អរគុណ ។ អ៊ីចឹង ទាក់ទងជាមួយនឹងការបង្កាប់ ឬបញ្ជារបស់មេ ព្រោះលោកថាមានមេដល់ពីរ គឺ សុន សេន និង នួន ជា ។ អ៊ីចឹង ថ្ងៃមុនលោកបានជម្រាបអង្គសវនាការស្តីអំពីបញ្ជារបស់ នួន ជា ឱ្យផ្លាស់ទីតាំងទៅកប់ស្រូវ ហើយលោកបានប្រកែក ឬក៏លោកបានពន្យល់តវ៉ាទៅវិញជាមួយ នួន ជា ថាដោយសារនៅជើងឯក គ្មានអ្នកណាមើលការខុសត្រូវ ដោយសារមានកន្លែងកប់សាកសពច្រើនពេកអ៊ីចឹងមែនទេ ថ្ងៃមុន?

**ឆៈ** មុននឹងឆ្លើយ ខ្ញុំសូមលើកបញ្ហាមួយដើម្បីច្បាស់លាស់ មិនមែនខ្ញុំស្ថិតនៅក្រោមបញ្ជាមេទាំងពីរនេះក្នុងពេលតែមួយទេ គឺនៅពេលដែលលោកគ្រូ សុន សេន ខ្ញុំ គាត់អញ្ជើញទៅសមរភូមិ ពូនួនដែលនៅពីលើ សុន សេន ហ្នឹង ចុះមកជួបខ្ញុំ ចាប់តាំងពីថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៧ ទៅ ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។ ទីពីរ គោលការណ៍ដែលឱ្យកសាងមន្ទីរស-២១ នៅកប់ស្រូវជាគោលការណ៍បក្សប៉ុល ពត សម្រេច ។ នេះបើតាមខ្ញុំមើលហូរហែប្រវត្តិពីសាក្រោយឡើងវិញ ។

បានជាខ្ញុំប៊ាននិយាយដូច្នេះ ពីព្រោះថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៥ ដែលខ្ញុំទៅជាមួយនឹង ណាត ទទួលការឧទ្ទេសនាមអំពីការកកើតមន្ទីរស-២១ នេះ លោកគ្រូ សុន សេន មេខ្ញុំបញ្ជាក់ថាទីតាំងមិត្តនៅកប់ស្រូវឯណោះ ។ មិត្តឱ្យ មិត្តចន ជូនទៅបង្ហាញកប់ស្រូវ ក៏ប៉ុន្តែដោយមិត្តចន នីរសាររបស់គាត់ដែលនៅប្រចាំការនៅវ៉ារទេះភ្លើងហ្នឹង ស្ថានីយ៍រថភ្លើងហ្នឹង រវល់ពេកអត់បានជូនទៅក៏ប្រគប់ប្រញាយឱ្យចាប់ផ្តើមបង្កើតមួយរយៈក្រោយមក ឱ្យៗខ្ញុំទៅដើររើសៀវភៅនេះ ។ ដូច្នេះ កប់ស្រូវនេះវាគោល-ការណ៍បក្សតាំងពីនាយមក ។

ដល់ចុងបញ្ចប់ នៅប្រហែលខែ ដែលខែ១១ អី ឆ្នាំ១៩៧៨ ពូនួន គាត់មានប្រសាសន៍ម្តងទៀត គាត់ថា “មិត្តទីតាំងមិត្តដែលបក្សចង្អុលនេះ កប់ស្រូវ” ។ ខ្ញុំថា “ខ្ញុំដឹងហើយបង” ។ កាលណោះ ខ្ញុំហៅបង ខ្ញុំអត់ហៅពូទេ ។ ខ្ញុំដឹងហើយបង ។ ប៉ុន្តែ បញ្ហាចោទ ខ្ញុំមិនប៊ានដើរចោលជើងឯកទេ ខ្ញុំសុំនៅនឹងជើងឯក ព្រោះសាកសពច្រើនណាស់ ។ បើខ្ញុំដើរចោលទៅ គេទៅរើទៅកកាយពាសវាលពាសកាលវាអត់កើតទេ នេះខ្ញុំជម្រាបគាត់អ៊ីចឹង ។ ដល់ខ្ញុំជម្រាបគាត់អ៊ីចឹង គាត់ក៏មិនទាន់សម្រេចភ្លាមថាម៉េចទេ ។ ទៅធ្វើការលើកក្រោយបាន១ គាត់ប្រាប់ខ្ញុំថា “បក្សអនុម័តិឱ្យមិត្តនៅជើងឯក កសាងកន្លែងនៅជើងឯករៀបចំទៅ” នេះ ។

**ស៖** ខ្ញុំសូមអរគុណ ។ អ៊ីចឹង ខ្ញុំសុំសួរសំណួរពីរទៀតទាក់ទងនឹង-- លោកបានមានប្រសាសន៍ជូនអង្គសវនាការនិងលោកប្រធាន លោកស្រី លោកចៅក្រមហើយ ប៉ុន្តែ ក្នុងន័យជាពាក្យស្លោក ។ អ៊ីចឹង ខ្ញុំចង់ឲ្យលោកបកស្រាយ ឬពន្យល់ថា ពាក្យថា *"ប៉ែកហ្សេ"* ឬ "បកក្តាមបង្ហាញអាចម៍" ន័យជាៗទូទៅ ឲ្យជាការងាយស្រួលដល់អង្គសវនាការ ។ តើមានន័យយ៉ាងម៉េចចំពោះលោកជាមួយនឹងមេឬបក្សរបស់លោក?

[០៩:៣៣:៤០]

**ឆ៖** ខ្ញុំគិតថាពាក្យអស់នេះខ្មែរស្រួលយល់ទេ ។ បារាំង អង់គ្លេស ក៏ដូចជាមិនពិបាកយល់ អំពីពាក្យ *"ប៉ែកហ្សេ"* ដែរ ។ យើងជាមនុស្សស្មោះត្រង់នឹងគេ គេទុកយើងជាឧបករណ៍ដែលគេប្រើប្រាស់។ ពាក្យនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាគេហៅថា "ឧបករណ៍ដ៏បរិសុទ្ធរបស់បក្សៗ" ។ មួយជំហានណាក៏អត់ប៉ានក្បត់បក្សដែរ ។ បក្សចង្អុលឆ្វេង ឆ្វេង បក្សចង្អុលស្តាំ ស្តាំ ។ ប៉ុន្តែ ខ្ញុំចង់យកពាក្យសាមញ្ញដែលខ្មែរយើងស្រួលយល់ ។ ខ្ញុំប្រើពាក្យ *ប៉ែកហ្សេ* នេះទៅ នេះទីមួយ ។ ទីពីរ "បកក្តាមបង្ហាញអាចម៍" ឬ "ហែកពោះឲ្យក្អែកចឹក" គឺយើងលាតត្រដាងស្អី ដែលនាំឲ្យយើងងាប់ ហើយដែលមិនចាំបាច់ត្រូវលាតត្រដាង ។ ក្តាមតែបកខ្វាក ឃើញអាចម៍ក្តាមងាប់បាត់ហើយ ។ ហើយយើងទៅវះពោះឲ្យក្អែកចឹក វះខ្វាក យើងងាប់បាត់ទៅហើយ ។

ដូច្នេះ យើងមិននិយាយអ្វី ដែលហាឡើងផ្តាប់ គេសម្លាប់យើងភ្លាមនោះទេ ។ ឧទាហរណ៍ ខ្ញុំមិនធ្វើការនគរបាលទេ នគរបាលខ្មែរក្រហមជាឧក្រិដ្ឋ ។ យើងប៉ាននិយាយអ៊ីចឹងទេ? យើងមិនប៉ានទេណ្ហើយហើយយើងរកវិធី ។ ដូចខ្ញុំបានលើកវិធីជូនរួមមកហើយ ដើម្បីនិយាយថាសេចក្តីសារភាពទាំងអស់វាមិនពិត នៅពេលដែលចាប់ទាំងឈុតមកពីខាងឧត្តរ ខ្ញុំបានលើកឧទាហរណ៍ ។ ខ្ញុំនិយាយជាមួយមេខ្ញុំលោកគ្រូ សុន សេន ខ្ញុំថា "បងអ្នា ឈ្មោះនេះដូចមិនទំនង" ។ គាត់កំហែងពីចុងម្ខាងទូរស័ព្ទមកថា "មិត្តឌុច ណាចម្លើយ អាឃួន ណ៎ា!" ។ ដូច្នេះពាក្យដែលថា គាត់ថាចម្លើយអាឃួន ក៏មានន័យថា គាត់មិនជឿរួចទៅហើយ ។ ចម្លើយផ្សេងៗទៀតគាត់មិនជឿ ក៏ប៉ុន្តែនេះជាចម្លើយអាខ្លួន គាត់ត្រូវតែជឿ ។

សរុបមកវិញ ដែលហៅថា "បកក្តាមបង្ហាញអាចម៍" យើងមិនទៅវាយប្រហាររបបគ្រាន់តែហានិយាយឡើង យើងមានគ្រោះថ្នាក់កំបុតកបាត់ទៅហើយទេ ។ នេះហៅថា "បកក្តាមបង្ហាញអាចម៍" ឬក៏ "ហែកពោះឲ្យក្អែកចឹក" នេះជាពាក្យខ្មែរដែលប្រើជាទូទៅ ។ ខ្ញុំសូមបញ្ចប់ត្រឹមណេះ ។

**ស៖** សូមអរគុណ ។ លោកបានជម្រាបអង្គសវនាការរួចមកហើយទាក់ទងនឹងមុនពេលលោកចូលកាន់ការងារស-២១ លោកថាបានមករៀនសូត្រ ដូចលោកចៅក្រមបានសួរមុនហ្នឹង ។ ខ្ញុំគ្រាន់តែបញ្ជាក់បន្តិចថា លោកមិនសរសេរប្រវត្តិរូបទាក់ទងជាមួយនឹងឪពុកមាបានក្មួយលោកសេនាប្រមុខ លន់ នល់ ទេ តែលោកបានជម្រាបរាមច្បងខ្លះ ។ តើលោកអាចជម្រាបអង្គសវនាការបានទេថា រាមច្បងខ្លះៗនោះអ្នកណាគេ?

[០៩:៣៦:៤៤]

**ឆ៖** អរគុណលោក គឹមសួន ដែលបានបញ្ជាក់បញ្ហានេះទៀត ។ រាមច្បងទីមួយណា គឺ ឆាយ គឹមហ៊ី ហៅ ហុក ហ្នឹង ប៉ុនកាលណោះគាត់អត់នៅជាមួយខ្ញុំទេ ។ បានខ្ញុំនឹងដល់រឿង ឆាយ គឹមហ៊ី ហៅ ហុក ហ្នឹង ពីព្រោះកាលដែលគាត់ជាប់គុក ។ គាត់លើកបញ្ហាជាគំរូជាឧទាហរណ៍ឲ្យខ្ញុំតាំងពីមុនខ្ញុំទៅជាប់គុកទៀត ។ គាត់ថានៅពេលដែលគាត់ជាប់គុក ប្រពន្ធគាត់ដើរទៅរកស្លូក ។ គាត់កំហែងនឹងប្រពន្ធគាត់ ។ គាត់ថាបើស្លូក ទោះបីជាគេឲ្យចេញក៏ដោយក៏អញមិនដើរចេញពីគុកដែរ ។ នេះគាត់ឲ្យគំរូខ្ញុំ ក្នុងការដាច់ខាតរស់នៅជាមួយបក្ស ។ នេះបង ឆាយ គឹមហ៊ី ។ ក៏ប៉ុន្តែ ពេលដែលខ្ញុំជាប់គុកខ្ញុំចេញពីគុក អូ! នៅក្នុងជាប់គុកនោះ ខ្ញុំជិតស្និទ្ធណាស់នឹង បង ទេព សៀន ហៅ ស សៀន អចិន្ត្រៃយ៍សភានោះ ដែលខ្ញុំជម្រាបលោក គឹមសួន មិញនោះ ។

ចេញពីម្តាយខ្ញុំទៅវិញ ខ្ញុំទៅជម្រាបបង សៀន ខ្ញុំថា “ម្តាយខ្ញុំទាក់ទងបានជីទួតមួយគាត់ក្មួយប្រសា តានល់” ហើយកាលនោះនៅជាឧត្តមសេនីយ៍ទេ មិនទាន់ សេនាប្រមុខទេ ។ ក្មួយតានល់ ខ្ញុំហៅតានល់ អ៊ីចឹង ។ ខ្ញុំអត់ហៅឯកឧត្តម ឧត្តមសេនីយ៍អីទេ ។ ហើយ ដល់ក្មួយតានល់ ប៉ុន្តែ តានល់ សុខចិត្តណាស់ ឲ្យខ្ញុំសរសេរញត្តិទៅយកអង្ករសាមលៀវ ។ លោក គឹមសួន ប្រហែលជាមិនស្គាល់អង្ករសាមលៀវទេ ។ អង្ករសាមលៀវជាអង្ករឆ្ងាញ់នៅខាងស្មោង កំពង់ធំ យកមកជូន តានល់ មួយបាវមក ហើយផ្អកត្រីប្រៃហើយនិងប្រហាយ ។ នេះម្តាយមីងខ្ញុំគាត់រៀបចំអ៊ីចឹង អ្នកមីង ភី ។

ដល់ទៅខ្ញុំនិយាយជម្រាប បងសៀន ទាំងអស់ហើយបានខ្ញុំថា ខ្ញុំបានឆ្លើយជាមួយម្តាយខ្ញុំអ៊ីចេះជាមួយម្តាយខ្ញុំ ខ្ញុំខំពុះពារពន្យល់គាត់ថាម៉ែអ៊ីចេះ ស្វាលោតពីដើមឈើស្អីៗអ៊ីចឹង ។ ដូច្នេះ រាមច្បងដែលខ្ញុំនៅចាំថា ខ្ញុំបាននិយាយរឿងនេះ ពីព្រោះមានពេលជិតស្និទ្ធគ្នាច្រើន គឺបងសៀន ហើយក្រោយមកដល់ពេលជួបគ្នានៅឆ្នាំ១៩៧១ បាន១ខ្ញុំជម្រាប បងហុក គឺ ឆាយ គឹមហ៊ី នេះ ។ ហើយ ខ្ញុំអត់បានជម្រាប វន វ៉េត ខ្ញុំអត់បានជម្រាប សុន សេន ទេ មិនសូវមានពេល ប្រាជ្ញព្រោកជាមួយនឹងគ្នាពី

រឿងអស់ហ្នឹងទេ ។ ដូច្នេះ និយាយពីពាក្យរាមច្បង គឺសំដៅទៅពីរនាក់ហ្នឹង ឆាយ គឹមហ៊ ហៅ ហុក ហើយនិង ស សៀន ហៅ ទេព សៀន នេះ។

[០៩:៣៩:០៩]

**ស៖** សំណួរចុងក្រោយ ឆាយ គឹមហ៊ ហៅ ហុក ដែលលោកថា បានឲ្យគាត់ដឹងពីប្រវត្តិរូប គឺជាសហការីលោកដែលធ្វើការក្នុងស-២១ ដែលលោកថា ធ្វើការជារៀងរាល់ថ្ងៃការងារច្រើនហ្នឹងមែនឬទេ?

**ឆ៖** សុំទោសណ៎ា លោក គឹមសួន ចាំឈ្មោះមនុស្សអត់អស់ទេ ។ លោក គឹមសួន ចាំឈ្មោះមនុស្សអត់អស់ទេ ។ បង ឆាយ គឹមហ៊ នេះនៅថាមពល៧ ដែលខ្ញុំចង់សុំឲ្យគាត់មកធ្វើប្រធានមន្ទីរ ស-២១ នៅពេលដែល ណាត ចេញទៅនោះ ។ នៅពេលដែលបក្សដក ណាត ចេញពីស-២១ លែងឲ្យធ្វើប្រធានស-២១ ទៅ ខ្ញុំមិនចង់ធ្វើប្រធានចង់ធ្វើនគរបាលអីទេ ។ ខ្ញុំស្នើសុំមេខ្ញុំលោកគ្រូ សុន សេន សុំអញ្ជើញបង គឹមហ៊ មកធ្វើជាប្រធាន បងគឹមហ៊ ហៅ ហុក នុ៎ង ។ ហើយនៅពេលនោះខ្ញុំអត់ទាន់ដឹងថាបក្សចាត់តាំងធំដុំជាប្រធានក្រសួងថាមពលអី ខ្ញុំអត់ដឹងទេ ។ ដឹងថា បងហុក នៅខាងថាមពល៧ ។ ខ្ញុំសុំមក មេខ្ញុំកំហែង មេខ្ញុំគាត់កំហែង លោកគ្រូ សុន សេន "ឌុច ស្អីគេហ្នឹង ក៏ខ្លាំងម្ល៉េះ អាស-២១ វាធំប៉ុនណា?" គាត់កំហែងអីចឹងមក ខ្ញុំដាក់កន្ទុយ លែងហ៊ានតមាត់ទៅទៀត ។ ដូច្នេះ ឆាយ គឹមហ៊ ហៅ ហុក នេះ គឺជាកម្មាភិបាលចាស់ ដែលអប់រំខ្ញុំតាំងពីដើមមកនោះ ។

**ស៖** សំណួរខ្ញុំតើត្រូវគ្នាទេ ជាមួយនឹងឈ្មោះមិត្តហ៊ ឬឆាយ គឹមហ៊ នេះ?

**ឆ៖** សុំទោសណា លោក គឹមសួន លោកច្រឡំមែន ។ មិត្តហ៊ អនុលេខាខ្ញុំ ឈ្មោះដើម ខឹម វ៉ាក ដែលសរសេរ ហូរហែនៅក្នុងឯកសារ ខឹម វ៉ាត តាមពិត ខឹម វ៉ាក ហៅហ៊ ។ ឯចំណែកគាត់ ឆាយ គឹមហ៊ ហៅ ហុក ។

**លោក ហុង គឹមសួន៖**

សូមអរគុណ លោកប្រធាន ។

សំណួរខ្ញុំចប់ត្រឹមនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះដល់វេទិកាមេធាវីការពារក្តី តើមេធាវីការពារក្តីហ្នឹងមានសំណួរអ្វីសួរដល់ជនជាប់ចោទដែរឬទេ? អំពីអង្គហេតុនៃការបង្កើតមន្ទីរសន្តិបាលស-២១ និងគុកនៅមន្ទីរពេទ្យឆ្កួតតាខ្មៅ ។ បើ

មានសូមអញ្ជើញ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ លោកប្រធាន ។ មេធាវីការពារក្តីមិនមានអ្វីសួរបន្ថែមទៀតទេ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រី ចៅក្រម តើមានសំណួរអ្វី ត្រូវសួរបន្ថែមដល់ជនជាប់ចោទទៀតដែរឬទេ អំពីអង្គហេតុដែលកំណត់ក្នុងការធ្វើសវនាការកន្លងមកនេះ?

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

[០៩:៤២:៣០]

**សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សេចក្តីសម្រេចទាក់ទងទៅនឹងសំណួរចុងក្រោយ ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹង ឆាយ គឹមហ៊ី ហើយនិង ហ៊ី លោកបញ្ជាក់ថាមិនមែនជាមនុស្សដូចគ្នាទេ ។ ហើយលោកថា ចង់ឲ្យលោក ឆាយ គឹមហ៊ី មកជាប្រធានស-២១ នៅក្នុងលក្ខខណ្ឌណា ដែលលោកចង់ឲ្យគាត់មកធ្វើជាប្រធាននោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ឆាយ គឹមហ៊ី ហៅ ហុក នេះជាលេខាថាមពល ក្រសួងថាមពលរបស់បក្សកុម្មុនីស្តកម្ពុជា បានន័យថា ទទួលខុសត្រូវខាងប្រេងសាំង ហើយនិងការចែកចាយប្រេងសាំងទូទាំងប្រទេស ។ ប្រេងសាំង ប្រេងម៉ាសូត ។ ដល់ចុងបញ្ចប់ មានចម្លើយឆ្លើយដាក់ ខាងលើចាប់មកស្រករ វរវាងខែ-- អ្ហេ! ចុងឆ្នាំ១៩៧៨ ឆាយ គឹមហ៊ី ហៅ ហុក ហ្នឹង ចាប់ៗមកហើយ ។ គឺបុគ្គលនេះហើយ ដែលខ្ញុំបានរាយការណ៍ជម្រាបលោកចៅក្រម ម៉ាកសែល ឡឺម៉ុង ថាខ្ញុំបានស្នើសុំដោះលែងពីរនាក់ គឺឈ្មោះ ញ៉ លេខាថ្មីរបស់កងពល៧០៣ នេះមួយ ហើយបង ឆាយ គឹមហ៊ី នេះពីរ ។ ដំបូង ពូនួន គាត់ហាក់ដូចជាចង់ដោះលែងដែរ ។ ប៉ុន្តែដល់ក្រោយមក គាត់កំហែងខ្ញុំវិញមិនឲ្យដោះលែង ។ ដូច្នេះ ឆាយ គឹមហ៊ី ហៅ ហុក នេះ មករងគ្រោះ ហើយស្លាប់បាត់ទៅហើយនៅមន្ទីរស-២១ មានទាំងរូបថតនៅពេលដែលគេកម្ទេចគាត់ គេសម្លាប់គាត់ហើយទៅទៀត ។ នេះសូមបញ្ជាក់ជូនលោកចៅក្រមប៉ុណ្ណោះ ដោយគោរព ។

[០៩:៤៤:២០]

**ប្រធានអង្គជំនុំ៖**

ដំណើរការសវនាការពិភាក្សាដេញដោលលើអង្គហេតុនៃការបង្កើតមន្ទីរសន្តិបាលស-២១ និង គុកនៅមន្ទីរពេទ្យឆ្កួតនៅតាខ្មៅបានដល់ទីបញ្ចប់ហើយ ។ ហើយជាកិច្ចបន្តនេះអង្គជំនុំជម្រះសូមជម្រាប ដល់ភាគីទាំងអស់ដែលចូលរួមក្នុងដំណើរការសវនាការ អង្គជំនុំជម្រះចាប់ផ្តើមធ្វើសវនាការជាបន្តលើ អង្គហេតុនៃការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស-២១ ។

**ស៖** លោក កាំង ហ្គេកអ៊ាវ ឥឡូវនេះ យើងចូលដល់ទៅរបៀបអង្គហេតុមួយទៀត គឺអង្គហេតុ ទីបី នៃផែនការក្នុងការគ្រប់គ្រងដឹកនាំសវនាការនៅក្នុងរឿងក្តីនេះ ។ ហើយអង្គហេតុនេះគឺអង្គហេតុ ការអនុវត្តគោលនយោបាយបក្សនៅមន្ទីរស-២១ ។ តើលោកអាចនិយាយប្រាប់ដល់អង្គសវនាការបាន អ្វីខ្លះ អំពីការអនុវត្តនូវគោលនយោបាយបក្ស នៅក្នុងមន្ទីរសន្តិបាល ស-២១ ដែលលោកនៅចងចាំ?

បើលោកអាចនិយាយបញ្ហានេះបានជូនអង្គសវនាការ សូមអញ្ជើញ ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ដំបូងខ្ញុំសូមគោរពរាយការណ៍ជូនថា គោលនយោបាយ កម្ទេចខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈមន្ទីរនគរបាល វាមានលក្ខណៈដាច់ខាត តាំងពីយូរមក ហើយ គឺចាប់តាំងពីយើងខ្ញុំទទួលភារៈ-- ខ្ញុំបាទទទួលភារៈធ្វើជាប្រធានមន្ទីរ១៣ មកម្ល៉េះ ។ មនុស្ស ដែលគេចាប់ ហើយគេចោទថាខ្មាំងមិនដោះលែងទេ ។ មកដល់មន្ទីរស-២១ ក៏គោលការណ៍នៅតែ អនុវត្ត ។ មនុស្សដែលគេចាប់មកហើយ គ្មាននរណាមានសិទ្ធិដោះលែងទេ ។

ខ្ញុំសូមជូនឧទហរណ៍មួយ ដែលបញ្ជាក់ថាគ្មានសិទ្ធិដោះលែង ។ នៅពេលដែលចាប់ផ្តើមកកើត មន្ទីរស-២១ ដំបូងនេះ យើងខ្ញុំជាមួយនិងណាត ចូលទៅរួបរួមគ្នា ពេលនុ៎ងលោកគ្រូ សុន សេន មេខ្ញុំ ហ្នឹងប្រាប់ថាមានក្មេងម្នាក់ ឈ្មោះ គង់ សុជាតិ ហៅ សឿន លេខាវរសេនាធំមិនដឹង កងពលមិនដឹង នៅភូមិភាគពាយ័ព្យ ជាកូន គង់ សុផល ហៅ កឺ មិត្តកុំអាលទាន់វ៉ៃសួរចម្លើយចាំមើលខ្ញុំសុំយោបល់ អង្គការសិន ក្រែងលអង្គការដោះលែង ។

ដល់ចុងបញ្ចប់គាត់ប្រាប់ខ្ញុំថា អង្គការមិនដោះលែងទេ សួរចម្លើយតាមធម្មតាទៅ ។ ដូច្នេះ ឈ្មោះ គង់ សុជាតិ ហៅ កឺ ហ្នឹងក៏-- (សូមទោស) គង់ សុជាតិ ហៅ សឿន នោះក៏ត្រូវតែសួរចម្លើយត ទៅទៀត ។ នេះជាឧទាហរណ៍មួយដែលខ្ញុំសូមលើកជូនថាគេមិនដោះលែងទេ ។ ក្នុងម៉ាពិសោធន៍ទាំង អស់ដែលថាមិនដោះលែងនេះ គឺវាមានជាហូរហែដល់ពិសោធន៍ចុងក្រោយ គឺពិសោធន៍ដែលខ្ញុំសុំឲ្យបាន បងញ៉ លេខាកងពល៧០៣ ត្រូវដោះលែង ហើយនិង បងហុក ឆាយ គឺមហ៊ នេះត្រូវដោះលែង តែ

ខាងលើមិនដោះលែង ។ នេះវាបញ្ជាក់ឲ្យឃើញបញ្ហានេះ ។

ហើយទន្ទឹមនេះដែរ ក៏សូមបញ្ជាក់ថា ប៉ុល ពត ខ្លួនគាត់នោះក៏អត់ទទួលស្គាល់សិទ្ធិរបស់គាត់ក្នុងការដោះលែងដែរ ។ ឧទាហរណ៍ ឈ្មោះទន្តពេទ្យ ឌី ផុន ហៅ ធុក គាត់ជាអ្នកសម្រេចឲ្យចាប់បញ្ជូលមក ស-២១ ពីរបីថ្ងៃស្រាប់តែ ពូនួន ហៅខ្ញុំទៅធ្វើការ គាត់ប្រាប់ថា “មិត្តទុកពេទ្យ ធុក ឌី ផុន កុំសម្លាប់ណា៎ កុំវ៉ៃសួរចម្លើយ មិត្តទុកឲ្យធ្វើធ្មេញមាត់មិត្តទៅ” ។ ខ្ញុំទទួល ។ ដូច្នេះ សិទ្ធិប៉ុន ប៉ុល ពត ទទួលភារៈ-- ទទួលស្គាល់សិទ្ធិរបស់ខ្លួនឯងត្រឹមតែ មិនឲ្យសម្លាប់ឲ្យនៅធ្វើជាពាក់កណ្តាលអ្នកទោស ពាក់កណ្តាលយុទ្ធជននៅមន្ទីរស-២១ នេះប៉ុននុ៎ង ។

ហើយសូមបញ្ជាក់ថា ពួកគូរ ពួកឆ្លាក់ គ្នាប៉ុន្មាននាក់នេះ បានទទួលសិទ្ធិត្រឹមតែ មិនកម្ទេច ទុកឲ្យនៅជាមួយនឹងស-២១ នេះ ពាក់កណ្តាលអ្នកទោស ពាក់កណ្តាលអ្នកមានសេរីភាពទៅអ៊ីចឹង ។

និយាយនេះហួរហែ ខ្ញុំសូមអនុញ្ញាតត្រឡប់ទៅរកគោលការណ៍ដើម ដែលខ្ញុំជម្រាបលោកប្រធានវិញ គឺមនុស្ស ឲ្យតែគេសម្រេចថា ជាខ្មាំងហើយ គេចាប់ប្រគល់មកឲ្យស-២១ ហើយ គ្មានអ្នកណាមានសិទ្ធិដោះលែងទេ ។ សូម្បីតែ ប៉ុល ពត ខ្លួនឯងដែលជាកំពូលអ្នកដឹកនាំរបស់ខ្មែរក្រហមនោះក៏គាត់មិនទទួលស្គាល់ថា គាត់មានសិទ្ធិដោះលែងដែរ ។ នេះសូមជម្រាបលោកប្រធានប៉ុណ្ណេះ ។

ហើយតទៅទៀត ខ្ញុំសូមជម្រាបថា មាគ៌ានេះ នេះជាមាគ៌ាអី? នេះជាមាគ៌ារបស់បក្ស ។ មាគ៌ារបស់បក្ស ដែលមានចែងនៅក្នុងឯកសារដំបូង អនុម័តនៅឆ្នាំ១៩៦០ នៅពេលកកើតបក្សកុម្មុយនីស្តកម្ពុជានេះ វាមានមាគ៌ាពីរប្រភេទ ។ មួយ គេហៅថា មាគ៌ាជាយុត្តិសាស្ត្រ ។ ទីពីរ គេហៅថា គោលនយោបាយជាយុទ្ធវិធីប្រមូលកម្លាំងរណសិរ្ស ។ គោលនយោបាយជាយុទ្ធវិធីប្រមូលកម្លាំងរណសិរ្ស គឺគេខំប្រមូល ប្រមូលកម្លាំងធំ ដើម្បីវាយខ្មាំងដែលឯកោ ។ នេះជាគោលនយោបាយជាយុទ្ធវិធី ។

បើតាមខ្ញុំសរុបបាន ក្នុងបក្សកុម្មុយនីស្តកម្ពុជា មុនឆ្នាំ១៩៧០ អត់ប៉ានកម្ទេចផ្ទៃក្នុងណាម្នាក់អ្ហ៊ែ! និយាយអ៊ីចឹងមិនត្រូវទេ មានម្នាក់ ។ មិនងាយប៉ះពាល់ដល់អាយុជីវិតផ្ទៃក្នុងខ្លួនឯងទេ ហើយក៏មិនដែលប៉ះពាល់ដល់អាយុជីវិតប្រជាជនកម្ពុជាដែរ ។ ផ្ទៃក្នុងខ្លួនឯងនៅជាសម្ងាត់ ។ ខ្ញុំដឹងដោយសារមានចម្លើយសារភាពរបស់ កុយ ធួន ។ មុនឆ្នាំ១៩៧០ កុយ ធួន បានកម្ទេចឈ្មោះ យុង តាមការបញ្ជារបស់បក្សខាងលើ ។ ដូច្នេះមានតែមួយហ្នឹងទេ ។ ឯចំណែកពួកក្បត់គេមាននិយាយ មាន ស៊ីវ ហេង, មាន ប៉ែន យុទ្ធ, មាន ស៊ី ផុន ហៅ ម៉ុន នេះ គេមាននិយាយ ក៏ប៉ុន្តែ អត់ប៉ានប៉ះពាល់អាយុជីវិតអ្នកអស់នុ៎ងទេ ។ ខ្ញុំបានរាយការណ៍បញ្ហានេះ ជាលាយលក្ខណ៍ អក្សរជូនចៅក្រមស៊ើបអង្កេតរួចហើយ ។

[០៩:៥២:២៨]

សរុបមកវិញ មុនឆ្នាំ១៩៧០ គេអនុវត្តគោលនយោបាយប្រមូលកម្លាំងរណសិរ្ស ។ ដល់ឆ្នាំ ១៩៧០ ក្រោយរដ្ឋប្រហារ គេមានដីរំដោះ គេមានកម្លាំងកងទ័ពខ្លះ គេចាប់ផ្ដើមអនុវត្តមាគ៌ាកាប់សម្លាប់ ដោយយកលេសថា "គិញ" កាប់សម្លាប់ដើម្បីការពារប្រជាជនក្នុងតំបន់រំដោះ ដើម្បីការពារមូលដ្ឋាន រំដោះ។ ពីឆ្នាំ១៩៧៣ ទៅគេចាប់ផ្ដើមអនុវត្តមាគ៌ាវណ្ណៈ ។ ដូចខ្ញុំជម្រាបអ៊ីចឹង ប្រជាជននៅអមលាំង ហាសិបហ្លាយ នាក់ ឬក៏ហុកសិបនាក់ អ្នកខ្លះគេថា សក្តិភូមិទៅ អ្នកខ្លះគេគិតថា ជាសក្តិភូមិទៅ ដូចអាអ្នកខ្លះគេគិតថាជាសក្តិភូមិទៅ អ្នកខ្លះគេគិតថា ជានាយទុនទៅ ។ ដូច ជាងសយ អីនេះ គ្នាជាង កាត់ដេរណ៎ា ហើយគឺគេគិតទុកថាជា នាយទុន មេឃុំ ប៉ាន់, មេឃុំ អឿង អីហ្នឹង គេទុកជាសក្តិភូមិ ទេ ។ នេះសូមបញ្ជាក់អ៊ីចឹង ។ ដល់ក្រោយមក ថ្ងៃ១៧ មេសា បានសម្រេចជោគជ័យ ឯកសារនៅសល់ ទេ ។ គេចាប់ផ្ដើមអនុវត្តមាគ៌ាហិង្សាវណ្ណៈទៅលើវណ្ណៈជិះជាន់ ។ នេះច្បាស់លាស់ ជម្លៀសប្រជាជន ចេញពីក្រុង ក៏ស្ថិតនៅក្នុងក្របខ័ណ្ឌនៃការតស៊ូវណ្ណៈ ។

លួចចាប់នាយទាហានថ្នាក់ឧត្តមសេនីយ៍ យកទៅកម្ទេចស្ងាត់ៗ ក៏ស្ថិតនៅក្នុងក្របខ័ណ្ឌនៃការ តស៊ូវណ្ណៈ លួចចាប់អ្នកនេះ អ្នកនោះ យកទៅកម្ទេចទៀតក៏ស្ថិតនៅក្នុងក្របខ័ណ្ឌនៃការតស៊ូវណ្ណៈ ។ សូមបញ្ជាក់ថា សូម្បីតែសម្ដេចព្រះសង្ឃរាជ ហួត តាត ប្រហែលជានៅក្នុងកណ្ដាប់ដៃកងពល៧០៣ ។ គ្មានឯកសារទេ ក៏ប៉ុន្តែមានជាសេចក្ដីប្រាប់មកខ្ញុំឲ្យដឹង ដោយ យូ ប៉េងគ្រី ហៅ ម៉ុន នេះមានអំណួត ។ គឺណាត ដៀលថា សម្ដេចព្រះសង្ឃរាជ ជួន-- (សុំទោស) ហួត តាត មានប្រពន្ធពីរបី ។ ដូច្នេះ យើង និយាយមួយម៉ាត់នេះ គេនិយាយមួយម៉ាត់នេះឲ្យខ្ញុំជាអនុប្រធានដឹង ។ មានន័យថា សម្ដេចសង្ឃរាជ ហួត តាត គេចមិនផុតពីកណ្ដាប់ដៃកងពល៧០៣ទេ ។ នេះសូមសរុបមកប៉ុណ្ណេះ ។

ឯឯកសារនៅសល់ គឺនៅក្នុងសៀវភៅរៀនសូត្រ ដែលបង ម៉ម ណៃ ទៅរៀនសូត្រវគ្គ ថ្ងៃ២៤ ដល់ថ្ងៃ២៧ មិថុនា ១៩៧៥ នុ៎ង ។ មូលហេតុដែលនាំឲ្យឈ្នះ គឺយើងជម្លៀសប្រជាជន យើងដេញពួក បរទេសចេញក្រៅកម្ពុជា គឺយើងបានត្រៀមឈ្នះអ៊ីចឹង នេះមូលហេតុដែលគេបញ្ជាក់ក្នុងឯកសារនោះ ។

[០៩:៥៦:០២]

សរុបមក វាច្បាស់លាស់ហើយគេចមិនរួចទេ បក្សកុម្មុយនីស្តកម្ពុជាត្រូវតែទទួលលើឧក្រិដ្ឋកម្ម ដែលខ្លួនបានប្រព្រឹត្ត ។ និយាយបក្សកុម្មុយនីស្តកម្ពុជា គឺវាទាំងអស់គ្នា ទាំងខ្ញុំទាំងគេ ដែលជាសមាជិក បក្សវាគ្រាន់តែមាគ៌ានេះ វាជាមាគ៌ារបស់អចិន្ត្រៃយ៍មជ្ឈិមប៉ុណ្ណឹង ។ ប៉ុន្តែ អ្នកដែលប្រព្រឹត្តបទឧក្រិដ្ឋដៃ

ដល់ដំបូង ក្រោយពី១៧ មេសា គឺពួកកងទ័ព ។ នេះតាមសេចក្តីសន្និដ្ឋានរបស់លិខិតបញ្ជូនសំណុំរឿងឲ្យជំនុំជម្រះរបស់ចៅក្រមស៊ើបអង្កេត ។ មែនពួកកងទ័ពទាំងអស់ ក្រោមបញ្ជារបស់លេខាភូមិភាគ គ្រប់ភូមិភាគ គឺអ៊ីចឹង ។

ដល់ក្រោយមក បានវាចេញមកមន្ទីរនគរបាលគ្រប់កន្លែងទូទាំងប្រទេស អនុវត្តមាគ៌ាមួយទៅតាមសេចក្តីសម្រេច ថ្ងៃ៣០ មីនា ១៩៧៦ ។ ថ្ងៃ៣០ មីនា ១៩៧៦ នេះ គឺអចិន្ត្រៃយ៍មជ្ឈិមបក្ស និយាយឲ្យចំ គឺគំនិតផ្តើមរបស់ ប៉ុល ពត ប្រគល់សិទ្ធិទៅឲ្យមនុស្សបួនក្រុម មានអំណាចកាប់សម្លាប់ប្រជាជនតាមទស្សនៈផលប្រយោជន៍របស់ខ្លួន របស់ពួកអាបួនក្រុមហ្នឹង ។

ខ្ញុំឃើញឯកសារនេះមានហូរហែមកហើយ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ជូនសំណុំរឿង-- អ៎!សេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ក៏ដូចជាដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ។

ខ្ញុំមានបំណង ចង់សុំលោកចៅក្រម បញ្ចាំងនៅលើអេក្រង់ ប្រសិនបើជាលោកចៅក្រមអនុញ្ញាតឯកសារ-- លោកប្រធាន (សុំទោស) បើសិនជាលោកប្រធានអនុញ្ញាត យើងខ្ញុំនឹងសុំបញ្ចាំងឯកសារនេះនៅក្នុងទំព័រ ERN00003136 ។ បើសិនជាលោកប្រធានអនុញ្ញាត ខ្ញុំសូមអនុញ្ញាតបញ្ចាំងអានេះ ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតឲ្យដាក់ឯកសារនេះបញ្ចាំងនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។ មន្ត្រីតុលាការចាត់ការ ។

*(ដំណើរការរៀបចំបញ្ចាំងឯកសាររបស់ជនជាប់ចោទ)*

ក្រឡាបញ្ជី សែ កុលវុឌ្ឍី អាននៅចំណុចត្រង់ ចំណុចសេចក្តីសម្រេចពីលេខ៣០ ខែ៣, ៧៦ រហូត មកដល់ត្រង់ចំណុចសំណូមពរ ដែលមានចំណុចទីមួយ ទីពីរ ។

[០៩:៥៩:៥៩]

**លោកស្រី សែ កុលវុឌ្ឍី៖**

ចំណុចទី២ សិទ្ធិកម្ទេចក្នុងជួរ និងក្រៅជួរ ។

សំណូមពរ៖

១) ឲ្យមានក្របខ័ណ្ឌក្នុងកិច្ចអនុវត្តផ្តាច់ការបដិវត្តន៍របស់យើង ។

២) ពង្រឹងប្រជាធិបតេយ្យសង្គមនិយមរបស់យើង ទាំងអស់គ្នាដើម្បីពង្រឹងរដ្ឋអំណាចរបស់យើង។

- បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋានត្រូវអចិន្ត្រៃយ៍ភាគសម្រេច ។
- ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមជ្ឈិម គណៈមន្ទីរមជ្ឈិមសម្រេច ។

**ប្រធានអង្គជំនុំ៖**

ម្តងទៀតអ្នកអានឲ្យយឺត ដើម្បីអ្នកបកប្រែអាចបកប្រែបាន ហើយនិងអាចសរសេរប្រតិចារឹកបាន ។ ហើយទាំងអស់នេះ មិនមែនទាំងអស់គ្នាទេ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

ខ្ញុំសូមអានម្តងទៀត ។

២) សិទ្ធិសម្រេចកម្មេចក្នុងជួរ និងក្រៅជួរ

សំណួមពរ៖

១) ឲ្យមានក្របខ័ណ្ឌក្នុងកិច្ចអនុវត្តផ្តាច់ការបដិវត្តន៍របស់យើង ។

២) ពង្រឹងប្រជាធិបតេយ្យសង្គមនិយមរបស់យើង ។ ទាំងអស់នេះ ដើម្បីពង្រឹងរដ្ឋអំណាចរបស់យើង ។

- បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋាន ត្រូវអចិន្ត្រៃយ៍ភាគសម្រេច ។
- ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច ។
- តំបន់ឯករាជ្យ ត្រូវអចិន្ត្រៃយ៍សម្រេច ។
- កងទ័ពមជ្ឈិម ត្រូវសេនាធិការសម្រេច ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ជនជាប់មានអ្វីចង់និយាយទៀតទេអំពី-- មានអ្វីត្រូវនិយាយទៀតទេអំពីបញ្ហាអនុវត្តគោលនយោបាយនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នេះខ្ញុំគ្រាន់តែចង់សូមបញ្ជាក់មួយម៉ាត់ពីរថែម ។ សិទ្ធិសម្រេចកម្មេចក្នុងជួរ និងក្រៅជួរ បានន័យថា អចិន្ត្រៃយ៍បក្សដែលមាន ប៉ុល ពត ជាកំពូលដឹកនាំប្រគល់សិទ្ធិឲ្យមនុស្សបួនក្រុមនេះ សម្រេចកម្មេច ។ មនុស្សទាំងក្នុងជួរនោះបានន័យថា ទាំងបក្ខជនទាំងកម្មាភិបាលបក្សគ្រប់ជាន់ថ្នាក់ រហូតដល់ក្រៅជួរ រហូតដល់ប្រជាជនធម្មតា ។ សំណួមពរនៃការអនុវត្តនេះខ្ញុំមិន-- សំណួមពរនៃការចេញមាគ៌ានេះ ខ្ញុំសូមមិនអធិប្បាយទេ គេច្បាស់របស់គេហើយ ។

[១០:០២:៥៦]

ខ្ញុំគ្រាន់តែសូមបញ្ជាក់ថា បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋាន ត្រូវអចិន្ត្រៃយ៍ភាគសម្រេច ក្នុងមូល-ដ្ឋានអចិន្ត្រៃយ៍ភាគសម្រេច ។ ដូច្នេះអ្នកដែលមានសិទ្ធិនៅតាមមូលដ្ឋាន មិនមែនអចិន្ត្រៃយ៍ភាគទាំងមូល

ទេ លេខាជាសំខាន់ៗ ពីព្រោះនៅកន្លែងណាក៏ដោយ នគរបាលគេទុកដូចជាកំបិតមុខពីរ ។ អ្នកកាន់អាវុធនុ៎ង វាបម្រើអ្នកនោះ ឬក៏ខ្មែរយើងថា គេប្រយ័ត្នណាស់ ប្រយ័ត្នកំបិតចិតដងឯង ។ ដូច្នេះ នៅមូលដ្ឋានអ្នកណាខិតខំពុះពារយ៉ាងម៉េចក៏ដោយ ចងក្រងឯកសារចម្លើយដែលផ្តល់មកឲ្យក៏ដោយ ក៏ត្រូវតែលេខាភាគគេជាអ្នកសម្រេចកម្ទេច ។ លេខាភាគសិទ្ធិកម្ទេចអ្នកណា ត្រូវកម្ទេចអ្នកនុ៎ង លេខាភាគទុកឲ្យអ្នកណារស់ គឺអ្នកនុ៎ងរស់ ។ ដូច្នេះ អំណាចនៅលើលេខាភាគ ។

ខ្ញុំសូមរំលងទៅដល់ទី៣ ព្រោះទី២ ក៏យើងស្រួលយល់ទេ ខ្ញុំសូមរំលងទៅដល់ទី៣ ។ តំបន់ឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេច ។ (នេះៗអត់ទេៗកុំលឿន នេះៗ)

១) នៅក្នុងក្របខ័ណ្ឌមូលដ្ឋាន ត្រូវអចិន្ត្រៃយ៍ភាគសម្រេច ។

២) ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច ។

៣) តំបន់ឯករាជ្យ ត្រូវអចិន្ត្រៃយ៍សម្រេច ។

ពាក្យអចិន្ត្រៃយ៍នេះៗ មិនមែនសំដៅស្អីទេ គឺសំដៅអចិន្ត្រៃយ៍មជ្ឈិម ដែលមាន ប៉ុល ពត ជាកំពូលដឹកនាំធំ ។ តំបន់ឯករាជ្យ មិនត្រូវសម្រេចខ្លួនឯងទេ ត្រូវឲ្យអចិន្ត្រៃយ៍សម្រេច ។ រឿងអីបានដូច្នេះ ពីព្រោះនៅតំបន់ឯករាជ្យបើតាមខ្ញុំចាំ ដូចជា តំបន់កំពង់សោមអ៊ីចឹង យកតំបន់កំពង់សោមចុះដែលស្រួលយល់ ។ តំបន់កំពង់សោម មាស មុត គាត់ធ្វើជា-- បងមុត ឈ្មោះដើម មាស មុត នោះគាត់ធ្វើជាលេខាតំបន់ឯករាជ្យកំពង់សោម ។ គាត់ចូលជាជំនួយការមជ្ឈិមទេ មិនទាន់ទៅជាសមាជិកមជ្ឈិមពេញសិទ្ធិទេ ។ ដូច្នេះ តែកាលណាមិនទាន់ទៅជាសមាជិកមជ្ឈិមពេញសិទ្ធិ មិនមានសិទ្ធិសម្រេចចាប់បក្ខជនយកទៅដាក់គុកបានទេ ។ អ្នកដែលបានចូលបក្ខជនហើយ ទាល់តែសមាជិកមជ្ឈិមពេញសិទ្ធិ ដូចបង ពក ដូចបងស៊ី ដូចបងញឹម បានៗសម្រេចបាន ។ ដូច្នេះ តំបន់ឯករាជ្យ គឺត្រូវអចិន្ត្រៃយ៍សម្រេច គឺត្រូវបង ប៉ុល គាត់សម្រេច ប៉ុល ពត អ្នកសម្រេច ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

[១០:០៥:៥០]

ឯចំណែកនៅកងទ័ពមជ្ឈិម ត្រូវសេនាធិការសម្រេច ។ សេនាធិការហ្នឹង គឺលេខាសេនាធិការហ្នឹង មិនមានអ្នកណាផ្សេងទៀតសម្រេចបានទេ គឺទាល់តែគាត់ សុន សេន ហ្នឹង បង៨៩ ហ្នឹងសម្រេចដូច្នេះ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

ដូច្នេះហើយបានជាមនុស្សដែលគេបញ្ជូនមកដល់ស-២១ ក្តី មនុស្សដែលគេបញ្ជូនទៅមន្ទីរនគរបាលផ្សេងទៀតក្តី ខ្ញុំបានជម្រាបតុលាការម្សិលមិញហើយ គ្នាស្លាប់រួចបាត់ទៅហើយ ។ ឯចំណែក

នគរបាលដែលវ៉ៃសួរចម្លើយ ឬក៏យកទៅកម្ទេចនៅជើងឯកគឺឧក្រិដ្ឋកម្មទៅលើមនុស្សស្លាប់រួចបាត់ទៅហើយ គ្នាវាស្លាប់ គេសម្រេចឲ្យសម្លាប់រួចបាត់ទៅហើយ ។ នេះបានជា ខ្ញុំសូមបញ្ហានេះឡើងវិញប៉ុណ្ណេះ ហើយសូមបញ្ចប់ការដែលអធិប្បាយលើឯកសារនេះ ជូនលោកប្រធានប៉ុណ្ណេះ ។

**ស៖** លោកបានឆ្លើយជាបន្តបន្ទាប់ពាក់ព័ន្ធជាមួយនឹងកិច្ចការនយោបាយ នៅក្នុងចំពោះខ្មាំងនេះតាំងពីនៅស-២១ បានន័យថា ក្រោយឆ្នាំ១៩៧០ គឺមានការអនុវត្តនៅគោលនយោបាយ ចំពោះខ្មាំងនេះរួចហើយ ។

សំណួរសួរថា ពីមុនមកតើមានឯកសារដូចឯកសារនេះឬទេ? ឬក៏គ្រាន់តែជាការប្រជុំផ្សព្វផ្សាយនៅក្នុងការសម្រេចចិត្តជាសន្និបាត ឬក៏ជាប្រជុំផ្សេងៗរបស់បក្ស ឬក៏របស់បក្សភាគ ឬក៏តំបន់ពិសេសជាដើមទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ។ ឯកសារសេចក្តីសម្រេចចិត្តរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួននេះ ជាឯកសារសម្ងាត់ដែលគេតម្កល់នៅតែមន្ទីរមជ្ឈិមទេ ។ ខ្ញុំបាទប្រធានមន្ទីរស-២១ អត់ដែលឃើញឯកសារនេះទេ ទើបនឹងឃើញឯកសារនេះនៅក្នុងរយៈពេលស៊ើបអង្កេត ដែលលោកចៅក្រម លោកប្រគល់ឲ្យខ្ញុំ ជាឯកសារសម្ងាត់របស់បក្ស មហាសម្ងាត់ហើយ ។ ខ្ញុំទន្ទឹមនេះដើម្បីស្រួលយល់ ខ្ញុំសូមអនុញ្ញាតជម្រាបលោកប្រធានជាបើកវង់ក្រចកបន្តិច ។

ឯកសារក្នុងបក្សកុម្មុយនីស្តកម្ពុជាមានបីប្រភេទ ។ អាប្រភេទទីមួយ គឺប្រភេទមហាសម្ងាត់នេះ ឯកសារនេះមួយ ឯកសារថ្ងៃ០៩ តុលា នេះពីរ ខ្ញុំសូមលើកឧទាហរណ៍ជូនតែប៉ុណ្ណឹង ។ អានេះគេហៅឯកសារមហាសម្ងាត់ ។ ឯកសារផ្សេងទៀត គេហៅថាឯកសារផ្ទៃក្នុងបក្ស ។ ឯកសារផ្ទៃក្នុងបក្សឧទាហរណ៍លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាជាឯកសារផ្ទៃក្នុងបក្ស ។ អ្នកណាមិនមែនជាបក្ខជនអត់មានសិទ្ធិអាន អត់មានសិទ្ធិរៀន អត់ទាន់មានសិទ្ធិពិភាក្សា នេះគេហៅថា ឯកសារផ្ទៃក្នុងបក្ស ។

ឯកសារទីបី គេហៅថាឯកសារចំហ ដែលផ្សាយទូលាយទូទៅ ។ សូមលើកឧទាហរណ៍ជូនលោកប្រធានថា ទង់បដិវត្តន៍ ជាប្រភេទឯកសារចំហ ។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ជាឯកសារចំហ ផ្សាយវិទ្យុជាឯកសារចំហរបស់បក្ស គឺសន្ទឹងន័យក៏មិនចាក់ជ្រៅទៅក្នុងការតស៊ូវណ្ណៈខ្លាំងពេកទេ ។

[១០:០៩:៣២]

សរុបមកវិញ ខ្ញុំបាទរាយការណ៍នេះ ដើម្បីបញ្ជាក់ថា តាំងពីដើមមកយើងខ្ញុំធ្វើតាមបញ្ហាគេ

ឯកសារនេះទើបតែឃើញទេ ក៏ប៉ុន្តែធ្វើតាមបញ្ជានេះវាមានឫសគល់ជាឯកសារនៅអ៊ីចឹង ។ សូមគោរពជម្រាបប៉ុណ្ណឹង ។

**ស៖** លោក កាំង ហ្គេកអ៊ាវ ស្តាប់សំណួរឲ្យបាន ។ សំណួរយើងសួរដូច្នេះថា ពីមុនមកបានន័យថា មុនមានឯកសារនេះការអនុវត្តគោលនយោបាយចំពោះខ្មាំង គឺកម្ទេចដែលមានជាហូរហែតាំងពីនិយាយរួមគឺការបង្កើតនៅមន្ទីរសន្តិសុខ សន្តិបាលម-១៣ ។ សំណួរសួរថា កាលនោះពេលដែលអនុវត្តប្រតិបត្តិការនៅមន្ទីរសន្តិសុខម-១៣ នុ៎ង តើមានប្រភេទឯកសារ ឬសេចក្តីសម្រេចរបស់មជ្ឈិមរបៀបនេះដែរឬទេ?

**ឆ៖** អរគុណលោកប្រធាន សូមគោរពឆ្លើយបញ្ជាក់ជូនដូចតទៅ ។ គ្មាន ខ្ញុំបាទគ្មានឃើញឯកសារនេះធ្លាក់ទៅដល់ដៃខ្ញុំទេ ឯកសារបែបនេះអត់ធ្លាប់-- អត់ឃើញធ្លាក់ទេ គឺតាមបញ្ជាគេ ហើយនិងជឿទុកចិត្តថា មនុស្សដែលគេបញ្ជូនឲ្យមកហើយគឺគេទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រក្នុងការចាប់ និងកម្ទេចរួចហើយ ។ យើងអនុវត្តតាមតែប៉ុណ្ណឹង ។ ហើយដូចខ្ញុំបានរាយការណ៍ជម្រាប លោកប្រធាន ហើយនិងអង្គសវនាការទាំងមូលហូរហែមកហើយដែរ ដែលខ្ញុំបានរស់នៅរហូតដល់សព្វថ្ងៃនេះគឺអត់ប៉ានសម្រេចសុំចាប់អ្នកណាទេ ។ មនុស្សដែលគេប្រគល់ឲ្យមក ទទួល បើគេប្រាប់ថា វ៉ៃសួរចម្លើយទៅ ហើយកម្ទេចទៅ ធ្វើតាមគេ នេះប៉ុណ្ណឹងឯង ។

សរុបមកត្រឡប់មកវិញ គឺខ្ញុំបាទអត់ដែលឃើញឯកសារបែបនេះទេ គឺគោរពតាមពាក្យសម្តីដែលគេបញ្ជាមកដោយផ្ទាល់មាត់ ។

[១០:១១:៣៧]

**ស៖** ដូចគ្នាផងដែរ ដែលយើងមើលអំពីកាលប្រវត្តិនៃដំណើរការ បានសេចក្តីថា តាមខ្លឹមសារនៃលិខិត គឺកាលបរិច្ឆេទចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ។ ចំណែកឯដំណើរការប្រព្រឹត្តិទៅនៃការបង្កើតស-២១ ចាប់ផ្តើមពីថ្ងៃទី១៥ ខែសីហា ១៩៧៥ ។ បានន័យថា ការបង្កើត ហើយនិងប្រតិបត្តិការរបស់ស-២១ហ្នឹង គឺកើតមុនមួយឆ្នាំ ឬក៏ជិតមួយឆ្នាំហើយ ប្រហែលជា៨ខែៗមុន ទើបមានចេញសេចក្តីសម្រេចរបស់មជ្ឈិមនេះឡើង ។ ហើយលោកបានបញ្ជាក់ហើយថ្ងៃមុនថា យកតាមលំនាំនៃគោលនយោបាយបក្សចំពោះខ្មាំងដែលធ្លាប់អនុវត្តពីមុនៗនៅម-១៣ យកមកអនុវត្តតែម្តង ដោយមិនមាននៅសេចក្តីសម្រេចឯណាបន្ថែមទៀតទេ អ៊ីចឹងមែនទេ?

**ឆ៖** លំនាំនៃការអនុវត្តនោះ ពិតជាវាតំណតាំងពីម-១៣ មកមែន ។

**ស៖** នៅក្នុងអំឡុងពេលដំបូងៗនៃការបង្កើតមន្ទីរសន្តិបាលស-២១ គឺក្នុងអំឡុងពេល អិន លន ហៅ ណាត ជាប្រធាន ហើយកាលនោះលោកជាអនុប្រធានផងដែរ ។ តើកាលដំបូងៗហ្នឹង មានការណែនាំជាគោលនយោបាយក្នុងការអនុវត្តមុខងារ បច្ចេកទេស ភារកិច្ចពី សុន សេន ដែរឬទេ អំពីកិច្ចប្រតិបត្តិការដែលនឹងអនុវត្ត សម្រាប់អនុវត្តនៅក្នុងស-២១ នោះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន ។ យើងខ្ញុំទាំងពីរចាប់ដៃពេញបន្ទុកធ្វើការងារ បើតាមចាំមិនមានឯកសារអីច្បាស់លាស់នៅឡើយទេ បើតាមចាំគឺក្នុងខែ១០ ។ ក្នុងពេលនោះ យើងខ្ញុំទៅជួបមេញឹកញាប់ជាមួយគ្នា មិនដែលគាត់ហៅទៅតែម្នាក់ទេ ទៅទាំងពីរនាក់ ។ ដូច្នេះទៅហ្នឹង ទទួលបញ្ជាការងារប្រតិបត្តិប្រចាំថ្ងៃ ពីមួយរយៈទៅមួយរយៈៗ ។ ឧទាហរណ៍ ដល់ពេលចូលទៅហ្នឹង ខ្ញុំចាំថា មនុស្សដំបូងដែលគេចោទថាខ្មាំងគឺ *សេអ៊ីអា* ហ្នឹង ឈ្មោះ លៀវ សុខសុផុនផាវិស្វករអគ្គិសនីចាប់មកពីអគ្គសនីផ្សារតូច ។ ដល់ឥឡូវគាត់ម៉េចចម្លើយលើ លៀវ សុខសុផុនផាដល់ណាហើយ ខ្ញុំរាយការណ៍ទៅ ។ នេះជាកិច្ចប្រតិបត្តិការប្រចាំ ។ ឯចំណែកគោលការណ៍ដែលថា ខ្មាំងចាប់ហើយមិនដោះលែងទៅវិញ ខ្ញុំជឿថា ទាំងខ្ញុំ ទាំងណាត ទាំងមេខ្ញុំ លោកគ្រូ សុន សេន សុទ្ធតែយល់បញ្ហានេះទាំងអស់គ្នា អត់មានអ្នកណាហ៊ានល្មើសនឹងគោលការណ៍នេះទេ ។

ដោយឡែក ពេលនោះមានលួចប្រព្រឹត្តខុសគោលការណ៍មួយអំពីសំណាក់ ណាត គឺគាត់ចាប់យុទ្ធជននៅក្នុងកងទ័ពគាត់ចាស់ដោយអត្តនោម័តិ ។ នេះមានជាបាតុភាពនៃការល្មើសគោលការណ៍ ។ បញ្ហានេះ ខ្ញុំសុំយោបល់លោកប្រធានសម្រេច តើឲ្យខ្ញុំរាយការណ៍នៅពេលនេះ ឬក៏ចាំពេលណាក្រោយដែលមានរៀបវារៈណាប៉ះពាល់ដល់កន្លែងនេះ សឹមរាយការណ៍? ហ្នឹងសុំលោកមេត្តាសម្រេច ។

[១០:១៥:៤៣]

**ស៖** កិច្ចពាក់ព័ន្ធជាមួយនឹងសកម្មភាពប្រតិបត្តិការនៅមានឱកាសច្រើន ដែលយើងនឹងទុកឱកាសសម្រាប់ទៅបកស្រាយនៅពេលនោះចុះ កន្លែងដែលសមស្រប ។

ឥឡូវនេះ អនុវត្តគោលនយោបាយ យើងចង់ដឹងពីកិច្ចការធំៗ ដែលមូលដ្ឋានគ្រឹះដែលនាំការបង្កើតនូវមន្ទីរសន្តិសុខនេះ ។ ហើយក្នុងការអនុវត្តនូវគោលនយោបាយទាំងនោះ ។

ហើយចំណុចមួយ ដោយអង្គជំនុំជម្រះមិនមានឯកសារនោះជាផ្លូវការទេ ដោយការបកស្រាយសំណើសុំរបស់សហចៅក្រមស៊ើបអង្កេតបានលិខិតទៅប្រទេសបារាំង ។ ប៉ុន្តែ មិនបានផ្តល់ជាផ្លូវការទេនូវលិខិតមួយ ដែលសវនាការលើកមុនបានសួរដេញដោលទៅ លោកបានផ្ញើលិខិតមួយតាមរយៈជន

រងគ្រោះមួយនៅម-១៣ គឺលោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ មកដល់ស្ថានទូតបារាំង ។ ហើយខ្លឹមសារ នៃលិខិតនោះសង្ខេបទៅ គឺការអនុវត្តនូវគោលនយោបាយបក្ស នៅក្នុងការកម្ទេចជនក្បត់ចំនួនប្រាំពីររូបក្នុងរបប លន់ នល់ ហើយនិងជនផ្សេងទៀតដែលមិនព្រមចុះចូលជាមួយនឹងបដិវត្តន៍ ។

ហើយទីមួយសំណួរថា តើលោកនៅចងចាំបានខ្លះទេ នៅលើខ្លឹមសារនៃលិខិតដែលខាងបដិវត្តន៍កាលនោះផ្ញើតាម ហ្វ្រង់ស្វ័រ ប៊ីហ្សូ មកដល់ទូតបារាំង?

បញ្ហាសំណួរទីពីរ គឺសួរបញ្ជាក់ថា តើគោលនយោបាយកម្ទេចជាបន្តបន្ទាប់ក្រោយថ្ងៃ១៧ មេសា ៧៥ ហ្នឹងវាស្របជាមួយនឹងខ្លឹមសារនៃលិខិតដែលផ្ញើពី ម-១៣ មកស្ថានទូតបារាំងដែរឬទេ?

**ឆ៖** សូមគោរពលោកប្រធាន ជាទីគោរព ។ ខ្ញុំសូមអនុញ្ញាត-- សូម១ ខ្ញុំសូមរាយការណ៍ជូនដូចតទៅ៖

ទីមួយ និយាយអំពីកម្មវិធីនយោបាយរណសិរ្សរួបរួមជាតិកម្ពុជា ។ កម្មវិធីនយោបាយរណសិរ្សរួបរួមជាតិកម្ពុជានេះ វាជាឯកសារចំហ និងសន្ទឹង ទាំងក្នុងប្រទេស ទាំងក្រៅប្រទេស ។ ដូច្នេះ និយាយសំខាន់អំពីការខិតខំប្រមូលកម្លាំងដោយមិនប្រកាន់និន្នាការនយោបាយ មុនរដ្ឋប្រហារថ្ងៃ១៨ មីនា ១៩៧០ ។ ហើយក៏មានជ្រុងមួយនិយាយអំពី ឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន មានន័យថាបក្សកុម្មុយនីស្តកម្ពុជា បដិវត្តន៍កម្ពុជាមិនរណបបក្សពលករវៀតណាមទេ ។ ក៏ប៉ុន្តែ អត់ទាំងប៊ានប្រើឈ្មោះនុ៎ងផងនិយាយត្រឹមតែពាក្យថា គោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន ។ គោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួននេះ ទិសដៅគឺចាក់ទៅខាងនុ៎ង ទៅខាងបក្សកុម្មុយនីស្តវៀតណាម មិនទទួលការដឹកនាំរបស់អ្នកឯងទេ ។

[១០:១៩:១២]

ដូច្នេះសរុបមកវិញ ឯកសារកម្មវិធីនយោបាយរណសិរ្សរួបរួមកម្ពុជា រួបរួមជាតិកម្ពុជានេះជាឯកសារចំហរ ទាំងក្នុងប្រទេស ទាំងក្រៅប្រទេស ។ អត់ប៊ាននិយាយអីពីរឿងសម្រិតសម្រាំង អត់ប៊ាននិយាយអីពីរឿងកម្ទេចទេ និយាយតែពីការបញ្ហាប្រមូលកម្លាំង ។ ចំហ ហើយសន្ទឹង ជាជាងគោលនយោបាយជាយុទ្ធវិធីប្រមូលដែលខ្ញុំបានរៀនជាសម្ងាត់ កាលពីឆ្នាំ១៩៦៦-៦៧ ទៅទៀត ។

ដូច្នេះ បើយើងប្រៀបធៀបថ្ងៃខែ បើតាមខ្ញុំចាំថ្ងៃ២៣ មីនា ប្រកាសបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ។ កម្មវិធីនយោបាយរណសិរ្សនេះធ្វើឡើងដោយបញ្ញាជនមួយចំនួន រួមផ្សំនៅខាងប៉េកាំង ផងមាន ហាក់សៀង ឡាយនី នេះជាដើម ។ រួបរួមគ្នាធ្វើ មិនមែនជាឯកសារចេញសុទ្ធសាធអំពីបក្សកុម្មុយ

នីស្តកម្ពុជាទេ ។ ចាប់តាំងពីក្រោយ២៣ មីនា បន្តិចចេញឯកសារនេះ ។

ឯចំណែកផែនការដែលប្រកាសថា មហាក្បត់ទាំងប្រាំពីរនាក់នោះ ដែលខ្ញុំបាទក៏មិនចាំឈ្មោះច្បាស់ អ្នកណាខ្លះដែរ ចាំឈ្មោះតែ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ, លន់ នល់, លន់ ណុន ជាដើមអីប៉ុណ្ណឹង មិនចាំច្បាស់អ្នកណាខ្លះទេ ។ ជាសេចក្តីប្រកាសនៅពេលក្នុងរយៈកាល វគ្គវាយសម្រុកផ្តាច់ព្រ័ត្រ ។ សូមបញ្ជាក់ថា វគ្គវាយសម្រុកផ្តាច់ព្រ័ត្រ នេះវាចាប់កំណើតនៅថ្ងៃ០១ មករា ១៩៧៥ ។ ដូច្នេះអាសេចក្តីប្រកាសនេះ វាជិតដល់អា១៧ មេសា ១៩៧៥ ហើយ ដែលប្រកាសកាត់ទោស កាត់ទោសមនុស្សប្រាំពីរនាក់នេះ ។

ដូច្នេះ ឯកសារទាំងពីរនេះខុសរយៈកាលគ្នា មិនទាក់ទងគ្នាទេ ។ យកខ្លឹមសារសម្រិតសម្រាំងទៅចូលក្នុងឯកសារកម្មវិធីនយោបាយរណសិរ្សរួបរួមជាតិកម្ពុជា ខុស ។ ជាការសរសេរមិនឈរលើមូលដ្ឋានឯកសារនេះ ដើម្បីសរសេរទេ ។ ជាការសរសេរដែលមិនឈរលើ ឯកសារកម្មវិធីនយោបាយរណសិរ្សរួបរួមជាតិកម្ពុជានេះ ដើម្បីវិភាគនិងសន្និដ្ឋានគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទេ។

សូមរាយការណ៍ជូនប៉ុណ្ណេះ ។

**ស៖** លោកអាចចាំបានទេ កាលពីសវនាការលើកមុន ក៏មានការសួរដេញដោលដល់បញ្ហានេះដែរចំពោះសាក្សី ហ្វ្រង់ស្វ័រ ប៊ីហ្សូ អំពីខ្លឹមសារនៃលិខិតមួយដែលលោកបានផ្ញើតាមរយៈ ហ្វ្រង់ស្វ័រ ប៊ីហ្សូ មកស្ថានទូតបារាំង ។ ហើយស្ថានទូតបារាំងតម្រូវឲ្យគាត់បកប្រែពីភាសាខ្មែរទៅភាសាបារាំង ។

តើលិខិតនុ៎ងមានខ្លឹមសារយ៉ាងម៉េចខ្លះ?

[១០:២២:១៤]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មិនមែនជាលិខិតផ្ទាល់ខ្លួនរបស់ខ្ញុំបាទទេ គឺជាឯកសាររបស់រណសិរ្សរួបរួមជាតិកម្ពុជា ។ មានចំណងថាជើងថា "កម្មវិធីនយោបាយរណសិរ្សរួបរួមជាតិកម្ពុជា" ខ្លឹមសារ ខ្ញុំបាទបានវិភាគអម្បាញ់ហើយ ជាឯកសារចំហ ទាំងក្នុងប្រទេស ទាំងលើឆាកអន្តរជាតិសម្រាប់ប្រមូលកម្លាំងគាំទ្រ ។ កម្លាំងប្រជាជនកម្ពុជាក៏ប្រមូល កម្លាំងទូត កម្លាំនយោបាយប្រទេសផ្សេងៗទៀតក៏ប្រមូល ដើម្បីគាំទ្រការតស៊ូរបស់ខ្លួនប្រឆាំងអាមេរិកកាំងប៉ុណ្ណឹង ។

ដូច្នេះ មិនមែនជាលិខិតរបស់ខ្ញុំបាទ គឺជាឯកសាររបស់រណសិរ្សរួបរួមជាតិកម្ពុជា ហើយនិងរូបថតឃោសនាការប្រមាណពីរបីសន្លឹក ដែលមានរូបថត ហ៊ូ យន់ ផង, រូបថត ហ៊ូ នឹម ផង អីនុ៎ង ដូចជាអត់មានរូបថត បង ហែម, ខៀវ សំផន ទេ នេះតាមខ្ញុំចាំ ។

សូមគោរពរាយការណ៍ជូនប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

លោក លោកស្រី តើមានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទរូបនេះទេ អំពីអង្គហេតុដែលកំពុងធ្វើសវនាការនេះ? បើមានសូមអញ្ជើញ ។

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

*(មិនមានការបកប្រែ)*

*(អ្នកបកប្រែស្ដាប់មិនបានប្រសាសន៍របស់លោកចៅក្រម ឡាវែន៍ ទេ ។)*

*(អ្នកបកប្រែអាចស្ដាប់បានហើយឥឡូវនេះ ។)*

ខ្ញុំបានបញ្ជាក់ថាព្រឹកនេះ ភាគច្រើនបានបញ្ជាក់អំពីឯកសារដែលបានលើកឡើង ដូចជាសេចក្ដីសម្រេច ឬក៏ការណែនាំរបស់បក្សកុម្មុយនីស្ដកម្ពុជា នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ។ លោកបញ្ជាក់ពីឯកសារនេះ ពីព្រឹកនេះ ។ ខ្ញុំបានបញ្ជាក់ថាឯកសារនៅក្នុង-- នូវឯកសារផ្លូវការទាំងបីច្បាប់ លោកបានយោងទៅរកលេខ ERN នេះជាឯកសារ 000313623142 ។ អត្ថបទជាភាសាអង់គ្លេសនោះគឺមានលេខ 00182809 រហូតទៅដល់ 200182814 ។ អត្ថបទភាសាបារាំងនោះលេខនោះ 00224363 រហូតទៅដល់ 00224367 ។

ខ្ញុំមានសំណួរមួយចំនួន ថាតើខ្ញុំអាចសួរឥឡូវ ឬក៏សម្រាកឥឡូវនេះ? តើលោកប្រធានលោកអនុញ្ញាតឲ្យខ្ញុំសួរពេលនេះ ឬក៏ត្រូវប្រកាសសម្រាកបាទ?

**ប្រធានអង្គជំនុំ៖**

បន្តសំណួរសិនទៅ ដើម្បីឲ្យបានកិលនូវពេលវេលាសមស្របដែលនឹងអាចឈប់សម្រាក ។

អ៊ីចឹងអាចសួរយ៉ាងតិចក៏បានមួយសំណួរ ឬពីរសិន ។

[១០:២៦:៥៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមអនុញ្ញាតមុននឹងបញ្ចូលទៅសំណួរទាក់ទង ទៅនឹងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្ដកម្ពុជានោះ ។ ខ្ញុំសូម-- យើងអនុញ្ញាតនិយាយអំពី បរិបទនៃមនោគមន៍វិជ្ជាទូទៅ ។

ចំណុចទីមួយក្នុងគោលបំណងនេះ គឺថា សំណួរទាក់ទងទៅនឹងរដ្ឋធម្មនុញ្ញនៃបក្សកុម្មុយនីស្ដ

កម្ពុជា កម្ពុជាប្រជាធិបតេយ្យ ។ ហើយឯកសារនេះ នៅក្នុងឯកសារសំណុំរឿង គឺថាវាមានពីរច្បាប់ចំពោះអត្ថបទខ្មែរ លេខ ERN នឹងគឺ 00089841 រហូតទៅដល់ 000890089 ។ អត្ថបទអង់គ្លេសនោះគឺលេខ 00184843 រហូតទៅដល់ 00184889 ។ អ៊ីចឹង មិនមានអត្ថបទជាភាសាទេនៅក្នុងសំណុំរឿង ក៏ប៉ុន្តែមានសៀវភៅមួយដែលហៅឈ្មោះថា គិតទៅ-- ហៅថា *"ឡេកូស្ទីទុយស្យុង ឌុយកាំបូដ"* ។ គឺថារដ្ឋធម្មនុញ្ញនៃកម្ពុជា គឺថាជាអត្ថបទដែលបង្ហាញដោយលោក រ៉ាអូល ម៉ាឃ្យូណែល គ្មានអត្ថបទបកប្រែ ដោយរដ្ឋធម្មនុញ្ញនៅក្នុងទំព័រ៦៥ នៃសៀវភៅនោះ ។ បើមិនមានការជំទាស់ពីភាគីទេ ខ្ញុំស្នើថាគប្បីតែដាក់ជូននូវអត្ថបទភាសាបារាំងនៅក្នុងឯកសារសំណុំរឿងនេះដែរ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

លោកប្រធាន យើងមានអត្ថបទជាភាសាបារាំង ហើយយើងថាស្ថិតនៅក្នុងឯកសារនេះ-- នៅក្នុងសំណុំរឿងគឺថានឹងលេខ ERN ខ្ញុំនឹងជម្រាបជូនលោកចៅក្រម ឡាវែន៍ ។ ជាភាសាបារាំងនោះគឺថា S0012644 រហូតទៅដល់ 12659 នៅក្នុងជាឯកសារនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ជាឯកសារ C ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកប្រធាន សូមឲ្យលោកព្រះរាជអាជ្ញាបញ្ជាក់ឡើងវិញលេខឧបសម្ព័ន្ធបាទ ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាបញ្ជាក់ម្តងទៀតលេខឧបសម្ព័ន្ធ អ្នកបកប្រែស្តាប់អត់បាន មិនអាចកត់ត្រាបានទេ ។

[១០:២៩:៥៥]

**លោក អាឡិចសាន់ឌឺ ប៊េត៖**

តាមពិតដែលខ្ញុំអាច-- នៅក្នុងដីការសន្និដ្ឋាន-- យល់ដូច្នេះគឺថា ឧបសម្ព័ន្ធ C គឺឯកសារ ៩.២ ហើយខ្ញុំសូមបញ្ជាក់ដើម្បីកំណត់ត្រាឯកសារនេះ មិនមែនជាឯកសារបកប្រែទេ ជាឯកសារច្បាប់ដើមដែល បង្កើតឡើងជាបណ្តោះអាសន្នដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

**សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកសហព្រះរាជអាជ្ញា គឺថាធ្វើឲ្យយើងមានការច្បាស់ល្អ ។

**ស៖** ដូច្នេះ លោកបានប្រាប់យើងថា តាមពិតនោះគាត់បាន១ លោកបានផ្តល់វគ្គបណ្តុះបណ្តាលនយោបាយនៅក្នុង ស-២១ ។ តើមានឯកសារណាមួយដែលលោកយកមកប្រើនៅក្នុងឯកសារនោះទេ? តើលោកបានដឹងថាពីឯកសារដែលគេប្រើនោះដែរឬទេ?

**ឆ៖** លោកចៅក្រមជាទីគោរព! ខ្ញុំសូមរាយការណ៍ជូនដូចតទៅអំពីការបណ្តុះបណ្តាលរបស់ខ្ញុំខាងនយោបាយនៅក្នុងអង្គភាពស-២១ ។ ការបណ្តុះបណ្តាលប្រចាំឆ្នាំ គឺយើងខ្ញុំធ្វើតាមមេរៀន ដែលទៅរៀននៅឯសេនាធិការនោះ ។ មេខទ្ទេសនាមមកប៉ុន្មាន ដល់ខ្ញុំចេញមកផ្ទះវិញគេឲ្យសេចក្តីសង្ខេបឬក៏អត្ថបទដែលមេខទ្ទេសនាមហ្នឹងមកឲ្យខ្ញុំ ។ ខ្ញុំយកខទ្ទេសនាមឲ្យក្នុងអង្គភាពបន្តទៅទៀត។

សូមបញ្ជាក់ម្តងទៀតថា មេរៀនដែលខ្ញុំទៅរៀនប្រើរាល់ឆ្នាំ ។ ដូច្នោះ មេរៀនដែលខ្ញុំបានខទ្ទេសនាមជូនអង្គភាពនោះក៏ប្រើរាល់ឆ្នាំដែរ ។ នេះគឺខ្ញុំបាទសុំបញ្ជាក់ប៉ុណ្ណេះ ។

ដោយឡែក ឯកសាររដ្ឋធម្មនុញ្ញ ខ្ញុំជម្រាបដោយស្មោះត្រង់ទៅ ខ្ញុំមិនដែលបានបង្រៀនទេ ។ ព្រោះអី? ព្រោះឯកសារនេះ វាមានលក្ខណៈជារបាំងសម្រាប់បិទបាំងភាពផ្តាច់ការដែលនៅក្នុងលក្ខន្តិកៈបក្ស ឬក៏នៅក្នុងមាគ៌ាជាយុទ្ធសាស្ត្ររបស់បក្ស ។ ខ្ញុំមិនបានយករបាំងនេះទៅបង្រៀនទេ ។ ឥឡូវនេះ ខ្ញុំឃ្លាតឆ្ងាយអំពីឯកសារហ្នឹងយូរហើយ ខ្ញុំមិនអាចលើកឧទាហរណ៍ អ៊ូ!មិនអាចរំលឹកឲ្យចំមាត្រាទេ ។

ដូចជាមាត្រា១៥ ជំពូក១៣ មិនដឹង និយាយអំពីសាសនា ។ ខ្ញុំសូមលើកបញ្ហានេះជូនលោកចៅក្រមដើម្បីយល់ថាឯកសារនេះវាជារបាំងយ៉ាងម៉េច ។ នៅក្នុងមាត្រា១៥ ជំពូក១៣ នេះ បើតាមខ្ញុំចាំខុសយ៉ាងម៉េច អាហ្នឹងខ្ញុំសូមអនុញ្ញាតកែប្រែមាត្រា ហើយនិងជំពូកនេះ ។ ក៏ប៉ុន្តែនៅក្នុងហ្នឹងគេនិយាយថា "ជនជាតិកម្ពុជាគ្រប់រូបមានសិទ្ធិជឿជំនឿសាសនា ហើយក៏មានសិទ្ធិមិនជឿជំនឿសាសនា តែប្រឆាំងដាច់ខាតសាសនាប្រតិកិរិយា" ។

[១០:៣៣:៥៨]

ដូច្នេះ អាឃ្លាទីមួយនោះវាជារបាំងហើយ ថាអ្នកជឿក៏គេមិនប្រកាន់ អ្នកមិនជឿក៏គេមិនប្រកាន់ ។ ដូច្នេះ អ្នកឯង អ្នកជឿ ជឿទៅកុំមករករឿងនឹងគេអ្នកមិនជឿ ។ ដូច្នេះ ជារបាំងដែលគេរៀបចំហើយស្រេចសម្រាប់ទប់ទល់ការវាយប្រហាររបស់អ្នកដែលជំនឿសាសនា ។ នេះ ខ្ញុំសូមនិយាយលើកឧទាហរណ៍នេះ គឺដើម្បីបញ្ជាក់ថា ឯកសាររដ្ឋធម្មនុញ្ញមិនមែនជាគ្រឹះសម្រាប់បណ្តុះបណ្តាលមាគ៌ា

វណ្ណៈ និងការតស៊ូវណ្ណៈទេ ។ ខ្ញុំមិនដែលបានអាន ហើយមិនដែលបានបង្រៀនទេ ។

នេះសូមជម្រាបលោកចៅក្រមឡើងវិញ ខ្ញុំបង្រៀនតែតាមឯកសារ ដែលខ្ញុំបានទៅរៀនសូត្រប្រចាំឆ្នាំ ហើយនិងឯកសារ ហើយនិងខ្លឹមសារដែលខ្ញុំបានទៅធ្វើការជាមួយនឹងមេពីបន្តបន្ទាប់ ។

នេះសូមគោរព បញ្ជាក់ជូនប៉ុណ្ណេះ ដោយគោរព ។ សូមចប់ ។

**ស៖** ដូច្នេះប្រសិនជាខ្ញុំយល់មិនខុសទេនូវអ្វីដែលលោកបញ្ជាក់នោះ គឺថាឯកសារនេះ គឺចាត់ទុកផ្សព្វផ្សាយជាសាធារណៈ ។ ប៉ុន្តែ ក៏គេយកទៅប្រើដើម្បីលាក់កំបាំងអំពីការពិតមាគ៌ានយោបាយបក្សកុម្មុយនីស្តកម្ពុជានោះផងដែរ? ឬក៏ខ្ញុំយល់ច្រឡំពីបញ្ហានេះ?

**ឆ៖** លោកចៅក្រមជាទីគោរព១ៗ! ខ្ញុំសូមបញ្ជាក់ថាការក្តាប់បានរបស់លោកចៅក្រមអំពីការដែលខ្ញុំបានរាយការណ៍ជូននេះត្រឹមត្រូវហើយ គឺរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ជារបាំង១ ដែលបានគេហៅថា *"ហ្វាសាដ"* នោះ បានដើម្បីលាក់បិទបាំងអំពើឧក្រិដ្ឋរបស់ខ្លួន ។ នេះខ្ញុំសូមបញ្ជាក់បន្ថែមតាមសំណួររបស់លោកចុងក្រោយនេះតែប៉ុណ្ណឹង ។ សូមអរគុណ ។

**ស៖** ដូច្នេះ យើង១និយាយអំពីសម័យកាលដែលគេចាត់ទុកថាជាសម័យកាលបដិវត្តន៍ ។ ដូច្នេះយើងគោរពតាមមនោគមវិជ្ជាដែលបង្កើតសង្គមមួយដែលពិសេសមួយ ។ អ៊ីចឹង ខ្ញុំនឹងអាននៅក្នុងបុព្វកថារបស់រដ្ឋធម្មនុញ្ញដែលលោកប្រាប់យើងថា ទាក់ទងទៅនឹងគោលបំណងនៃបដិវត្តន៍នោះ ។ នៅក្នុងបុព្វកថារបស់នោះបាននិយាយថា នៅក្នុងកថាខណ្ឌ១ កម្ពុជា ប្រជាជនកម្ពុជាទាំងមូល ហើយនិងបដិវត្តន៍កម្ពុជា ទ័ពបដិវត្តន៍កម្ពុជាទាំងមូល គឺថាសម្រេចពីឯករាជ្យភាព ឯកភាព សន្តិភាព អព្យាក្រឹត្យមិនចូលបក្សសម្ព័ន្ធ ហើយនិងបូរណភាពទឹកដី ។ ហើយទទួលបាននូវបូរណភាពទឹកដី សង្គមជាតិទាំងមូលគឺថា បង្កើតដោយភាពសុខមាលភាព សមភាព យុត្តិធម៌ ហើយនិងប្រជាធិបតេយ្យ ។ ដោយមិនមានអ្នកក្រ មិនមានអ្នកមាន ហើយមិនមានអ្នកវណ្ណៈជិះជាន់គេ ឬក៏វណ្ណៈដែលគេជិះជាន់ ។ ជាសង្គមមួយដែលទាំងអស់គ្នារស់នៅសុខដុមរមនាជាមួយគ្នានៅក្នុងមហាសាមគ្គីជាតិ ហើយនិងរួមកម្លាំងគ្នាដើម្បីធ្វើការងារពលកម្មជាមួយគ្នា ហើយបង្កើត និងការបង្កបង្កើនផលជាមួយគ្នាក្នុងវិស័យកសិកម្ម ។

អ៊ីចឹងតើទាក់ទងទៅនឹងចំណុចនេះ នៅក្នុងមនោគមវិជ្ជាជាគោលការណ៍បែបនេះ តើលោកយល់ថាវាឆ្លើយតបទៅនឹងអ្វីដែលថាជា *"ហ្វាសាដ"* ដែលថាជារបាំងហ្នឹង ?

**ឆ៖** តាមខ្ញុំយល់ គឺជារបាំង ។ ចាប់តាំងពីកម្ពុជាកសាងសង្គមមួយមានសុភមង្គល ។ ខ្ញុំសូមបញ្ជាក់ថា ប្រសិនបើយើងសួរថា តើសុភមង្គលដើម្បីអ្នកណា? ខ្ញុំបើសិនជាយើងសួរថា តើសុភមង្គល

ដើម្បីអ្នកណា? ជនកុម្មុយនីស្ត ។ អើយអ្នកបកប្រែអើយ ខ្ញុំនិយាយសុភមង្គល *ឡឺ បូណឺ* ។

បើសិនជាយើងសួរថា តើសុភមង្គលដើម្បីអ្នកណា? ជនកុម្មុយនីស្តកម្ពុជាជំនាន់នោះៗ ទាំងគេទាំងខ្ញុំឆ្លើយថា "សុភមង្គលដើម្បីវណ្ណៈកម្មករ-កសិករ" ។ នេះជារបាំងដែលគេនិយាយក្រោយនេះល្អមើលណាស់ ក៏ប៉ុន្តែវាបង្កប់នូវន័យអនុវត្តផ្តាច់ការនៅក្នុងហ្នឹងហើយ ។ តែកាលណាយើងនិយាយទៅគេថា "សុភមង្គលដើម្បីវណ្ណៈកម្មករនិងកសិករ" ។

ខ្ញុំសូមបញ្ចប់ប៉ុណ្ណោះ សូមគោរពរាយការណ៍ជូនប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

ដល់ម៉ោងត្រូវសម្រាកហើយ ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលមកវិញដើម្បីបន្តសវនាការតទៅទៀត ។

*[សវនាការសម្រាកពីម៉ោង ១០:៤១ នាទី ដល់ម៉ោង ១១:០៥ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តដំណើរការពិភាក្សាដេញដោលតទៅទៀត ។ ហើយជាកិច្ចបន្តនេះសូមប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីបន្តសំណួរដល់ជនជាប់ចោទជាបន្ត ។

សូមអញ្ជើញ លោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** បើអ៊ីចឹងខ្ញុំចង់ធ្វើការបញ្ជាក់បន្តិច អ្វីដែលខ្ញុំព្យាយាមចង់ទទួលបាននៅពេលដែលខ្ញុំសួរលោកនោះគឺទាក់ទងនឹងរដ្ឋធម្មនុញ្ញ គឺថាតើអ្វីដែលមាននៅក្នុងឯកសារហ្នឹង វាស៊ីគ្នាអ្វីទៅនឹងអ្វីដែលលោកជឿជាក់នៅពេលនោះ? ថាតើនេះគឺជាគោលបំណងដែលនាំឲ្យអ្នក ហើយប្រហែលជានៅពេលក្រោយនោះ យើងនឹងពិនិត្យមើល តើវាហ្នឹងស៊ីគ្នាទៅនឹងអ្វីដែលលោកបានធ្វើនៅក្នុងប្រតិបត្តិការរបស់លោកឬក៏អត់? អ៊ីចឹងខ្ញុំបានអានបុព្វកថាហើយ ហើយខ្ញុំគិតថា នេះគឺជាកម្មវិធីសម្រាប់សង្គមមួយដ៏ប្រសើរបំផុត ប៉ុន្តែលោកនិយាយថា នេះគឺជារបាំងទៅវិញ ។ តើនេះគឺជាអ្វីដែលបច្ចុប្បន្ននេះដែលលោកបានគិតថា ជារបាំងនៅពេលនេះ ឬក៏នៅពេលនុ៎ងលោកជឿថា គឺថាលោកនៅមានលទ្ធភាពដែលអាចធ្វើបានទទួលបាននូវសង្គមមួយដ៏ល្អប្រសើរបំផុតនោះ?

**ឆ៖** លោកចៅក្រមជាទីគោរព! មុននឹងឆ្លើយឲ្យចំសំណួរដែលលោកបានសួរខ្ញុំនៅពេលនេះ ខ្ញុំសូមអនុញ្ញាតបញ្ជាក់ថា អំពីជំនឿសាសនានេះ គឺនៅក្នុងជំពូក១៥ មាត្រា២០ ។ មាត្រា ហើយនិងជំពូកដែលខ្ញុំបាទរៀបរាប់ជូនលោកចៅក្រមលើកមុនខុសទេ តាមខ្ញុំចាំខុស ។

លោកចៅក្រមជាទីគោរព! ឥឡូវនេះនិយាយអំពីគោលបំណងនៃការកសាងសង្គមមួយដែលមានលក្ខណៈជាសង្គមឧត្តមគតិ ដែលប្រាថ្នាហ្នឹងវាយ៉ាងម៉េច? សង្គមដែលស្ថិតនៅក្នុងឧត្តមគិតដែលប្រាថ្នានុ៎ង គឺវាស្ថិតនៅក្នុងទ្រឹស្តីមួយដែលគេហៅថា *ម៉ាតេរ្យ៉ាអ៊ើលលីស អ៊ីសស្តូរីក* សម្ភារៈនិយមប្រវត្តិសាស្ត្រ ។ នៅក្នុងនុ៎ងគេថា សង្គមមនុស្សវាវិវឌ្ឍន៍ពីសង្គមទាសភាពមក ជាសង្គមសក្តិភូមិ ។

(សូមទោសណ៎ា អ្នកបកប្រែកុំលឿនពេក) ដំបូងគឺសង្គមសម្ហូហភាពបុព្វកាល១ ហើយចេញពីសង្គមសម្ហូហភាពបុព្វកាលមក មកជាសង្គមទាសភាព១ មកជាសង្គម វិវត្តន៍មកជាសង្គមទាសភាព ។ ហើយវិវត្តន៍ពីសង្គមទាសភាព ទៅជាសង្គមសក្តិភូមិ ។ ទៅពីសង្គមសក្តិភូមិទៅជាសង្គមមូលធននិយម។ ផុតពីសង្គមមូលធននិយម ទៅជាសង្គមសង្គមនិយម ។ ចេញពីសង្គមសង្គមនិយម បានទៅដល់សង្គមកុម្មុយនីស្តនិយម ។

[១១:១២:១២]

យើងខ្ញុំជាអ្នករៀនសូត្រទ្រឹស្តីដំបូងខ្ញុំជឿបញ្ហានេះ ។ ហើយចាប់ផ្តើមចូលចិត្តនឹងទ្រឹស្តីបែបនេះតាំងពីយើងខ្ញុំរៀននៅថ្នាក់ *ម៉ាត់តាឡែម ម៉ាតេម៉ាទិច អេឡេម៉ង់ទែរ* ។ ខ្ញុំរៀនៅថ្នាក់ *ម៉ាតេម៉ាទិច អេឡេម៉ង់ទែរ១* ។ ពេលនុ៎ងសាស្ត្រាចារ្យភូមិសាស្ត្ររបស់ខ្ញុំ *មេស្សឺ ហ្កោឡាំង* ។ *មេស្សឺ ហ្កោឡាំង* នេះគាត់ឧទ្ទេសនាមថា នៅក្នុងសង្គមសង្គមនិយមការទាក់ទងផលិតកម្ម១ តាមពាក្យស្លោកពីម្នាក់១តាមសមត្ថភាព១ ហើយត្រឡប់មកម្នាក់១វិញតាមសាច់ការ ។

ខ្ញុំសូមអនុញ្ញាតជម្រាបលោកចៅក្រមជាភាសាបារាំងចុះ នូវពាក្យដែលខ្ញុំនិយាយភាសាខ្មែរអំមិញថា “ពីម្នាក់១តាមសមត្ថភាព ហើយ១ត្រឡប់ទៅម្នាក់១វិញតាមសាច់ការ” ហ្នឹង គឺបារាំងគេថា *“ដហ្សាកាំង សឺឡុងសាកាប៉ាស៊ីតេ អេ អាហ្សាកាំង សឺឡុងសុងត្រាវ៉ៃយ៍”* (លទ្ធភាពរបស់បុគ្គលម្នាក់គឺលទ្ធភាពម្នាក់១ ហើយតម្រូវទៅតាមតម្រូវការរបស់ខ្លួន ។) ហើយដល់ទៅសង្គមកុម្មុយនីស្តនិយម គេប្រើពាក្យស្លោក “អំពីម្នាក់១តាមសមត្ថភាព ហើយត្រឡប់ទៅម្នាក់១វិញ តាមសេចក្តីត្រូវការ” ។ បានន័យថា បើសិនជាយើងប្រើជាភាសាបារាំងគេថា *ដឺហ្សាកាំង សឺឡុងសាកាប៉ាស៊ីតេ*-- គឺថាផ្អែកទៅតាមលទ្ធភាពរបស់បុគ្គលម្នាក់១ ហើយអ៊ីចឹង គឺទៅតាមសេចក្តីត្រូវការរបស់បុគ្គលម្នាក់១នោះឯង ។

ទ្រឹស្ដីនេះខ្ញុំពេញចិត្ត ។ ដល់ទៅរៀនបរិច្ចសមុប្បាទប្រវត្តិសាស្ត្រ អូ៎!សូមទោស ដល់ខ្ញុំទៅរៀនឯកសារសម្ងាត់ គឺទស្សនវិជ្ជា *ម៉ាក្សលេនីន* នោះ គេនិយាយថា សង្គមវាវិវឌ្ឍន៍ទៅអ៊ីចឹង ។ ខ្ញុំជឿ ។

ហើយដល់ក្រោយ ១៧ មេសា ឃើញការជម្លៀសប្រជាជន ហើយនិងឃើញការកាប់សម្លាប់ទាំងឈុតបែបនេះ ធ្វើឲ្យខ្ញុំខ្លោចផ្សាៗ ។ ពេលហ្នឹងហើយដែលគេលើកពាក្យស្លោកថា “មហាចលនា មហាជន មហាលោតផ្លោះ មហាអស្ចារ្យ” ។ ពាក្យស្លោកជាពាក្យខ្មែរគេថា “មហាចលនា មហាជន មហាលោតផ្លោះ មហាអស្ចារ្យ” ។ សូមទោសណ៎ា ខ្ញុំមិនកែតម្រូវទេ ទុកឲ្យវានៅអ៊ីចឹងចុះ ។

ឯចំណែកអ្នកខ្លះ គេមាននិន្នាការពន្យល់ថា ពាក្យនេះៗសំដៅការកសាងសេដ្ឋកិច្ចជឿនលឿនមហាលោតផ្លោះ ។ និយាយទៅណាឆ្ងាយ អ្នកវិភាគថា មហាលោកផ្លោះខាងសេដ្ឋកិច្ចហ្នឹង គឺសាច់ខ្ញុំឈាមខ្ញុំហ្នឹង ។ បងហែម ហ្នឹង លោកប្រធានគណៈប្រធានរដ្ឋលោក ខៀវ សំផន ហ្នឹងគាត់ពន្យល់អ៊ីចឹង ។ ខ្ញុំឃើញពាក្យហ្នឹងភរទៀតហើយ ។ (ទៅហើយៗ អ្នកបកប្រែ *អាលីញ៉េ* ណាទៀតហើយ )។ ខ្ញុំឃើញពាក្យហ្នឹងភរទៀតហើយ ពាក្យរបស់ បងហែម ហ្នឹងភរទៀតហើយ ។ ខ្ញុំឃើញថាការបកស្រាយរបស់លោក ខៀវ សំផន របស់ខ្ញុំនេះ គឺជាការបកស្រាយភូតភរ ។

រឿងពិត មហាលោតផ្លោះ ហ្នឹងគឺអី? ប៉ុល ពត ជម្លៀសប្រជាជនចេញអស់ពីក្រុងភ្នំពេញ ។ កម្ទេចអ្នករដ្ឋការចាស់ កម្ទេចនាយទុន កម្ទេចបញ្ញាជន ។ នៅសល់ស្អី? នៅសល់វណ្ណៈកម្មករកសិករ ។ *ឡាក្រ័រស៍ អ៊ូវីយ៉ែរ៍ អេពីល អ៊ីលហ្សង់* ខ្ញុំសូមកែលោកអ្នកបកប្រែបន្តិច ។ ដូច្នេះ នៅសល់វណ្ណៈកម្មករ និងកសិករនេះ សម្ងហភាពទៅទៀត ។ បានន័យថា កម្មករសម្ងហភាព ហើយនិងកសិករសម្ងហភាព មានពួក មានក្រុម មានអនុសេនាតូច មានអនុសេនាធំ មានប្រជុំជីវភាព មានរៀនសូត្រ មានការដឹកនាំ ។

[១១:២១:២២]

ឥឡូវនេះខ្ញុំសូមត្រឡប់មកសំណួររបស់លោកចៅក្រមដ៏ជាទីគោរព ដែលសួរខ្ញុំអំមិញឲ្យចំ ។ តើសប្បាយចិត្តនឹងសង្គម*ពីដេអាល់* បែប ប៉ុល ពត គាត់ធ្វើទេ? ខ្ញុំជម្រាបដោយស្មោះត្រង់រន្ធត់ណាស់នឹងការបាត់បង់អាយុជីវិតមនុស្ស ហើយមកបង្កើតតែវណ្ណៈពីរភ្លាមៗអ៊ីចឹង ។ ឥឡូវនេះខ្ញុំសូមសរុបមកវិញថា ខ្ញុំត្រឡប់មើលទៅក្រោយវិញ តើសង្គមបែបនេះជាអ្វី?

ខ្ញុំត្រឡប់មើលទៅក្រោយវិញ ខ្ញុំសូមបញ្ជាក់ថា មានអ្នកវិភាគបស្ចិមប្រទេសខ្លះគេនិយាយថាៗ ប៉ុល ពត គឺកូនសិស្ស ម៉ៅ សេទុង ជាសាវ័ករបស់ ម៉ៅ សេទុង ។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំសូមនិយាយថា

ប៉ុល ពត ទីស្ដ៍ មិនមែន ម៉ៅអ៊ីស្ដ៍ ទេ ។ ប៉ុល ពត គឺជាដំណើរពង្រីកតទៅទៀត នៃទ្រឹស្ដីរបស់អាក្រុមបួននាក់នៃមហាបដិវត្តន៍វប្បធម៌ចិន ។ អាក្រុមបួននាក់ វាដើរបានប្រាំបួនជំហាន ប៉ុល ពត គាត់លេងដប់ហើយស្រេច ។ អាក្រុមបួននាក់ (លោកអ្នកបកប្រែអាក្រុមបួននាក់ *ឡាបង់ ដេកាត់ ។ ឡាបង់ ដេកាត់* នេះនៅក្នុងមហាបដិវត្តន៍វប្បធម៌ចិន *រ៉េវ៉ូលុយស្យុង គុលទារ៉ែល* លោកអ្នកបកប្រែ) ។ ខ្ញុំសូមបញ្ជាក់ថា ប៉ុល ពត ជាទ្រឹស្ដីដែលមហាឃោរឃៅជាងទ្រឹស្ដីរបស់អាក្រុមបួននាក់នោះទៅទៀត ។ ខ្ញុំសូមបញ្ជាក់ថា នេះជាការដែលខ្ញុំមើលឃើញទៅក្រោយវិញ ។ ដល់និយាយអំពីការដែលមើលឃើញជំនាន់នោះ វាហួសចិត្តនឹងការដែលស្លាប់មនុស្សច្រើន ។ នេះហួសចិត្ត តក់ស្លុត តែមិនដឹងធ្វើម៉េច ។ វាហួសចិត្ត តែមិនដឹងធ្វើម៉េច ។ យូរៗអស់រលីងអ្នកអប់រំគ្រប់គ្រងខ្ញុំ ហើយពេលនុ៎ង ខ្ញុំអត់ទាន់ដឹងថាក្រុមគ្រួសារខ្ញុំត្រូវខ្មែចខ្មីអស់ពាក់កណ្ដាលជាង អត់ទាន់ដឹងទេ ។

ខ្ញុំសូមជម្រាបថា បើគេសួរថាម៉េចក៏មិនរត់? បើអ្នកឯងឃើញអាក្រក់អ៊ីចឹង? រត់ទៅឯណា? ទៅខាងលិចថៃ ។ រត់រួចទេ? មិនរួចទេ ។ រត់ទៅខាងកើតវៀតណាម ។ រត់រួចទេ? មិនរួចទេ ។ ថ្វីត្បិតតែគេទាស់គ្នាក៏ដោយ យើងឃើញច្បាស់ ក៏ប៉ុន្តែសួរថាគេជឿទុកចិត្តទេ? សូមទោស ឥឡូវនេះខ្ញុំអធិប្បាយវែងណាស់ សរុបមកវិញមួយម៉ាត់ *សូស្យ៉ាតេ អ៊ីឌីអាល់* ដែលខ្ញុំចង់បាន វាមិនមែនជា *សូស្យ៉ាតេ អ៊ីឌីអាល់* ដែលប៉ុល ពត គាត់ធ្វើក្រោយ ១៧ មេសា នោះទេ ។

[១១:២៧:២៩]

*សូស្យ៉ាតេ អ៊ីឌីអាល់* ដែលយើងខ្ញុំពិតប្រាកដចង់បាននោះ គឺ *សូស្យ៉ាតេ* មួយ ដែលសម្រេចតាមពាក្យស្លោកពីរម៉ាត់ដែលខ្ញុំនិយាយអម្បាញ់មិញ គឺពីម្នាក់ៗតាមសមត្ថភាព ហើយត្រឡប់ទៅម្នាក់ៗវិញតាមសាច់ការ ។ *ដឺហ្សាកាំង ស៊ីឡុងសាកាប៉ាស៊ីតេ អាហ្សាកាំង--* ។ ណាកុំលឿនពេក ។ បានហើយខ្ញុំសូមនិយាយជាខ្មែរទៅចុះណ៎ា ។ សង្គមដែលខ្ញុំចង់បាន គឺត្រឹមតែសង្គមនិយមទេ។ ។ គឺពីម្នាក់ៗតាមសមត្ថភាព ហើយត្រឡប់ទៅម្នាក់ៗវិញតាមសាច់ការ ។

សូមបញ្ចប់ពាក្យអធិប្បាយរបស់ខ្ញុំប៉ុណ្ណេះ ដោយគោរព ។

**ស៖** លោកបានបញ្ជាក់ឲ្យយើងនូវសេចក្តីពន្យល់មួយ ហើយលោកបាននិយាយថា ហើយលោកបានធ្វើដូច្នោះ ដោយរបាំងមួយ ។ ហើយខ្ញុំចូលត្រឡប់ទៅដល់ពេលមួយដែលលោកទទួលខុសត្រូវ ដែលធ្វើឲ្យយើងឈានមកដល់ពេលនេះដែលថា ក្នុងការទទួលបន្ទុកក្នុងការអនុវត្តន៍នូវនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។

**ឆ៖** នៅពេលដែលខ្ញុំឡើងធ្វើជាប្រធានមន្ទីរស-២១ បញ្ហាទស្សនៈនយោបាយដូចខ្ញុំបានរាយការណ៍ជូនអម្បាញ់មិញហើយ ។ ក៏ប៉ុន្តែ ភារកិច្ចខ្ញុំវាប៉ះពាល់ វាទទួលខុសត្រូវនៅក្នុងក្របខ័ណ្ឌនៃឧក្រិដ្ឋកម្មប្រល័យជីវិតមនុស្ស គឺវាចូលទៅក្នុងការប្រល័យជីវិតមនុស្សជាផ្ទៃក្នុងបក្សខ្លួនឯង ។ មុនដំបូងវាចាប់ផ្តើមគិតគួរភ័យព្រួយអាណោចអធម៌ដែរ ក៏ប៉ុន្តែចៀសមិនរួចត្រូវតែបង្ខំចិត្តធ្វើតទៅ ។ ដែលចាប់ផ្តើមរន្ធត់មែនទែនគឺនៅពេលដែល ថ្ងៃ៣១ ខែមករា ឆ្នាំ១៩៧៧ នៅពេលដែល សុន សេន គាត់ចាប់កម្លាំងកម្មាភិបាលឧត្តរទាំងឈុតមកនោះ (ភូមិភាគឧត្តរ១) ។ នៅពេលដែល-- ពេលនុ៎ងហើយដែលខ្ញុំចាប់ផ្តើមតក់ស្លុត ហើយនិយាយគិតថា ហើយគិតថា អ្នកដែលតស៊ូប្តូរផ្តាច់លះបង់អ្វីទាំងអស់ដើម្បីជាតិប្រជាជនខ្លួន ឥឡូវមកជាប់គុកទាំងឈុតៗក្នុងឋានៈជាអ្នកក្បត់បក្ស ។ ឃើញបែបនេះដែលរន្ធត់ ។ គ្រាន់តែមានចិត្តមួយ អើ! យើងហៅថាកំសាក មិនហ៊ានតស៊ូ ហើយធ្វើតាមគេតទៅទៀត ។ ហើយពេលខ្លះក៏បញ្ចេញសមត្ថភាព និងការយល់ដឹងរបស់ខ្លួនដើម្បីធ្វើម៉េចឲ្យតែខ្លួន និងគ្រួសារខ្លួនផ្ទាល់បានរស់ ។

[១១:៣៣:៥៩]

ដូច្នេះ សុខចិត្តធ្វើឧក្រិដ្ឋកម្មសព្វបែបយ៉ាង ហើយសុទ្ធតែជាឧក្រិដ្ឋធ្ងន់ធ្ងរផង ។ ក្នុងមួយមន្ទីរស-២១ គ្មានអ្នកណាមានលក្ខណៈឧក្រិដ្ឋជាងខ្ញុំទេ ។ នៅមន្ទីរ មនុស្សដែលមិនទាន់ដាច់ខាតខាងជំហរវណ្ណៈ ខ្ញុំរុញគេឲ្យមានជំហរវណ្ណៈ ។ ត្រូវហើយ មនុស្សដែលមិនទាន់មានជំហរវណ្ណៈដាច់ខាត ខ្ញុំអប់រំគេ រុញគេ បណ្តុះបណ្តាលគេឲ្យមានគោលជំហរវណ្ណៈដាច់ខាត ។ ខ្លួនឯងមួយដែលស្មោះត្រង់នឹងបក្ស កសាងប្អូនដប់ម្ភៃ សាមសិបនាក់ទៀត ឲ្យស្មោះត្រង់នឹងបក្ស ។ នេះត្រឹមតែស្មោះត្រង់ហ្នឹង វាម្យ៉ាងទេ បើសិនជាមានគោលវណ្ណៈទៀត ទោះបីជាយើងដឹងថា អាគោលជំហរហ្នឹង វាអន្តរាយដល់ជាតិប្រជាជនក៏ដោយ ក៏ត្រូវតែខំបំពាក់ ។ នេះដែលខ្ញុំទទួលស្គាល់ថា វាមានលក្ខណៈឧក្រិដ្ឋជាងគេ ជាងឯង មួយបែបក្នុងរឿងអប់រំ ។

ឯចំណែកម្យ៉ាងទៀត ខ្ញុំជាអ្នកចារលើសេចក្តីសារភាពជូនទៅខាងលើ ។ មនុស្សដែលគេនៅមានសេរីភាពៗ អាឯកសារហ្នឹង វាទៅធ្វើឲ្យគេ ផ្លាស់ប្តូរឈ្មោះអស់ហើយ ។ មិនយូរ មិនឆាប់ទេ ឲ្យតែឆ្លើយច្រើនៗ មកឥឡូវហើយ នេះជាឧក្រិដ្ឋមួយ ដែលធ្ងន់ជាងមិត្តផ្សេងទៀតនៅក្នុងស-២១ ។ ឯចំណែក មិត្តផ្សេងទៀតដូច មិត្តហ៊័រ អីជាដើម គ្នាទាក់ទងនឹងការឃោមកាម ក្នុងការបញ្ជាឲ្យយកទៅកម្ទេចអីៗហ្នឹង ។ ខ្ញុំសូមនិយាយម្តងទៀត គ្នាឧក្រិដ្ឋកម្មរបស់គ្នាទៅលើមនុស្សដែលស្លាប់រួចទៅហើយ

ទេ ឯចំណែកឧក្រិដ្ឋកម្មរបស់ខ្ញុំ ម្យ៉ាងបង្កើតឲ្យកូនចៅឲ្យគេឲ្យបានច្រើន មិនសុខចិត្តតែម្នាក់ឯងទេ បង្កើតកូនចៅឲ្យគេ ឲ្យបានច្រើនទៅទៀត ដែលស្មោះត្រង់ទៅនឹងគេ ។ ហើយទៅធ្វើឲ្យគ្នា អ្នកដែលនៅមានសេរីភាពហ្នឹង មានឈ្មោះប្រលាក់ប្រលូក បន្តិចទៀតហ្នឹងមកហើយ បន្តិចទៀតគេចាប់យកមកហើយ ។

សរុបមកសំណួររបស់លោកចៅក្រម អម្បាញ់មិញ ដែលចង់ដឹងថា តើគំនិតខ្ញុំជំនាន់នោះពេលណា?

គំនិតរបស់ខ្ញុំជំនាន់នោះ គឺធ្វើឧក្រិដ្ឋកម្ម ឃើញតួនាទីរបស់ខ្លួនឯង តែធ្វើម៉េច វាមិនរួច គេចវាអត់រួចទេ ។ ម្ល៉ោះហើយ ពេលខ្លះក៏ខំបញ្ចេញសមត្ថភាពរបស់ខ្លួនខាងទ្រឹស្តីកសាងកម្លាំងឲ្យគេ ។ ហើយជំរុញការអនុវត្តនៅនុ៎ងមន្ទីរស-២១ នោះ នៅឧក្រិដ្ឋកម្មតាមរូបភាពផ្សេងៗ ដែលខាងលើគេត្រូវការ ។ សរុបមក ខ្ញុំសូមរាយការណ៍ប៉ុណ្ណេះ បើសិនជាមិនទាន់ចំបញ្ហាទេ សូមលោកចៅក្រមមេត្តាបញ្ជាក់មកទៀតចុះ ។

[១១:៤០:៣៨]

**ស៖** ឥឡូវនេះ ខ្ញុំសូមបន្តធ្វើការជាមួយឯកសារមួយទៀត ជាលក្ខន្តិកៈនៃបក្សកម្មុយនីស្តកម្ពុជា ហើយនេះជាឯកសារមួយដែលចូលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៅក្នុង ៩.១ លេខ ERN នៅក្នុងអត្ថបទខ្មែរ គឺដូចខាងក្រោមនេះ 0053007 រហូតទៅដល់ 0053080 ។ ហើយនៅក្នុងអត្ថបទភាសាបារាំង 002914-002924 ហើយក្នុងអត្ថបទអង់គ្លេស 00184022 រហូតដល់ 00184047 ។ ដូច្នេះ លោកបានប្រាប់យើងពីខាងដើមថា ឯកសារនេះ គឺជាឯកសារមួយ ជាឯកសារផ្ទៃក្នុង គឺឯកសារគឺមានតែសមាជិកនៃបក្សកម្មុយនីស្តកម្ពុជាទេ ដែលអាចមើលបាន ។ តើអ៊ីចឹងពិតដែរឬទេ?

**ឆ៖** លោកចៅក្រម សេចក្តីអះអាងរបស់ខ្ញុំអម្បាញ់មិញ គឺជាការពិត ។

**ស៖** នៅបក្សកុម្មុយនីស្តកម្ពុជា គឺជាបដិវត្តន៍មួយដែលថា មាននយោបាយប្រឆាំងនឹងខ្មាំងប្រយុទ្ធនឹងខ្មាំង?

**ឆ៖** ចៅក្រម បក្សកម្មុយនីស្តកម្ពុជាតស៊ូទល់នឹងខ្មាំងៗ ។ មុន ១៧ មេសា ខ្មាំងគឺអ្នកណា? ដល់ក្រោយ១៧ មេសា ខ្មាំងគឺជាអ្នកណា? ខ្មាំងមុន១៧ មេសា បក្សកុម្មុយនីស្តកម្ពុជា កំណត់ចក្រពត្តិ សក្តិភូមិ នាយទុន ប្រតិកិរិយា ។ ចក្រពត្តិ សក្តិភូមិ នាយទុន ប្រតិកិរិយា បើតាមខ្ញុំគិត គេនិយាយជាភាសាបារាំង*ឡាំពេរ៉េអាល់លីស្មឹស អេ បុកស័រវ៉េអាក់សុងណែរ* ។ ទ្រឹស្តីរបស់បក្សកុម្មុយនីស្តកម្ពុជា

ប៉ុណ្ណឹង ប៉ុន្តែក្នុងការអនុវត្ត-- អ៊ូយ! មុន១៧ មេសា អត់ទាន់មានកម្ពុជាប្រជាធិបតេយ្យទេ អ្នកស្រី ។ ខ្ញុំនិយាយបក្សកុម្មុយនីស្តកម្ពុជា ។ មុន១៧ មេសា បក្សកុម្មុនីស្តកម្ពុជាប្រកាសជាចំហរអ៊ីចឹង ខ្មាំងសត្រូវគឺចក្រពត្តិ សក្តិភូមិ នាយទុន ប្រតិកិរិយា ។

ខ្ញុំ ដល់ក្នុងការអនុវត្ត វាប៉ះអ្នកណា? វាប៉ះខ្មែរអ្នកក្រ ដែលមកពីដី លន់ នល់ ចូលដល់ដីរំដោះ ។ គិញ ឬមិនគិញ មានខ្លះគិញ ប៉ុន្តែមានខ្លះមិនមែនគិញទេ ។ ទីពីរ ពីឆ្នាំ៧៣មក វាប៉ះប្រជាជនដែលពីដើមមកជាអ្នករកស៊ីលក់ដូរ ជាជាងកាត់ដេរ ហ្នឹងហើយខ្មាំងសត្រូវវណ្ណៈ ដែលបងស៊ី ឈ្មោះដើម ជូ ជេត បញ្ជាឲ្យគេចាប់យកមកប្រគល់ឲ្យម-១៣ ។ នេះហើយខ្មាំងដែលបក្សកុម្មុយនីស្តកម្ពុជាតស៊ូនៅសមរភូមិក្រោយមុន១៧ មេសា ។ នេះខ្ញុំមិននិយាយសមរភូមិមុខជាមួយនឹងទាហានទេ ។ នេះខ្ញុំមិននិយាយអំពីនៅសមរភូមិមុខ ជាមួយទាហានលន់ នល់ ទេ ។

ក្រោយ១៧មេសា ខ្មាំងដែលបក្សកុម្មុយនីស្តកម្ពុជាដែលបក្សកុម្មុយនីស្តកម្ពុជាៗ កំណត់ជាសត្រូវ ហើយដែលត្រូវតែតស៊ូកម្ទេចនោះ មានច្រើនណាស់ ។ យើងមើលជាមនុស្ស វាមានពួកអ្នកមុនចាស់ ទាហានចាស់ អ្នកដឹកនាំពុទ្ធសាសនា ដូចយ៉ាងសម្តេចព្រះសង្ឃរាជ ហួត តាត ។ បើនិយាយអំពីទ្រឹស្តីវិញ ប្រឆាំងនឹងគ្រប់ជំនឿសាសនាទាំងអស់ ។ បើនិយាយអំពីរបបសិក្សាធិការវិញ លុបចោលទាំងអស់ ។

[១១:៤៧:៥៣]

លោកចៅក្រមខ្លួនលោក លោកមានពិសោធន៍ហើយ ដែលសួរចម្លើយខ្ញុំ ថាហ្អែងឃើញសាលាហ្នឹង ឃើញជាសំណង់ធម្មតា ឬក៏ឃើញអី? ខ្ញុំបានឆ្លើយជម្រាបលោកដោយត្រង់ហើយ ទទួលការអប់រំបណ្តុះបណ្តាលពីគេរហូតដល់មើលឃើញសាលាហ្នឹងជាសំណង់ធម្មតា ដូចសំណង់ផ្សេងទៀត ។ មានតែពេលនេះទេ ដែលឃើញថា អាហ្នឹងវាជាការប្រឆាំងកម្ទេច អារ្យធម៌ វប្បធម៌មនុស្សជាតិ ។

សរុបមក ខ្មាំងសត្រូវក្រោយ១៧មេសា ច្រើនណាស់ រហូតដល់ឯកោខ្លួនឯង រកដីនៅគ្មាន ។ សរុបមកបើយើងនិយាយតាមទ្រឹស្តីគេ គេតស៊ូ ប៉ុន្តែក្នុងសត្រូវរបស់គេកំណត់ហ្នឹង វាពាសណា ពាសណីអស់ហើយ ។ ប៉ុន្តែ បើនិយាយតានទស្សនៈរបស់ខ្ញុំឥឡូវនេះ ដូចគំនូរដែលខ្ញុំបានជូនទៅអង្គជំនុំជម្រះអ៊ីចឹង ។ ម្នាក់ៗធ្វើការយករូបភាពបដិវត្តន៍យកមកដាក់ ក៏ប៉ុន្តែដើម្បីកសាងសន្តតិវង្សថ្មី ។ នេះខ្ញុំមានសរសេរជូនអង្គសវនាការនៅក្នុងគំនូររបស់ខ្ញុំហើយ ។ ខ្ញុំសូមចប់ការពន្យល់លើកនេះប៉ុណ្ណេះ ហើយសូមរង់ចាំនឹងឆ្លើយសំណួរបញ្ជាក់ថែមទៀត ដោយគោរព ។

[១១:៥០:៤៨]

**សះ** នៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជានោះ វាមានបញ្ជាក់ពីខ្នាំងមួយចំនួនដែលលោកបានលើកឡើងខាងដើមនោះ ។ តាមពិតជាពួកចក្រពត្តិ ពួកសក្តិភូមិ ពួកប្រតិកិរិយាជាដើមនោះ ប៉ុន្តែក៏ជាបញ្ហាមួយដែរ យើងពិនិត្យមើលគឺជាការតស៊ូប្រឆាំងនឹងឧត្តមគតិនិយម ហើយនិងចក្រពត្តិនិយម ហើយនិងរបបពួកអ្នកសេរីនិយម នៅក្នុងចំណុចទីបួន នៅក្នុងទំព័រមួយនៅក្នុងកថាខណ្ឌទីបួន ក្នុងទំព័រ -- ហើយៗនៅក្នុងកថាខណ្ឌទីប្រាំ ក៏បានបញ្ជាក់ពីចំណុចដូចខាងក្រោមនោះ ដែលថាបក្សគឺប្រឆាំងជាដាច់ខាត ប្រឆាំងនឹងជំងឺនៃការឯកោ ភាពផ្តាច់ការឃោធានិយម ហើយនិងការិយាធិបតេយ្យនិយម ហើយនៅក្នុងពេលជាមួយគ្នានោះគឺភាគីក៏ជំទាស់ខ្លួនឯងដែរទៅលើគោលការណ៍ដើម្បីការដើរថយក្រោយរបស់មហាជន ។ តើលោកអាចបញ្ជាក់ប្រាប់យើងអ្វីបន្ថែមទៀត អំពីការតស៊ូបែបនេះ? ថាតើគំនិតនៃការតស៊ូប្រឆាំងនឹងបក្សពួកខាងវិទ្យាសាស្ត្រនិយមនោះយ៉ាងដូចម្តេចដែរនោះ?

**ឆះ** លោកចៅក្រមទីគោរព! *ឡាស្យុងស៊ីលីវ៉ារ៉េស៍* ខ្ញុំបាទមិនទាន់រកឃើញទេ មិនដឹងជាចំកន្លែងណាទេ ។ គំនិត--

**សះ** នៅក្នុងឯកសាររបស់លោក តើលោកមានចំណុចមួយដែលជាចំណុចលេខបួន ដែលចាប់ផ្តើមសរសេរដូចខាងក្រោម៖ ដែលថាភាគីចាត់ទុកថា “ម៉ាក់ហ្ស៊ីស លេនីនីស្ត ជាមូលដ្ឋាននៃបក្ស” ។

ដូច្នេះនៅក្នុងប្រយោគចុងក្រោយមួយ នៅក្នុងអត្ថបទជាភាសាបារាំងនោះ គឺមានសេចក្តីដូចខាងនេះ៖

“ផ្អែកលើគោលការណ៍នេះ បក្សកុម្មុយនីស្តកម្ពុជា គឺតស៊ូប្រឆាំង ហើយនិងតស៊ូដាច់ខាតប្រឆាំងនឹងគំនិតនិយម ហើយពិសោធន៍និយម ហើយនិង*ប្មុគីសសាយអិន*” ហើយនិង តើវាផ្ទុះបញ្ចាំងពីអត្ថបទខ្លឹមសារបារាំងទេ?

**ឆះ** សូមជម្រាបលោកចៅក្រមថា គម្ពីរនិយមយើងខ្ញុំធ្លាប់ប្រើថា “*ដុកម៉ាទីស្សឹម*” ។

*(កែតម្រូវរបស់អ្នកបកប្រែគឺ គម្ពីរនិយម)*

**សះ** អ៊ីចឹង គឺថាលោកចង់និយាយថា ពាក្យ “គម្ពីរនិយម” ជាភាសា--

[១១:៥៥:០៥]

**ឆះ** ធ្លាប់ប្រើ ពាក្យថា *“ដុកម៉ាទីស្សឹម អត់ហ្សង់លីវ៉ែស៍”* ទេ ។

**សះ** តើមានន័យដូចម្តេចដែរ ពាក្យថា គម្ពីរនិយមនេះ?

**ឆ៖** ដែលហៅថា *ដុកម៉ាទីស្សឹម* គឺយើងយកទ្រឹស្តី លេនីន មកទាំងដុល មកអនុវត្តនៅស្រុកខ្មែរ ។ មិនស្របនឹងសភាពការណ៍នៅកម្ពុជា មិនស្របនឹងសភាពការណ៍កម្ពុជា ។ ឧបមាៗ លេនីន គាត់ក្តាប់កម្មករ កម្ពុជាទៅរកកម្មករឯណា ។

ដូច្នេះ បើសិនជាយើងដេកចាំតែស្វែង-- ដូច្នេះមានតែយើងទាក់ទងជាមួយនឹងវណ្ណៈកសិករហ្នឹងហើយ ដើម្បីធ្វើបដិវត្តន៍ ។ (អូ! អ្នកបកប្រែច្របូកច្របល់ហើយ)

នៅប្រទេសសហភាពសូវៀត-- នៅប្រទេសរុស្ស៊ី ដំបូងគឺមានវណ្ណៈកម្មករ ដែលបារាំងគេហៅថា "*ប្លាក្លាស៍ អូវីយែរ*" ។ ឯចំណែកនៅកម្ពុជាទៅរកៗវណ្ណៈកម្មករឯណា? យើងត្រូវក្តាប់កសិករតស៊ូ ។ នេះបើសិនជាយើងដេកចាំរកវណ្ណៈកម្មករ គឺ"យើងគម្ពីរនិយមហើយ" ។ ហ្នឹងហើយដែលៗពាក្យខាងដើម គេថាយើងយកលទ្ធិម៉ាក់លេនីន ជាមូលដ្ឋាន ។ យកតែជាមូលដ្ឋានទេ ក៏ប៉ុន្តែយើងមិនគម្ពីរនិយមទៅយកតាមទ្រឹស្តី លេនីន គ្រប់មាត់ទេ ។

ដូច្នេះ ខ្ញុំសូមជម្រាបជូនលោកចៅក្រម អំពី *ដុកម៉ាទីស្ស* ដោយខ្លីប៉ុណ្ណោះ ។ ដោយគោរព ។

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលម៉ោងត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះសាលាដំបូងប្រកាសសម្រាកដំណើរការសវនាការ ពិភាក្សាដេញដោលសម្រាប់ព្រឹកនេះត្រឹមនេះ ។ ហើយលើកទៅបន្តដំណើរការសវនាការនៅរសៀលនេះ ចាប់ពីម៉ោងមួយកន្លះទៅ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ និងឲ្យនាំគាត់មកនាំសាលសវនាការវិញ ឲ្យបានមុនម៉ោងមួយកន្លះរសៀលនេះ ជាកំណត់ ។

សូមអ្នកចូលរួមទាំងអស់ សូមអញ្ជើញឲ្យបានមុនម៉ោងកំណត់ ដូចខាងលើនៅរសៀលនេះ ។

*[សវនាការសម្រាកពីម៉ោង ១១:៥៩ នាទី ដល់ម៉ោង ១៣:៥៨នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការ ពិភាក្សាដេញដោលលើអង្គហេតុអនុវត្តគោលនយោបាយបក្សនៅមន្ទីរស-២១ ហើយសូមប្រគល់ភារៈនេះទៅចៅក្រម ហ្សង់ម៉ាក ដើម្បីបន្តសំណួរដល់ជនជាប់ចោទ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ព្រឹកមិញ យើងនិយាយអំពីលក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជា លើកលែងតែខ្ញុំយល់ច្រឡំ លោកបានលើកឡើងថា ឯកសារមួយនេះ ត្រូវបានយកមកប្រើប្រាស់ នៅក្នុងវគ្គបណ្តុះបណ្តាល ឬវគ្គរៀនសូត្រ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ដែលដឹកនាំដោយសេនាធិការមាន ។ មានបង្រៀនម្តង ។

**ស៖** បើខ្ញុំមើលទៅវាក្យខណ្ឌទី៦ ប្រយោគចុងក្រោយ គឺយើងអាចអានថា គ្រប់អង្គការបក្សត្រូវការពារបដិវត្តន៍ឲ្យបានច្រើនតាមតែអាចធ្វើទៅបាន ចំពោះគ្រប់កលល្បិចរបស់ខ្មាំង ជាផ្ទាល់ ជាប្រយោល ជាចំហ ជាសម្ងាត់ ដែលប៉ងប្រាថ្នាបំផ្លិចបំផ្លាញបក្សតាមគ្រប់វិធី ។ គ្រប់អង្គការបក្ស និងបក្ខជនគ្រប់រូបត្រូវល្អស្អាត បរិសុទ្ធខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងជានិច្ច តាមការកសាងប្រវត្តិរូបច្បាស់លាស់ និងស្អាតបរិសុទ្ធជាបន្តបន្ទាប់ ជានិច្ច ។ ដូច្នេះ តើឃ្លាជាភាសាបារាំងនេះ គឺវាស៊ីគ្នានឹងឯកសារខ្មែរដែរឬទេ? ហើយតើលោកជនជាប់ចោទ អាចប្រាប់យើងយ៉ាងម៉េចអំពីអត្ថន័យនៃប្រយោគទាំងអស់នេះ ដែលខ្ញុំទើបតែបានអាន?

**ឆ៖** លោកចៅក្រមជាទីគោរព! ការបកប្រែនេះពិបាកស្តាប់បន្តិចនៅមួយឃ្លាខាងដើម ប៉ុន្តែអត់អីទេ អត់ឃ្លាតឆ្ងាយន័យទេ តែមិនឃ្លាតពីន័យដើមឆ្ងាយពេកទេ ។ សរុបមក នៅឃ្លាខាងចុងៗចំពាក្យទាំងអស់ ។ ចំណែកឯការពន្យល់អធិប្បាយ បញ្ហានេះជាកិច្ចដំណើរការជាប្រចាំរបស់បក្សកុម្មុនីស្តកម្ពុជាទៅហើយ ។ គិតអំពីធាតុវណ្ណៈរបស់បក្ខជន វាចាប់ផ្តើមតាំងពីយូរមកហើយ ។ មកដល់គិតអំពីសមាសភាពជាបក្សជននៅក្នុងបក្ស ហើយឈានទៅធ្វើឲ្យបរិសុទ្ធនោះ គេគិតពីឆ្នាំ១៩៧៣មក ជាសំខាន់។

ខ្ញុំបានរាយការណ៍ជូនជាបន្តបន្ទាប់តាំងពីសម័យសៀមអង្កេតម៉្លេះ គឺគេប្រើពាក្យថា “មាគ៌ាវណ្ណៈណា កម្មាភិបាលវណ្ណៈនោះ” ។ បញ្ហានេះ នៅក្នុងករណីពេលនេះ ក៏វាបញ្ជាំងៗច្បាស់ថា វាបញ្ជាំងច្បាស់ម្តងទៀតថា គេគិតអំពីបក្សជនម្នាក់ៗនូវប្រវត្តិរូបនិងជីវទស្សនៈបដិវត្តន៍ ដែលស្អាតបរិសុទ្ធជាបន្តបន្ទាប់ ។ បានន័យថា មួយឆ្នាំទៅរៀនម្តង គេពិនិត្យប្រវត្តិរូបយើងម្តង មួយឆ្នាំទៅរៀនម្តង គេពិនិត្យប្រវត្តិរូបយើងម្តង គេពិនិត្យជីវទស្សនៈបដិវត្តន៍យើងម្តង ។ ជីវទស្សនៈបដិវត្តន៍យើង ក៏គេពិនិត្យរាល់ឆ្នាំដែរ ។

[១៤:០៥:១១]

**ស៖** តើលោកអាចពន្យល់នូវឃ្លានេះដែរឬទេ? ភាគីបក្សត្រូវប្រុងប្រយ័ត្នបក្សឲ្យខ្ពស់ដល់កម្រិតចំពោះគ្រប់សកម្មភាព និងគ្រប់កលល្បិចរបស់ខ្មាំងជាផ្ទាល់ ជាប្រយោល ជាចំហ ជាសម្ងាត់ ដែលប៉ងប្រាថ្នាបំផ្លិចបំផ្លាញបក្សតាមគ្រប់វិធី ។ ហើយតើវាមានន័យយ៉ាងម៉េចដែរថា របស់ខ្មាំងជាផ្ទាល់ ជាប្រយោល ជាចំហ ជាសម្ងាត់ ហ្នឹង?

**ឆ៖** លោកចៅក្រមជាទីគោរព! ឃ្លាដែលឃ្លាតន័យខ្មែរ ខ្ញុំចង់សាកល្បងជម្រាបលោកជាភាសាបារាំង ។ ឃ្លាជាភាសាខ្មែរនិយាយថា បក្សត្រូវប្រុងប្រយ័ត្នបដិវត្តន៍ឲ្យខ្ពស់ដល់កម្រិត *(ឡឺប៉ាកទីឌុយអ៊ែត វីសេឡង់អូម៉ាស៊ីម៉ូម ក៏ ពូស៊ីត)* បក្សត្រូវប្រុងប្រយ័ត្នបដិវត្តន៍ឲ្យខ្ពស់ដល់កម្រិត ។ ចំពោះគ្រប់សកម្មភាពនិងគ្រប់កលល្បិចរបស់ខ្មាំងជាផ្ទាល់និងជាប្រយោល ។ ឧទាហរណ៍ជាផ្ទាល់ ការប៉ុនប៉ងធ្វើឃាត ប៉ុល ពត គេហៅថា “សកម្មភាពបំផ្លិចបំផ្លាញជាផ្ទាល់” ។ សកម្មភាពបំផ្លាញបដិវត្តន៍ដោយប្រយោល ឧទាហរណ៍ គេនាំគ្នាប្រមូលយកជយភណ្ឌនៅភ្នំពេញយកទៅផ្ទះ យកទៅភូមិភាគរៀងខ្លួន ។ ជាសម្ងាត់ ឧបមា ជាសម្ងាត់ឧបមាដូចជា យើងកំពុងតែរៀបចំផែនការមួយ ដើម្បីបាចប្រាក់ ។ ជាចំហ គឺ ជេរ ដើរជេរហ្មង ដូចជាមានម្នាក់ហ្នឹងឈ្មោះ តូនីន ទៅជេរ អា ខៀវ អា ស ។ អា ខៀវ ហ្នឹងសំដៅលោក សុន សេន ហើយ អា ស សំដៅ ប៉ុល ពត គេចាប់ ។

ខ្ញុំសូមនិយាយឡើងវិញហើយណ៎ា ខ្ញុំសូមនិយាយឡើងវិញ មានកម្មាភិបាលម្នាក់ថ្នាក់វរសេនាធំឈ្មោះ តូនីន ដូចជានៅក្នុងកងពល៦៥០ ដើរជេរ តូនីន តូនីនៗ ។ គាត់ដើរ គាត់ជេរ ប៉ុល ពត ហៅ អា សៗ ហ្នឹងគឺសំដៅ សាឡុត ស ។ ហើយគាត់ទៅជេរ សុន សេន ថាអា ខៀវៗ ហ្នឹងគឺ សុន សេន ហៅ ខៀវ ។ ដល់ឮដល់ៗ គេចាប់យកទៅបញ្ជូនទៅស-២១ ឈ្មោះ តូនីន ។ នេះដែលគេហៅថា “ការពារបក្សអំពីឧបាយកលខ្មាំងទាំងចំហ ទាំងសម្ងាត់ ខ្មាំងបំផ្លាញបក្ស” ។ ដើម្បីច្បាស់លាស់ ខ្ញុំសូមជម្រាបជូនលោកចៅក្រមរឿងមួយដែលខ្ញុំ ហើយនិងលោកគ្រូ សុន សេន សន្ទនាគ្នា ។ ជាទូទៅ ជាប្រចាំ គេតែងតែដាស់តឿនក្រើនរំឭកបក្ខជនគ្រប់រូបឲ្យមានស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ ។

[១៤:១១:១២]

ថ្ងៃមួយនោះខ្ញុំនៅស្ងៀមៗ ស្រាប់តែដល់ ជួបទូរស័ព្ទជាមួយនឹង សុន សេន ក្រោយពីជជែកគ្នាពីការងារហើយគាត់សួរខ្ញុំ ក្រោយពីធ្វើការងាររួចហើយគាត់សួរខ្ញុំ ឌុច “បងប៉ុល គាត់ចង់ទៅមើលអាគេចោលគ្រាប់បែកប្រណាំង ។ គាត់ចង់ទៅមើលវិធីគេប្រលងប្រណាំងចោលគ្រាប់បែក តើគួរទៅឬក៏គួរកុំៗ?” ដល់អ៊ីចឹងទៅខ្ញុំថា ទេ ស្រេចនឹងបងទេ បើគាត់ចង់អញ្ជើញទៅ អញ្ជើញទៅចុះ ។ ដល់ទៅ

សុន សេន ថា "ឌុច ឯងអត់គិតលទ្ធភាពដែលវាបង្វិលខ្លួនមក ក្រោយមិនគប់គ្រាប់បែកទៅមុខ គប់គ្រាប់បែកមកក្រោយទេហ្អេ?" ដូច្នេះហើយបានយើងនិយាយថា គេប្រុងប្រយ័ត្នវាហួសពេក វាគិតតែដើរសង្ស័យគ្រប់តែគ្នា ដែល វន វ៉េត គាត់ថាទៅ ត្រដេវិច ខ្ញុំសូមរាយការណ៍បញ្ចប់ជូនការអត្ថាធិប្បាយនូវឃ្លាខាងដើមវាប៉ុណ្ណេះ ។

**ស៖** អរគុណលោកច្រើន វាប្រហែលជាមិនសូវច្បាស់នៅក្នុងឯកសារបារាំង ។ ប្រហែលនេះជាអ្វីដែលគណបក្ស បក្សកុម្មុយនីស្តកម្ពុជាគឺប្រើសម្រាប់ការពារខ្លួនឯង ហើយវាជាវិធីដែលខ្មាំងអាចកម្ទេចបក្ស នេះវាមានគោលគំនិតដូចគ្នានៅទីនេះ ។ ហើយខ្ញុំនឹងចូលទៅដល់សំណួរមួយទៀត ។ នៅក្នុងលក្ខន្តិកៈនេះដែរ ទាក់ទងទៅនឹងលក្ខណៈវិនិច្ឆ័យ លក្ខណៈសម្បត្តិដែលសមាជិកត្រូវតែមានដើម្បីចូលបក្ស ។ នៅក្នុងជំពូកទីពីរ លក្ខណៈសម្បត្តិ១០យ៉ាងដើម្បីចូលទៅក្នុងអង្គការដឹកនាំរបស់បក្ស ។ តើអ្វីទៅជាអង្គការដឹកនាំនៅទីនេះ វាមានន័យយ៉ាងម៉េច? បក្សយើងហៅថាជាអង្គការនោះ តើបក្សដែលថា យើងហៅអង្គការដឹកនាំនោះវាមានន័យយ៉ាងម៉េចដែរ?

**ឆ៖** លោកចៅក្រមជាទីគោរព! អង្គការ*ឌីរីស្យង់ ឌុយប៉ាកទី* វាមានតាមកម្រិតជាន់ថ្នាក់របស់វា ។ អង្គការដឹកនាំគណៈកម្មាធិការសាខា អង្គការដឹកនាំរបស់បក្សមានកម្រិតជាន់ថ្នាក់របស់វា ទាបបំផុតគឺ អង្គការដឹកនាំគណៈកម្មាធិការសាខា ។ ខ្ញុំមិនដែលធ្លាប់ប្រើពាក្យ "អង់តែន" ទេណ៎ា អ្នកស្រីបកប្រែ ។ ថ្នាក់គណៈកម្មាធិការដឹកនាំសាខា ថ្នាក់ដឹកនាំគណៈ-- ខ្ញុំធ្លាប់ប្រើពាក្យថា *"ឡេឌីរីស្យង់ ដេកុម្មុយតេ ដឺសែលលុល ដឺកុម្មុយតេ ដឺសែលលុល ដឺគ្រុបឺដឺសែលលុល"* ។ បាទ, ហើយខ្ពស់ទៅទៀតគឺគណៈកម្មាធិការតំបន់ ខ្ពស់ពីនោះទៅទៀតគឺគណៈកម្មាធិការភូមិភាគ ខ្ពស់ពីនោះទៅទៀតគឺគណៈកម្មាធិការមជ្ឈិមបក្ស ។ ឯចំណែកឫសគល់របស់វានៅសាខា ដែលបារាំងហៅថា *"សែលលុល"* សាខាបក្ស ។ នេះខ្ញុំត្រឡប់ទៅក្រោមបំផុតជាឫសគល់ ។ នៅឫសគល់ហ្នឹងបារាំងគេហៅថា *"សែលលុល"* ខ្មែរយើងហៅថា "សាខាបក្ស" ។ សូមរំឭកបញ្ហានេះជូនជាប្រវត្តិ ជូនលោកចៅក្រម ដើម្បីជ្រាបអំពីជប់ "ខ" ជ្រើសរើសកម្មាភិបាលនេះ ។

លក្ខន្តិកៈឆ្នាំ១៩៧០ ចាប់ផ្តើមមានអាជប់ "ខ" ជ្រើសរើសកម្មាភិបាលនេះហើយ ។ មុននោះគេប្រើលក្ខន្តិកៈឆ្នាំ១៩៦០ ។ នៅក្នុងលក្ខន្តិកៈឆ្នាំ១៩៦០ ហ្នឹងមានចែងច្បាស់ ខ្ញុំបានរៀននៅក្នុងវគ្គសម្ងាត់។ សមមិត្តណាចូលបក្សជាបក្ខជនពេញសិទ្ធិ បក្សគិតអាយុ បក្សគិតអាយុបក្សជូន ។ សមមិត្តណាមានអាយុបក្សជប់ឆ្នាំ-- ( អត់ *ប៉ារីសម* ទេណ៎ា អ្នកបកប្រែ) ។ សមមិត្តណាមានអាយុបក្សជប់ឆ្នាំ បក្ស

ពិនិត្យបេក្ខភាពមជ្ឈិម ។ លក្ខន្តិកៈបក្សឆ្នាំ១៩៧០ ចាប់ផ្តើមជម្រុះអាហ្នឹងចោល លើកអាដប់ “ខ” នេះ ។

ដូច្នេះ វាជារបាំងមួយដែល ប៉ុល ពត គាត់រៀបចំដើម្បីទប់កុំឲ្យបក្ខជនណា ជារបាំង ជាកញ្ច្រែង ជាតម្រងមួយសម្រាប់ទប់កុំឲ្យបក្ខជនណា ដែលគាត់មិនជឿទុកចិត្តចូលមក១ ក្នុងមជ្ឈិមបក្ស និងជាវិធានការការពារបក្សមួយបែប ។

ដូច្នេះ លក្ខណៈសម្បត្តិសព្វដប់ “ខ” ដែលលោកចៅក្រមលើកឡើងនេះគឺ គឺជាការជ្រើសរើសអង្គការដឹកនាំគ្រប់ថ្នាក់ តាំងពីគណៈកម្មាធិការសាខា រហូតដល់គណៈកម្មាធិការតំបន់ រហូតដល់គណៈកម្មាធិការភូមិភាគ រហូតដល់គណៈកម្មាធិការមជ្ឈិម ។ ខ្ញុំសូមរាយការណ៍ជូន ឆ្លើយជូនអំពីសំណួរនេះប៉ុណ្ណេះ ។ សូមគោរព ។

[១៤:២២:២១]

**សះ** អ៊ីចឹង គឺវា គឺលើកឡើងថាវាជាបក្ស និងអង្គការដឹកនាំរបស់បក្ស ។ ដើម្បីឲ្យនីតិវិធីនេះកាន់តែច្បាស់ ខ្ញុំនឹងអានអំពីលក្ខណៈសម្បត្តិដប់យ៉ាង ដែលលោកបានជម្រាបយើង វាជារបាំងដែល ប៉ុល ពត បានប្រើដើម្បីចម្រោះ និងរារាំង ដែលបុគ្គលមួយចំនួន ដែលគាត់ចង់ដកចេញពីបក្ស ។

១) លក្ខខណ្ឌទីមួយ ឬក៏លក្ខណៈសម្បត្តិទីមួយ ខ្ញុំនឹងសង្ខេបថា គោលជំហរបដិវត្តន៍រឹងពឹងខាងមាគ៌ានយោបាយរបស់បក្ស ។

២) លក្ខណៈសម្បត្តិទីពីរ គឺជំហរបដិវត្តន៍រឹងពឹងខាងសតិអារម្មណ៍អធន់របស់បក្ស ។

៣) លក្ខណៈសម្បត្តិទីបី ជំហរបដិវត្តន៍រឹងពឹងខាងសាមគ្គីភាព ឯកភាពផ្ទៃក្នុងរបស់បក្ស ។

៤) លក្ខណៈសម្បត្តិទីបួន ជំហរបដិវត្តន៍រឹងពឹង ខាងមាគ៌ាចាត់តាំង ដឹកនាំ និងធ្វើការងាររបស់បក្ស ។

៥) ទីប្រាំ ជំហរបដិវត្តន៍រឹងពឹង ខាងការប្រុងប្រយ័ត្នបដិវត្តន៍របស់បក្ស រក្សាការសម្ងាត់ និងការពារកម្លាំងបដិវត្តន៍ ។

៦) លក្ខណៈសម្បត្តិទីប្រាំមួយ ជំហរបដិវត្តន៍រឹងពឹងខាងឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន និងខ្លួនធ្វើជាម្ចាស់លើខ្លួនឯងរបស់បក្ស ។

៧) លក្ខណៈសម្បត្តិទីប្រាំពីរ ជំហរបដិវត្តន៍រឹងពឹង ខាងការធ្វើ និងត្រួតពិនិត្យប្រវត្តិរូប និងជីវទស្សនៈបដិវត្តន៍ ។

៨) លក្ខណៈសម្បត្តិទីប្រាំបី ជំហរបដិវត្តន៍រឹងពឹង ខាងវណ្ណភាព ។

១០) លក្ខណៈសម្បត្តិទីដប់ ជំហរបដិវត្តន៍រឹងពឹងខាងសីលធម៌រស់នៅ នៅស្អាតស្អំ និងស្អាតស្អំខាងនយោបាយ ។ លក្ខណៈសម្បត្តិមួយទៀតគឺ លទ្ធភាពកសាងខ្លួន និងទទួលនាទីដឹកនាំទៅអនាគត ។

ថាតើវាត្រឹមត្រូវនឹងឯកសារខ្មែរ ដែរឬទេ? ហើយសូមឲ្យលោកជួយពន្យល់ទៅលើឃ្លាទាំងអស់នេះប្រហែលជាឃ្លោងឃ្លា និងពាក្យទាំងអស់នេះវាពិបាកក្នុងការយល់បន្តិច ។

**ឆ៖** លោកចៅក្រមជាទីគោរព! ការបកប្រែជាភាសាបារាំង ដែលលោកអានអម្បាញ់មិញនេះត្រឹមត្រូវជាមូលដ្ឋានហើយ ។ ទីមួយ គឺមានគោលជំហរបដិវត្តន៍រឹងពឹង ខាងមាគ៌ានយោបាយរបស់បក្ស ។ គោលជំហរនយោបាយរឹងពឹងនេះ ខាងមាគ៌ានយោបាយរបស់បក្សនោះ គឺសំដៅការបែងចែកច្បាស់លាស់រវាងខ្មាំងនិងយើង, មិត្តនិងសត្រូវ ។ នេះម៉្យាង ។ ម៉្យាងទៀត យើងអនុវត្តឆ្វេង ហើយនិងយើងអនុវត្តស្តាំ ។ ពាក្យឆ្វេងនិងស្តាំ នេះជាពាក្យកាត់ទេ ពាក្យដែលគេធ្លាប់ប្រើជាទូទៅ បក្សកុម្មុយ-នីស្តផ្សេងទៀតគេប្រើ គេហៅថា “ឱកាសនិយមលម្អៀងស្តាំ និង ឱកាសនិយមលម្អៀងឆ្វេង” ។

នេះខ្ញុំសុំរាយការណ៍ជូនប៉ុណ្ណឹង លក្ខណៈសម្បត្តិទីមួយ ដែលគេទុកជាធំបំផុតនោះ ។ តាមពិតដែលហៅថា ឆ្វេង និង ស្តាំ នេះទាល់តែយើងធ្វើតាមគេគ្រប់ម៉ាត់ អាហ្នឹងបានវាមិនឆ្វេង វាមិនស្តាំ ។ ឧទាហរណ៍ បើយើងចេះតែទាមទារចាប់មនុស្ស ឲ្យតែឮចម្លើយចាប់អាហ្នឹងគេហៅថា “ឆ្វេង” អាហ្នឹងគេហៅថា “ឆ្វេង” បើកាលណាយើងមិនព្រមឲ្យចាប់នរណាសោះអាហ្នឹងហៅថា “ស្តាំ” ។ គេខំសម្រុកដុតដៃដុតជើងធ្វើការងារ យើងដេករំភើយអាហ្នឹងគេហៅថា “ស្តាំ” ។ ហើយមានអង្គភាពខ្លះដល់ចង់សម្តែងឫទ្ធិមែនទែន សែងអ្នកឈឺតាមអង្រឹងយកទៅដាក់ឲ្យមើលគេកាប់ដីៗ យើងសែងអ្នកឈឺឲ្យទៅមើលគេអ្នកកាប់ដី ហើយរុញឲ្យទៅកាប់ម្តងម្កាលទៀតអាហ្នឹងហៅថា “ឆ្វេង” ។ បន្តិចទៀត យើងឃើញឧទាហរណ៍បញ្ហាហ្នឹងហើយ នៅហ្នឹងអង្គសវនាការយើងនេះ ។ នេះហើយដែលហៅថា គោលជំហររឹងពឹង គឺប្រយ័ត្នប្រយែងសព្វគ្រប់អ៊ីចឹង ស្អីខ្មាំង ស្អីមិត្ត យើងចែក ។ ជៀសវាងកុំឲ្យមេគេថាយើងឆ្វេង ជៀសវាងកុំឲ្យមេគេថាយើងស្តាំ អាហ្នឹងបានវាសុខ ។ នេះជាគោលការណ៍ធំ សម្រាប់គេជ្រើសរើសកម្មាភិបាលហើយ ។ សរុបមកអ្នក--

[១៤:៣១:៣៨]

**ស៖** ដូច្នេះ នេះវាមានន័យថា សមាជិករបស់បក្សដែលមិនអាចអនុវត្តតាមគោលនយោបាយរបស់បក្សបាន គឺអ្នកឆ្វេង ឬយ៉ាងម៉េច?

**ឆ៖** លោកចៅក្រមជាទីគោរព! អ្នកដែលធ្វើឲ្យវាហួសហេតុ ធ្វើឲ្យមហាជនគេតក់ស្លុត ហ្នឹងហៅថា-- អ្នកដែលធ្វើហួសហេតុឲ្យមហាជនខ្លាចរអា ស្អប់ ហ្នឹងហើយដែលហៅថា "ឆ្វេង" នោះ ។ "ឆ្វេង" គឺធ្វើឲ្យខ្លាំង ពាក្យខ្មែរយើងនិយាយឲ្យស្រួលស្ដាប់ "ដុតឲ្យខ្លោច រោលឲ្យឆៅ" ។

**ស៖** ថាតើបក្សសម្រិតសម្រាំងអ្នកដែលជ្រុលនិយម សំណួរច្បាស់នោះ គឺថាតើអ្នកដែលដឹកនាំដែលល្អបំផុត គឺអ្នកដែលឋិតនៅក្រោមការគ្រប់គ្រង ឬយ៉ាងម៉េច? គឺអ្នកទាំងអស់នោះហើយ គឺថាអ្នកដែលអាចទុកចិត្តបាន ហើយអនុវត្តចំពោះគេបាន តើមានន័យដូច្នេះដែរឬទេ?

**ឆ៖** សំណួរចុងក្រោយនេះ ត្រឹមត្រូវហើយ សំណួររបស់លោកចុងក្រោយនេះត្រឹមត្រូវហើយ ។ អ្នកដឹកនាំល្អ គឺអ្នកធ្វើមិនឲ្យលើស ធ្វើមិនឲ្យខ្វះ ។ គោលបំណងគឺប៉ុណ្ណឹង គេថាអីយើងធ្វើហ្នឹង ធ្វើកុំឲ្យលើស ធ្វើកុំឲ្យខ្វះ ។

**ស៖** ហ្នឹងមិនមែនជារបាំងទេ វាជាលក្ខខណ្ឌតម្រូវទៅវិញទេ ។

**ឆ៖** លោកចៅក្រមជាទីគោរព! ការបកប្រែ "*ហ្វាសាជ*" នេះមិនត្រូវតាមខ្មែរ ដែលខ្ញុំបានជម្រាបទេ ។ ខ្ញុំដល់ឮគេបកប្រែ "*ហ្វាសាជ*" អ៊ីចឹង ខ្ញុំខំប្រាប់ថា តម្រង, របាំង ។

[១៤:៣៦:៣២]

**ស៖** ថាលោកខ្លួនឯងត្រូវបានគេដាក់រាំងចំពោះលក្ខខណ្ឌទាំងដប់ហ្នឹង តើលោកបានបំពេញទៅតាមលក្ខណៈសម្បត្តិហ្នឹងដែរឬទេ? ហើយហេតុអ្វីបានជាលោកបំពេញបាន?

**ឆ៖** បក្ខជនគ្រប់រូបដែលមានវណ្ណៈភាពដើមមិនមែនជា កសិករ ហើយគ្មានខ្សែជាមួយនឹងអ្នកសំខាន់ត្រូវតែខំផ្ចិតផ្ចង់រៀនសូត្រតាមដប់(១០) ហ្នឹង ជាពិសេសបី(៣) ខាងដើម ។ ក៏ប៉ុន្តែ ទោះបីជាខំយ៉ាងណាក៏ដោយ មិនមែនគ្នាគេ គេមិនតម្លើងយើងទេ គេអត់តម្លើងយើងទេ ។ ហើយដល់យើងឃើញអ៊ីចឹង គេនិយាយពាក្យមួយម៉ាត់មកទៀត គេថាបើអ្នកឯង បើអ្នកឯងតាំងខ្លួនថាជា មាសទឹកដប់ៗ សូមមាសទឹកដប់នោះនៅឲ្យស្ងៀម កុំឆាឆៅគេ ។ ហ្នឹងហើយដែលខ្ញុំហៅថា ជាតម្រង ជាចម្រោះ ដែលគេរើសតែគ្នាគេឡើង អ្នកណាដែលមិនមែនគ្នាគេ គេទុកចោល តែគេមិនពេញចិត្តគេ មិនមែនគឺគ្នាគេ ធ្វើអីក៏ខុសដែរ ។

**ស៖** ថាលោកជាក្រុមខាងណាដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! គេអាចចាត់ទុកខ្ញុំថា អ៊ីចឹងបានមែនៗ ។ ក៏ប៉ុន្តែ នៅពេលដែលលោកគ្រូ សុន សេន ទៅសមរភូមិបាត់ទៅ ពូនួន ឡើងមក ពូនួន ចុះមកទទួលៗ មានចម្លើយ

ឆ្លើយដាក់លោកគ្រូ សុន សេន ហួរហែ ។ ដូច្នេះ វាទៅជារឿងមួយដែលថា ខ្ញុំជាបក្សពួកខ្មែរអ្នកណា បានច្បាស់លាស់បានទេ ។ នេះសភាពការណ៍ពិតជាក់ស្តែង ហើយខ្ញុំក៏អត់ដែលបានឡើងថ្នាក់ចូលដល់ទៅមជ្ឈិម អត់ទាល់តែសោះ ហើយក៏មិនចង់ចូលដែរ ។ សុំតែមួយរស់ ភ័យខ្លាចតែមិនបានរស់ផង ។

**ស៖** ក្នុងចំណោមឯកសារដែលទាក់ទងទៅនឹងមាគ៌ារបស់បក្ស យើងឃើញមានទង់បក្សបដិវត្តន៍ ហើយយើងឃើញមានឯកសារមួយនៅក្នុងទង់បដិវត្តន៍ ដែលវាលើកឡើងអំពីលក្ខន្តិកៈ ។ នេះជាឯកសារមាននៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ គឺឯកសារ១១ ហើយលេខERN 0029614 ដល់ 002911557 ថាតើលោកដឹងដែរឬទេថា បុគ្គលណាគាត់សរសេរអត្ថបទនោះនៅក្នុងទង់បដិវត្តន៍នោះ ហើយមូលហេតុអ្វី?

**ឆ៖** ខ្ញុំសូមគោរព រាយការណ៍ជូនដូចតទៅ៖ ទស្សនាវដ្តីផ្ទៃក្នុងមានពីរ ។ ទីមួយ គឺទង់បដិវត្តន៍សរសេរដោយ ប៉ុល ពត ផ្ទាល់ដៃ ខ្ញុំសូម-- ។ ឯចំណែកទស្សនាវដ្តីយុវជនបដិវត្តន៍ បើតាមខ្ញុំដឹងមកក្រោយថា អ្នកបង យន់ យ៉ាត ប្រពន្ធលោកគ្រូ សុន សេន ជាអ្នកសរសេរ ។ ទស្សនាវដ្តីទង់បដិវត្តន៍នោះ អូ! មិនដឹងមានតាំងពីជាតិណាមកទេ ពីដើមមានឈ្មោះថា "ទង់ក្រហម" ។ ដល់ក្រោយឆ្នាំ១៩៧០ បាន១ប្រែមកថា ទង់បដិវត្តន៍ អាទង់ក្រហមនុ៎ងប្រែមកជា បដិវត្តន៍ ។ ទិសដៅគឺ ប៉ុល ពត អប់រំបក្ខជនរបស់ខ្លួនប្រចាំខែតាមទស្សនាវដ្តីនេះ ។ ឯចំណែកទស្សនាវដ្តី "យុវជនបដិវត្តន៍" ទិសដៅគឺសរសេរអប់រំយុវជន យុវនារី ដែលមិនទាន់ចូលបក្ស ។ (មិនទាន់ចូលបក្ស១) ។

សូមរាយការណ៍ចប់ប៉ុណ្ណេះ អំពីទស្សនាវដ្តី ។

**ស៖** នៅក្នុងទង់បដិវត្តន៍ដែលខ្ញុំលើកឡើងមុននេះ គឺទាក់ទងទៅនឹងវិន័យរបស់បក្ស ជាពិសេសការបញ្ចូលទទួលយកបក្ស និងការដេញចេញពីបក្ស ។ ហើយនៅក្នុងនោះ គឺវាទាក់ទងទៅនឹងមូលហេតុទាក់ទងទៅនឹងសតិអារម្មណ៍ផងដែរ ។ គឺត្រូវតែដឹកនាំតាម-- ដើរតាមបក្ស ដូច្នេះ តើលោកអាចបញ្ជាក់នៅក្នុងទីនេះដែរឬទេ?

[១៤:៤៧:៤៣]

**ឆ៖** នេះវាជាគោលការណ៍១ដែលយើងខ្ញុំធ្លាប់ប្រើនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាទេ ទាំងអស់ ។ មិនគិតគួរពិចារណាអីក៏ដោយ ត្រូវឈរលើមាគ៌ារបស់បក្ស គោលការណ៍របស់បក្ស ។ នេះខ្ញុំសូមឆ្លើយដោយខ្លីប៉ុណ្ណេះ ។

**ស៖** ខ្ញុំអត់មានសំណួរទៀតទេ ទាក់ទៅនឹងការអនុវត្តន៍ នៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ។ ប៉ុន្តែ អ្វីដែលខ្ញុំសុំស្នើនៅពេលនេះ គឺយើងគួរតែចាប់ផ្តើមពិនិត្យទៅលើឯកសារទាក់ទងទៅនឹងអង្គហេតុដែលយល់ព្រមព្រៀងគ្នា ដើម្បីឲ្យមានការអានទៅលើអង្គហេតុស្តីពីការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយបន្ទាប់ពីការបញ្ចប់កថាខណ្ឌនីមួយៗ ជនជាប់ចោទអនុញ្ញាតឲ្យជម្រាបអង្គសវនាការថា តើជនជាប់ចោទគាត់ទទួលយកទៅលើអង្គហេតុនោះដែរឬទេ? ឬក៏គាត់មានការសង្កេតណាមួយ? ហើយនឹងថានឹងអាចមានសំណួរមួយចំនួនដើម្បីបំភ្លឺទៅលើអង្គហេតុដែលបានព្រមព្រៀងគ្នា ហើយនេះជាអ្វីដែលខ្ញុំស្នើសុំឲ្យដំណើរកិច្ចដូច្នេះ ហើយនៅពេលនេះ គឺខ្ញុំស្នើសុំឲ្យក្រឡាបញ្ជីធ្វើការអានកថាខណ្ឌនីមួយៗ ។

**ប្រធានអង្គជំនុំ៖**

សូមភាគីទាំងអស់យកឯកសារដែលបានព្រមព្រៀងអង្គហេតុ ព្រមព្រៀងរវាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី យកមកពិនិត្យ ។ ហើយសុំឲ្យមេធាវីការពារក្តីរៀបចំនូវឯកសារសម្រាប់កូនក្តីរបស់ខ្លួនផង ដើម្បីលោកបានពិនិត្យមើលឯកសារទាំងអស់នោះ ។

ជនជាប់ចោទមានឯកសារអំពីអង្គហេតុដែលបានព្រមព្រៀងគ្នារួចហើយឬនៅ? សូមមេធាវីចាត់ចែងរៀបចំជូនដល់ជនជាប់ចោទ ដើម្បីពិនិត្យ ។ ហើយនាពេលនេះ គឺយកតែចំណុចអង្គហេតុអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរ ស-២១ ។

សូមអញ្ជើញបន្តទៀតលោកចៅក្រម ហ្សង់ម៉ាក តើតម្រូវឲ្យការ-- បង្អង់ៗសិនរង់ចាំមើលជនជាប់ចោទរៀបចំឯកសារស្រួលបួលសិន ។

ជនជាប់ចោទបានរៀបចំឯកសារពិនិត្យមើលស្រួលបួលហើយឬនៅ?

រួចៗហើយឬនៅ ឯកសារដែលបានព្រមព្រៀងនោះ បានរៀបចំរួចហើយ ឬនៅ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន បានហើយ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្សង់ម៉ាក តើតម្រូវឲ្យក្រឡាបញ្ជីអាននូវកថាខណ្ឌណាខ្លះ?

កថាខណ្ឌណាទៅ? កថាខណ្ឌ៥៨?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ក្រឡាបញ្ជីគួរតែអានចេញពីឯកសារខ្មែរ ។ ដូច្នេះ ក្រឡាបញ្ជីមួយរូបក្នុងចំណោមក្រឡាបញ្ជីខ្មែរ គួរតែអានគឺនិយាយអំពីគោលនយោបាយនៃការកម្ទេចខ្មាំង ។ គឺចំណុចនេះមួយ ត្រូវតែអាន ។ ឧទាហរណ៍ យើងមានចំណុច៥៨ ហើយបន្ទាប់មកយើងផ្តល់វេទិកាទៅដល់ជនជាប់ចោទ ឲ្យបញ្ជាក់ ហើយបន្ទាប់មក យើងនឹងបន្តចូលទៅមកដល់កថាខណ្ឌ៥៩ តើច្បាស់ដែរឬទេ?

ដូច្នេះ ខ្ញុំសូមអនុញ្ញាតឲ្យក្រឡាបញ្ជីធ្វើការអានលើឯកសារនេះ ។

**ប្រធានអង្គជំនុំ៖**

លោកស្រី សែ កុលវុឌ្ឍី ចាប់ផ្តើមអាន ដោយអានតាមការកំណត់អម្បាញ់មិញនេះ គឺយើងអានមួយកថាខណ្ឌម្តង ។ ដើម្បីមានការសួរបញ្ជាក់ រួចហើយទើបបន្តទៅកថាខណ្ឌមួយទៀត ហើយបន្តបន្ទាប់ទៀត ។

[១៤:៥៤:០៧]

**លោកស្រី សែ កុលវុឌ្ឍី៖**

កថាខណ្ឌ៥៨៖ តួនាទីជាចម្បងរបស់មន្ទីរ ស-២១ គឺការអនុវត្តមាគ៌ានយោបាយបក្សចំពោះខ្មាំង ដែលតាមរយៈមាគ៌ានេះ អ្នកទោសត្រូវតែកម្ទេចចោលជាដាច់ខាត ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** (គ្មានការបកប្រែ)

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ត្រឹមត្រូវតាមគោលគំនិតខ្ញុំ ។

**ស៖** ជនជាប់ចោទអាចបញ្ជាក់ដែរឬទេ?

**ឆ៖** (អត់មានការបកប្រែ)

**ស៖** យើងអត់ទទួលបានការបកប្រែនោះទេ ។ ដូច្នេះ ខ្ញុំសូមឲ្យជនជាប់បញ្ជាក់ទៅលើអ្វីដែលខ្ញុំបានអាននេះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម កថាខណ្ឌ៥៨ នេះត្រូវហើយ ។

**ស៖** យើងបន្តចូលទៅដល់កថាខណ្ឌបន្ទាប់ទៀត ។

**លោកស្រី សែ កុលវុឌ្ឍី៖**

កថាខណ្ឌទី៥៩ ពាក្យថា “កម្ទេច” បានត្រូវប្រើ និងយល់ជាទូទៅថាជា “ការសម្លាប់” ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកបាននិយាយទៅលើចំណុចអង្គហេតុនេះហើយ តែលោកអាចបញ្ជាក់ដែរឬទេ តើក្រៅពីពាក្យ “កម្ទេច” នេះ តើមានពាក្យអ្វីប្រើផ្សេងទៀតទេ សម្រាប់ពាក្យ “សម្លាប់” នោះ?

**ឆ៖** លោកចៅក្រមជាទីគោរព! ។ លោកចៅក្រមជាទីគោរព! ពាក្យ “កម្ទេច” នេះប្រើស្មើនឹងពាក្យ “សម្លាប់” ។ មុនឆ្នាំ១៩៧៣ បងវន គឺ វន វ៉េត ឲ្យខ្ញុំប្រើពាក្យ “ដោះស្រាយ” ។ ដូច្នេះ “ដោះស្រាយ, សម្លាប់ ឬកម្ទេច ឬវាយចោល” វាមានន័យប្រហែលគ្នា ។ គឺជីវិតមនុស្សម្នាក់ត្រូវគេយកទៅប្រហារ ហើយកប់ចោល ។ ឯចំណែកពាក្យដែលខ្មែរក្រហមប្រើពាក្យ “សម្រិតសម្រាំង” វាមានទិដ្ឋភាពផ្សេងពីនេះបន្តិច ។ គឺគេចាប់ គឺគេសម្រេចឲ្យចាប់មនុស្សពីក្នុងអង្គភាពបញ្ជូនទៅនគរបាល ។ នេះហៅថា “សម្រិតសម្រាំង” ។ សម្រិតសម្រាំងអង្គភាព គឺចាប់មនុស្សដែលគេសង្ស័យថាខ្មាំងចេញពីអង្គភាពនោះ ។ ទុកឲ្យអង្គភាពនោះស្អាតបរិសុទ្ធ តាមគំនិតគេ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដូច្នេះ ការអានអាចបន្តទៀត ដោយយើងអាននៅលើកថាខណ្ឌ៦០ ។

[១៤:៥៩:០៩]

**លោកស្រី សែ កុលវុឌ្ឍី៖**

កថាខណ្ឌ៦០ អ្នកទោសទាំងឡាយដែលបញ្ជូនមកមន្ទីរ ស-២១ ត្រូវតែសម្លាប់ទាំងអស់ ។ ដូចដែលគោលនយោបាយទូទៅនៅមន្ទីរ ស-២១ គឺមិនដោះលែងអ្នកទោសណាម្នាក់ឡើយ ។

**ជនជាប់ចោទ៖**

លោកចៅក្រមជាទីគោរព! កថាខណ្ឌ៦០ នេះត្រឹមត្រូវ ។ ខ្ញុំយល់ព្រម ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដូច្នេះ យើងអាចបន្តអានទៀត ។

**លោកស្រី សែ កុលវុឌ្ឍី៖**

កថាខណ្ឌ៦១ ទោះបីមានអ្នកទោសមួយចំនួនត្រូវបានគេចាប់និងនាំខ្លួនមកមន្ទីរស-២១ ដោយភ័ន្តច្រឡំក៏ដោយ ក៏ត្រូវបានគេសម្លាប់ចោលដែរ ដើម្បីរក្សាការសម្ងាត់និងសន្តិសុខ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

គឺខ្ញុំសូមឲ្យក្រឡាបញ្ជីអានយោបល់បន្ថែមនៅឃ្លាបន្ទាប់នោះដើម្បីឲ្យជនជាប់ចោទមានការយល់

ទៅលើចំណុចនេះឲ្យច្បាស់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

នៅទីនេះសូមបន្ថែមឃ្លាមួយចំនួននេះ ដកស្រង់ពីកថាខណ្ឌទី៣១ នៃដីកាដំណោះស្រាយ ។ ទោះបីជាមានសាក្សីម្នាក់ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីពីររូប បានអះអាងថា ពួកគេអាចចាកចេញពីមន្ទីរស-២១ បានក៏ដោយ ក៏ភស្តុតាងក្នុងចំនួនភាគច្រើនលើសលប់នូវតែបង្ហាញថា គោលនយោបាយមន្ទីរស-២១ គឺមិនទុកជីវិតឲ្យអ្នកទោសណាម្នាក់ឡើយ ។ សក្ខីកម្មដែលថាអ្នកទោសបានត្រូវគេដឹកមកកាន់មន្ទីរស-២១ ដោយអចេតនា ក៏ត្រូវបានខ្មែរក្រហមប្រហារជីវិតចោលដែរ--

**អ្នកបកប្រែ៖**

*លោកប្រធាន អ្នកបកប្រែបកមិនទាន់ទេ សូមឲ្យក្រឡាបញ្ជីសូមអានឃ្លាចុងក្រោយបន្តិចទាន ។*

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

អរគុណលោកប្រធាន ។ ខ្ញុំគិតថាជិតដល់ម៉ោងសម្រាកហើយ សហព្រះរាជអាជ្ញាបានលើកឡើង គឺកថាខណ្ឌនិងយោបល់ដែលទើបតែបានអាននេះ គឺវែង ។ នៅក្នុងកថាខណ្ឌទី៦០ នៃអង្គហេតុដែលបានព្រមព្រៀងគ្នា ក៏មានទៅលើយោបល់របស់ជនជាប់ចោទផងដែរ ។ ប៉ុន្តែ យើងអត់ឮទៅយោបល់នោះទេ ហើយជាការពិតយើងអាចត្រឡប់ទៅកថាខណ្ឌ៦០ ដើម្បីឲ្យយើងពិនិត្យមើលទៅលើយោបល់ផ្សេងៗរបស់ជនជាប់ចោទ ដែលបានសរសេរនៅក្នុងនោះផងដែរ ។

[១៤:០២:៣៥]

**ប្រធានអង្គជំនុំ៖**

ដោយឥឡូវ ដោយបរិយាកាសក៏ដូចជាតឹងតែងហើយដែរ ។ អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំនាទីហើយចាំចូលមកវិញ សឹមបន្តទៀត ហើយបន្តនូវចំណុចដែលមិនទាន់ច្បាស់នេះ ដើម្បីឲ្យច្បាស់នឹងមានការបញ្ជាក់ពីជនជាប់ចោទឲ្យបានច្បាស់នូវចំណុចនេះផង ។ ម៉ោងបីដប់ប្រាំនាទី អញ្ជើញចូលវិញ ។

*[សវនាការសម្រាកពីម៉ោង ១៤:០៣ នាទីដល់ម៉ោង ១៥:២៧ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការពិភាក្សាដេញដោលតទៅទៀត ។

ជាបន្តលោកស្រី សែ កុលវុឌ្ឍី ឡើងអានម្តងទៀតនូវកថាខណ្ឌទី៦០ ដោយអានទាំងស្រុងតែម្តង ។

**លោកស្រី សែ កុលវុឌ្ឍី៖**

កថាខណ្ឌទី ៦០ --

**ប្រធានអង្គជំនុំ៖**

ឈប់ៗ ! អញ្ជើញមានការអីហ្នឹង?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំជឿថា សហព្រះរាជអាជ្ញា មានឯកសារជាអេឡិចត្រូនិកនៅក្នុងកុំព្យូទ័រ ។ ដូច្នេះ វាប្រហែលជាអាចឲ្យយើង អាចឲ្យសហព្រះរាជអាជ្ញាស្នើសុំឲ្យបញ្ចូលឯកសារជាអេឡិចត្រូនិក ដាក់ចូលនៅក្នុងកុំព្យូទ័រ ហើយវានឹងជួយសម្រួលដល់ការអាន ហើយវាផ្តល់ភាពងាយស្រួលទៅដល់ជនជាប់ចោទ និងភាគីដទៃៗទៀតផងដែរ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

អរគុណលោកចៅក្រម ។ យើងប្រាកដណាស់មានឯកសារជាអេឡិចត្រូនិក ដូច្នេះហើយខ្ញុំសូមអនុញ្ញាតឲ្យលោកប្រធាន ឲ្យធ្វើការ សុំលោកប្រធាន សូមការអនុញ្ញាតពីលោកប្រធានឲ្យធ្វើការប្តូរចរន្តកុំព្យូទ័ររបស់សហព្រះរាជអាជ្ញាវិញ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងរូបភាពសូមបង្វែរភ្ជាប់មកកុំព្យូទ័រខាងសហព្រះរាជអាជ្ញា ដើម្បីសហព្រះរាជអាជ្ញាអាចមានលទ្ធភាពក្នុងការដាក់បញ្ចាំងនូវឯកសារដែលមានការព្រមព្រៀងនេះ តាមទៅកញ្ចក់អេក្រង់ទូរទស្សន៍។

អញ្ជើញលោកស្រី សែ កុលវុឌ្ឍី អាននូវកថាខណ្ឌទី៦០ សារជាថ្មីម្តងទៀតដោយអានទាំងស្រុងតែម្តង ។

**លោកស្រី សែ កុលវុឌ្ឍី៖**

កថាខណ្ឌទី៦០ អ្នកទោសទាំងឡាយដែលបញ្ជូនមកមន្ទីរស-២១ ត្រូវតែសម្លាប់ទាំងអស់ ។

ដូចដែលគោលនយោបាយទូទៅ នៅមន្ទីរ ស-២១ គឺមិនដោះលែងអ្នកទោសណាម្នាក់ឡើយ ។ នៅទីនេះ សូមបន្ថែមឃ្លាមួយចំនួននេះ ដកស្រង់ពីកថាខណ្ឌទី៣១ នៃដីកាដំណោះស្រាយ ។ ទោះបីជាមានសាក្សីម្នាក់ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីពីររូប បានអះអាងថា ពួកគេអាចចាកចេញពីមន្ទីរស-២១ បានក៏ដោយ ក៏ភស្តុតាងចំនួនភាគច្រើនលើសលប់នៅតែបង្ហាញថា គោលនយោបាយមន្ទីរស-២១ គឺមិនទុកជីវិតឲ្យអ្នកទោសណាម្នាក់ឡើយ ។

សក្ខីកម្មដែលថា អ្នកទោសបានត្រូវគេដឹកមកកាន់មន្ទីរស-២១ ដោយអចេតនាក៏ត្រូវបានខ្មែរក្រហមប្រហារជីវិតចោលដែរ ។ ដើម្បីធានាភាពសម្ងាត់និងសន្តិសុខនោះ ពិតជាបានបញ្ជាក់ចំណុចនេះច្បាស់ណាស់ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ថាតើជនជាប់ចោទបញ្ជាក់ ថាវាត្រឹមត្រូវដែរឬទេចំពោះអ្វីដែលបានអាន? ឬក៏ជនជាប់ចោទ មានយោបល់ណាផ្សេងចង់លើកឡើងចំពោះអង្គហេតុនេះ?

**ឆ៖** លោកចៅក្រមជាទីគោរព! កថាខណ្ឌ៦០ ដែលខ្ញុំសរសេរថា យល់ព្រមនេះ ខ្ញុំអត់កែប្រែទេ ។ គោលការណ៍គ្មានឲ្យដោះលែងអ្នកណាម្នាក់ទេ ចំណែកសាក្សីម្នាក់ បើតាមនេះខ្ញុំសូមជូនជាការសង្កេត ដល់លោកចៅក្រម ហើយរឿងលម្អិត យើងនឹងពិភាក្សាគ្នានៅវបៀបវារៈលើកក្រោយទៀត ។

សាក្សីម្នាក់នេះ CP សាក្សីម្នាក់នេះមានទិដ្ឋភាពដូចសាក្សី KW31 របស់ខ្ញុំពីមុនអ៊ីចឹង មិនៗមែនជាសាក្សីពិតប្រាកដទេ ។ ឯចំណែកដើមបណ្តឹងរដ្ឋប្បវេណី នឹងចាំដល់ជជែកគ្នាទៅក្រោយទៀត ។ ឯចំណែកឃ្លាមួយកំណាត់ចុងក្រោយ ខ្ញុំមានការឆ្ងល់ដែរ សក្ខីកម្មដែលថា អ្នកទោសត្រូវគេដឹកមកកាន់មន្ទីរស-២១ ដោយអចេតនា ក៏ត្រូវបានខ្មែរក្រហមប្រហារជីវិតចោលដែរ ដើម្បីធានាការសម្ងាត់ និងសន្តិសុខនោះពិតជាបានបញ្ជាក់ចំណុចនេះច្បាស់លាស់ណាស់ ។ សូមអានខាងក្រោម យល់ព្រម ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតឲ្យអានមើលខាងក្រោមទៀត មុននឹងធ្វើអត្ថាធិប្បាយ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថា យើងអាចបន្តអានកថាខណ្ឌបន្ទាប់ទៀត ។

[១៥:៣៤:៣៩]

**លោកស្រី សែ កុលវុឌ្ឍី៖**

កថាខណ្ឌទី៦១ ទោះបីមានអ្នកទោសមួយចំនួនត្រូវបានគេចាប់ និងនាំខ្លួនមកមន្ទីរស-២១ ដោយ

ភ័ន្តច្រឡំក៏ដោយ ក៏ត្រូវបានគេសម្លាប់ចោលដែរ ដើម្បីរក្សាការសម្ងាត់ និងសន្តិសុខ ។ បើតាម ឌុច គោលការណ៍ដែលរៀបរាប់នៅក្នុងកថាខណ្ឌនេះ ជាគោលការណ៍ពិតប្រាកដ គឺទោះបីជាមនុស្សម្នាក់ត្រូវបានចាប់ខ្លួនដោយភ័ន្តច្រឡំក៏ដោយ ក៏ត្រូវតែសម្លាប់ចោលដែរ ដើម្បីរក្សាការសម្ងាត់ និងសន្តិសុខ ។ ក៏ប៉ុន្តែតាមការជម្រាបរបស់គាត់ មានតែមនុស្សម្នាក់ប៉ុណ្ណោះ ដែលត្រូវបានចាប់ខ្លួនដោយភ័ន្តច្រឡំ ។ មិត្តលីន បានសង្កេតឃើញមនុស្សម្នាក់នេះ ហើយថ្នាក់លើបានអនុញ្ញាតឲ្យដោះលែងម្នាក់នេះ ។ អំពីរឿងនេះ សូមអាន D16/6 និង D16/5 ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ថាតើជនជាប់ចោទមានយោបល់បញ្ជាក់នៅលើហ្នឹងដែរឬទេ? ហើយលោកយល់ព្រមទៅលើអង្គហេតុនេះដែរឬទេ? ខ្ញុំគិតថាលោកបានរៀបរាប់អំពីរឿងរ៉ាវនៅព្រឹកនេះហើយ ។ ដូច្នេះ បើសិនជាលោកយល់ព្រមគឺវាជាការស្រេចទៅលើករណីនេះ ។

**ឆ៖** លោកចៅក្រមជាទីគោរព! អាកថាខណ្ឌ៦១ វាពិតជាតំណ ពីកថាខណ្ឌ៦០ សរុបទាំងអស់ទៅ វាទៅជាអង្គភាពមួយដែលយើងខ្ញុំយល់ស្រប ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះយើងអាចបន្តអានកថាខណ្ឌបន្ទាប់ទៀត ។

**លោកស្រី សែ កុលវុឌ្ឍី៖**

កថាខណ្ឌទី៦២ បក្សកុម្មុយនីស្តកម្ពុជាបានគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ ជាចម្បងតាមរយៈអង្គការរដ្ឋកម្ពុជាប្រជាធិបតេយ្យ អង្គការរដ្ឋបាលរបស់បក្ស និងកងទ័ពបដិវត្តន៍កម្ពុជា ។

**ជនជាប់ចោទ៖**

លោកចៅក្រមជាទីគោរព! កថាខណ្ឌនេះខ្ញុំបាទយល់ស្រប ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

កថាខណ្ឌបន្ទាប់ទៀត ។

[១៥:៣៧:៣១]

**លោកស្រី សែ កុលវុឌ្ឍី៖**

កថាខណ្ឌ៦៣ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦ និងលក្ខន្តិកៈបក្សបានផ្តល់អំណាចយ៉ាងធំទៅឲ្យគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដោយរួមមាន លទ្ធភាពក្នុងការកំណត់

គោលនយោបាយបក្ស និងសិទ្ធិអំណាចបញ្ជាទៅថ្នាក់ភូមិភាគ និងតំបន់ ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកចៅក្រមជាទីគោរព! កថាខណ្ឌ៦៣ នេះខ្ញុំបាទយល់ស្រប ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ពីការជំហររបស់យើងដែលបានយល់ ថាតើគណៈអចិន្ត្រៃយ៍ គឺជាគណៈកម្មាធិការមួយដែលសំខាន់បំផុត ឬក៏មានគណៈកម្មាធិការណាមួយទៀតដែលសំខាន់?

**ឆ៖** សូមគោរពលោកចៅក្រមជាទីគោរព! អចិន្ត្រៃយ៍មជ្ឈិមបក្ស ទូលាយបន្តិច ។ អ្នកដែលមានអំណាចពិតប្រាកដ សូមទោស គណៈកម្មាធិការមជ្ឈិមបក្សទូលាយបន្តិច ។ ឯចំណែកគណៈកម្មាធិការ តូចមួយទៀតនៅក្នុងនុង់ ដែលមានអំណាចពិតប្រាកដ គឺអចិន្ត្រៃយ៍មជ្ឈិមបក្ស ។ មួយ គឺអចិន្ត្រៃយ៍ដែលមានអំណាច ឯចំណែកមួយទៀតមានអំណាចដែរ ក៏ប៉ុន្តែអំណាចក្នុងការអនុវត្តតាមសេចក្តីសម្រេចរបស់អចិន្ត្រៃយ៍ ។ អចិន្ត្រៃយ៍គេអ្នកសម្រេច ខាងមជ្ឈិមជាអ្នកអនុវត្ត។ នេះសូមបញ្ជាក់ប៉ុណ្ណឹង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមបន្តអានកថាខណ្ឌបន្តទៀត ។

**លោកស្រី សែ កុលវុឌ្ឍី៖**

កថាខណ្ឌទី៦៤ ក្នុងការអនុវត្តជាក់ស្តែង គឺអនុគណៈកម្មាធិការនៃគណៈកម្មាធិការកណ្តាល ឬហៅថា គណៈកម្មាធិការអចិន្ត្រៃយ៍ជាអ្នកដើរតួនាទីជា អង្គភាពប្រកបដោយសិទ្ធិអំណាចធំបំផុត និងខ្ពស់បំផុតរបស់រដ្ឋ ។

[១៥:៤០:០០]

**ជនជាប់ចោទ៖**

លោកចៅក្រមជាទីគោរព! ខ្ញុំសូមឯកភាព ខ្ញុំបានជម្រាបលោកអម្បាញ់មិញ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអានកថាខណ្ឌបន្តទៀត ។

**លោកស្រី សែ កុលវុឌ្ឍី៖**

កថាខណ្ឌទី៦៥ សេចក្តីសម្រេចមួយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ ១៩៧៥ បានតែងតាំង ប៉ុល ពត ជាមេបញ្ជាការជាន់ខ្ពស់កងទ័ព និង សុន សេន ជានាយសេនាធិការ និងខាងផ្នែកសន្តិសុខ ។

**ជនជាប់ចោទ៖**

សូមជម្រាបប្រសាសន៍លោកចៅក្រម! ក្នុងកថាខណ្ឌទី៦៥នេះ ខ្ញុំបាទបានសរសេរថា យល់ព្រម ក៏ប៉ុន្តែនៅពេលនោះ ខ្ញុំបាទ មិនទាន់មានឯកសារថ្ងៃ៩ តុលា ឆ្នាំ១៩៧៥ ទេ ។ ឥឡូវដល់មានឯកសារនេះ ខ្ញុំសូមអនុញ្ញាតអានជូនអង្គប្រជុំដូចតទៅ ៖

១) សមមិត្តលេខា សំដៅ ប៉ុល ពត សមមិត្តលេខា ។

ចំណុច២ ទទួលរួមយោធា និងសេដ្ឋកិច្ច ។ នៅក្នុងឯកសារការប្រជុំអចិន្ត្រៃយ៍មជ្ឈិមថ្ងៃ៩ ខែ១០ ឆ្នាំ១៩៧៥ ERN00019108 នៅក្នុងបន្ទាត់ទីមួយ ។ នៅក្នុងបន្ទាត់ទីដប់ មានសរសេរថា៖

១) សមមិត្តលេខា ទទួលរួមយោធា និងសេដ្ឋកិច្ច ។ ដូច្នេះវាច្បាស់ជាងនេះបន្តិច ពីព្រោះ ប៉ុល ពត ស្អីក៏នៅលើគាត់សម្រេចដែរ ។ នេះសូមបញ្ជាក់ជូនលោកចៅក្រមប៉ុណ្ណេះ ដោយគោរព ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ថាតើលោកអាចផ្តល់លេខយោងឲ្យបានច្បាស់លាស់ចំពោះឯកសារនេះបានដែរឬទេ?

**ឆ៖** លោកចៅក្រមជាទីគោរព ឯកសារនេះចំណងជើងដាក់ថា "ការប្រជុំអចិន្ត្រៃយ៍ ថ្ងៃ៩ ខែ តុលា ឆ្នាំ១៩៧៥" លេខជាភាសាខ្មែរ 00019108 ដល់ 00019126 ។ ជាភាសាអង់គ្លេស 00183393 ដល់ 00183408 ។ ឯកសារជាភាសាបារាំង 00292668 ដល់ 00292886 ។ ឃ្លាដែលខ្ញុំបានអានអំមិញ នៅក្នុងទំព័រ00019108ជាភាសាខ្មែរ នៅបន្ទាត់ទីដប់ ។ "សមមិត្តលេខាទទួលរួម

(ដកឃ្លា) យោធា និងសេដ្ឋកិច្ច" ។

ដូច្នេះ បើកាលណាសរសេរបីតួនាទីរបស់គាត់បានៗវាគ្រប់តួនាទីរបស់ ប៉ុល ពត ក្នុងការដឹកនាំ អចិន្ត្រៃយ៍ ។

[១៥:៤៤:៣៥]

**ប្រធានអង្គជំនុំ៖**

មានបញ្ហាអីទៅលោកមេធាវី?

**លោក អាឡាំង វ៉ែនណឺ៖**

លោកចៅក្រម ថាតើយើងខ្ញុំអាចសុំលេខ ERN ជាភាសាអង់គ្លេងម្តងទៀតទេ ដោយសារតែយើងចាប់អត់ទាន់ ។ ដូច្នេះសូមអនុញ្ញាតលោកប្រធានធ្វើការបញ្ជាក់ ឲ្យបញ្ជាក់លេខ ERN ជាភាសាអង់គ្លេសឡើងវិញ ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទអាចបញ្ជាក់លេខ ERN ឯកសារអំមិញនេះជាភាសាអង់គ្លេសម្តងទៀតបានដែរឬទេ? សូមប្រាប់ម្តងទៀតណ៎ា ។

**ជនជាប់ចោទ៖**

សូមអរគុណ លោកប្រធាន សូមទទួលបញ្ជា ។ ជាភាសាអង់គ្លេស ERN00183393 ដល់ 00183408 ។ សូមអស់ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ បេ៊ត៖**

អរគុណ សូមអភ័យទោសដែលខ្ញុំកាត់ពាក្យទៀតហើយ ។ វាហាក់ដូចជាមានបញ្ហាក្នុងការអានទៅលើយោបល់ដែលមាននៅក្នុងកថាខណ្ឌនោះ ។ ឯកសារនៅក្នុងកុំព្យូទ័ររបស់យើង គឺឯកសារនៅក្នុងសំណុំរឿង ដែលត្រូវបានថតចម្លង ហើយឯកសារថតចម្លងនោះ គឺវាមានលក្ខណៈព្រឹលៗ ។ ហើយដោយសារតែនៅក្នុង*អេក្រង់*របស់យើង គឺវាមានពណ៌បៃតងខ្ចី ។ ដូច្នេះហើយគឺវាអត់ឃើញច្បាស់នោះទេ ។ ដូច្នេះគឺខ្ញុំនឹងធ្វើការ*ព្រីន* ឬក៏ថតឯកសារនេះជាឯកសារមួយទៀតដែលមានលក្ខណៈដាក់ជាអក្សរខ្មៅឲ្យបានច្បាស់ ដើម្បីឲ្យក្រឡាបញ្ជីអានឲ្យបានច្បាស់លាស់ទៅលើចំណុចនេះ ។

[១៥:៤៧:១០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ឌុច តើលោកគិតថា យើងគួរតែបន្តទៀតក្នុងខណៈពេលដែលឯកសារនេះកំពុងតែរៀបចំ ឬក៏យើងបន្តទៅមុខយ៉ាងម៉េច?

ដូច្នេះនៅពេលនេះ ខ្ញុំសូមឲ្យក្រឡាបញ្ជីធ្វើការបន្តអានទៀត ។ យើងចូលទៅលើកថាខណ្ឌលេខ ៦៦ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

កថាខណ្ឌទី៦៦ មន្ទីរស-២១ ជាផ្នែកមួយ-- ជាផ្នែកសំខាន់មួយនៃរចនាសម្ព័ន្ធនយោបាយយោធារបស់បក្សកុម្មុយនីស្តកម្ពុជា នៅថ្នាក់មជ្ឈិមដែល ឌុច បានហៅថា “អង្គការមជ្ឈិមបក្ស គណៈកម្មាធិការមជ្ឈិម ឬគណៈកម្មាធិការអចិន្ត្រៃយ៍” ។ បើតាម ឌុច ជាការត្រឹមត្រូវជាងដែលត្រូវនិយាយថា ស-២១ ស្ថិតនៅក្រោមការចាត់តាំង ចាត់ការរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមជាជាងស-២១ ស្ថិតនៅថ្នាក់មជ្ឈិម ។ ពិតមែនហើយប្រសិនបើ ឌុច ផ្ទាល់ខ្លួនជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិម អាចសរសេរថា ស-២១ ស្ថិតនៅថ្នាក់មជ្ឈិម ប៉ុន្តែគាត់មិនមែនជាសមាជិកមជ្ឈិមទេ ។

[១៥:៤៨:៥២]

**ជនជាប់ចោទ៖**

លោកចៅក្រមជាទីគោរព១! ខ្ញុំសូមបន្ថែមជូនជាការពិនិត្យបញ្ជាក់លើ អំណះអំណាងរបស់ខ្ញុំក្រោមកថាខណ្ឌ៦៦នេះ ។ ដោយអានជូនមាត្រា៨ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ។ សូមអានជូនមាត្រា៨ នៃលក្ខន្តិកបក្សកុម្មុយនីស្តកម្ពុជា ។ ច្បាប់ជាភាសាខ្មែរទំព័រ៣៤ “ចំពោះតំបន់ណា ឬអង្គការណាដែលមានលក្ខណៈពិសេសខាងនយោបាយក្តី ខាងយោធាក្តី ខាងសេដ្ឋកិច្ចក្តី ខាងវប្បធម៌ក្តី ខាងវប្បធម៌សង្គមកិច្ចក្តី អាចចាត់តាំងជាផ្នែកដោយឡែក ដោយគណៈកម្មាធិការមជ្ឈិមទទួលភារៈដឹកនាំដោយផ្ទាល់ ឬដោយប្រយោលតាមខ្សែចាត់តាំងជាក់ស្តែង” ។ នេះវាបញ្ជាក់គោលការណ៍ដែលគេបង្កបង្កើតស-២១ ទុកប្រើក្បែរខ្លួនគេ មិនមែនស-២១ ជាផ្នែកមួយនៃរចនាសម្ព័ន្ធនយោបាយយោធារបស់បក្សកុម្មុយនីស្តកម្ពុជានៅថ្នាក់មជ្ឈិមទេ ។

ពាក្យមន្ទីរ “ស-២១” ជាផ្នែកសំខាន់មួយនៃរចនាសម្ព័ន្ធនយោបាយយោធារបស់បក្សកុម្មុយនីស្តកម្ពុជានៅថ្នាក់មជ្ឈិមមិនត្រូវទេ ទាល់តែយើងនិយាយដូចខ្ញុំបានអះអាងរួចមកហើយ ដោយសំអាងលើមាត្រា៨ ជាភស្តុតាងស្រាប់ ។ មាត្រា៨នេះ សូមអានជូនម្តងទៀត “ចំពោះតំបន់ណា ឬអង្គការណាដែលមានលក្ខណៈពិសេស ខាងនយោបាយក្តី ខាងយោធាក្តី ខាងសេដ្ឋកិច្ចក្តី ខាងវប្បធម៌សង្គមកិច្ចក្តី អាចចាត់តាំងជាផ្នែកដោយឡែក ដោយគណៈកម្មាធិការមជ្ឈិមទទួលភារៈដឹកនាំដោយផ្ទាល់ ឬដោយប្រយោលតាមខ្សែចាត់តាំងជាក់ស្តែង” ។ ដូច្នេះអា ស-២១ នេះ វាមិនមែនជាមជ្ឈិមទេ ។ សូមបញ្ជាក់ប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ខាតវ៉ាយថ៍ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អរគុណលោកចៅក្រម ។ ខ្ញុំហាក់ដូចជាពិបាកក្នុងការតាមការបកប្រែជាភាសាអង់គ្លេស ហើយខ្ញុំមិនដឹងថា តើការបកប្រែបារាំងយ៉ាងណានោះទេ ។ ដូច្នេះហើយ គឺខ្ញុំអត់ដឹងថា បារាំងបកល្អជាងឬក៏យ៉ាងម៉េច? ខ្ញុំសូមអនុញ្ញាតឱ្យជនជាប់ចោទនិយាយឡើងវិញនូវអ្វីដែលគាត់បានលើកឡើង ដើម្បីឱ្យយើងបានយល់ឱ្យល្អ ហើយនៅក្នុងភាសាអង់គ្លេសគឺយើង ដើម្បីឱ្យយើងបានយល់ឱ្យបានល្អជាងនេះក៏ដូចជាភាសាបារាំងផងដែរ ។

**ជនជាប់ចោទ៖**

សូមអរគុណលោកជំទាវ ខាត់វ៉ាយថ៍ ដែលបានសូមឱ្យខ្ញុំបញ្ជាក់ ។ កថាខណ្ឌ៦៦ នេះខ្ញុំបាទបានសរសេរថា យល់ព្រមមួយផ្នែក ។ បានន័យថា មួយផ្នែកទៀត ខ្ញុំអត់យលព្រមទេ ។ យល់ព្រមមួយផ្នែកថា ស-២១ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈិម ។ ត្រង់ឱ្យនិយាយថា នៅថ្នាក់មជ្ឈិមមិនត្រូវទេ ។ នៅថ្នាក់មជ្ឈិមទាល់តែរូបខ្ញុំបាទផ្ទាល់ជាសមាជិកមជ្ឈិមពេញសិទ្ធិ ។

ដូច្នេះ ការដែលខ្ញុំបាទបានអធិប្បាយបដិសេធហើយនៅក្នុងកថា-- ពីក្រោមកថាខណ្ឌនេះ យើងខ្ញុំរក្សាដដែល គ្រាន់តែពេលនេះលើកយកមាត្រា៨ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ១៩៧៦ យកមកអះអាងថែម ។ ដូចដែលខ្ញុំបានអានអម្បាញ់មិញនេះ ។ ខ្ញុំជឿងថា ខ្ញុំមិនបាច់អានជូនលោកជំទាវទៀតទេ ។ សូមទោស ឬយ៉ាងម៉េច?

សូមអរគុណ សូមចប់ ។

[១៥:៥៣:៤៩]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

គឺខ្ញុំចង់ឱ្យលោកលើកយោបល់របស់លោក ដែលលោកបាននិយាយទាក់ទងទៅនឹងមាត្រាទី៨ នៃលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាឆ្នាំ៧៦ គឺទាក់ទងទៅនឹងស-២១ ទាក់ទងទៅនឹងការរៀបចំស-២១ ។ លោកនិយាយថា វាមិនមែនជាផ្នែកនៃរចនាសម្ព័ន្ធរបស់គណៈអចិន្ត្រៃយ៍នោះទេ គឺយើងសូមឱ្យលោកមើលទៅលើមាត្រា-- បើសិនជាយើងមើលមាត្រាទី៨ គឺមានការលើកឡើងថា មានការរៀបចំដោយគណៈអចិន្ត្រៃយ៍ ។ តើខ្ញុំយល់នូវអ្វីដែលលោកបានផ្តល់យោបល់នេះ ត្រឹមត្រូវដែរឬទេ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកជំទាវ ស-២១ រៀបចំដោយអចិន្ត្រៃយ៍តាមគោលការណ៍មាត្រា៨ ។ តាមគោលការណ៍មាត្រា៨ អចិន្ត្រៃយ៍មករៀបចំ ស-២១ ជាសកម្មភាពជាក់ស្តែង ការចុះមកចាត់តាំង ស-២១ នៅថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៥ ជាភស្តុតាងស្រាប់ ។ ក៏ប៉ុន្តែ ស-២១ វាមិនមែនជាអង្គការយោធានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា នៅថ្នាក់មជ្ឈិម មិនមានន័យថា នៅថ្នាក់មជ្ឈិម ។ អង្គការនយោបាយយោធានៅថ្នាក់មជ្ឈិម ខ្ញុំសូមជម្រាបជូនលោកជំទាវគឺ ក្រសួងការពារប្រទេស-- (សូមទោស) ហ្នឹងហើយក្រសួងការបរទេស និងអគ្គសេនាធិការក្រសួងការបរទេស វាជាអង្គការនយោបាយ ។ ឯចំណែកអង្គការយោធាវាគឺ គឺអគ្គសេនាធិការ អាហ្នឹងនៅថ្នាក់មជ្ឈិម អ្នកដឹកនាំក្រសួងនេះគេជាសមាជិកអចិន្ត្រៃយ៍ ។ ឯចំណែកខ្ញុំបាទមិនមែនជាអង្គការនយោបាយយោធារបស់បក្សកុម្មុយនីស្តកម្ពុជានៅថ្នាក់មជ្ឈិមទេ គឺជាគណៈកម្មាធិការសាខាដែលមជ្ឈិមបញ្ជាដោយផ្ទាល់នេះ ។ លោកជំទាវមើល! ដោយគណៈកម្មាធិការមជ្ឈិមទទួលភារៈដឹកនាំដោយផ្ទាល់ ។ គឺមជ្ឈិមទទួលភារៈដឹកនាំ ស-២១ នេះដោយផ្ទាល់ គឺ សុន សេន គាត់អញ្ជើញចុះមកផ្ទាល់ នេះវាខុសគ្នាត្រង់ហ្នឹង ។ មួយ សុន សេន គាត់ជាប្រធានមួយខ្ញុំ ស-២១ សុន សេន គាត់មកដឹកនាំបញ្ជាដោយផ្ទាល់ នេះវាខុសគ្នាប៉ុណ្ណោះ ។ សូមជម្រាបបញ្ជាក់ខាងចាត់តាំង គឺវាខុសគ្នាស្រឡះដូចមេឃនិងដី ។

សូមគោរពរាយការណ៍ជូនបញ្ជាក់ លោកជំទាវប៉ុណ្ណោះ ដោយគោរព ។

[១៥:៥៧:១២]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ទាក់ទងទៅនឹងចំណុចនេះ តើលោកអាចប្រាប់យើងបានដែរឬទេ ប្រសិនបើលោកដឹង? ថាតើវាមានទំនាក់ទំនងពិសេសទាក់ទងទៅនឹងគណៈមជ្ឈិម ជាមួយនឹងមន្ទីរសន្តិសុខផ្សេងៗ ឬមួយក៏យ៉ាងម៉េច ឬក៏ការទំនាក់ទំនងនេះ គឺវាមានលក្ខណៈពិសេសចំពោះស-២១?

**ឆ៖** លោកចៅក្រមជាទីគោរព! ស-២១ៗ ធ្វើការក្រោមបញ្ជាលោកគ្រូ សុន សេន បុគ្គលទីប្រាំពីររបស់បក្ស ។ ចំណែក នគរបាលទាំងអស់នៅភូមិភាគនិរតីរបស់ តាម៉ុក ស្ថិតនៅក្រោមបញ្ជារបស់តាម៉ុក គឺស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់ តាម៉ុក ។ ហើយសូមបញ្ជាក់ជូនលោកប្រធានថា តាម៉ុកជាបុគ្គលទីបួនរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឯចំណែក នគរបាលភូមិភាគបូព៌ាស្ថិតនៅក្រោមបញ្ជារបស់បង ភឹម, សោ ភឹម ហៅ សោ យ៉ាន់ នោះ ។ ដូច្នេះ សោ យ៉ាន់ គាត់ជាបុគ្គលទីបី របស់បក្ស

កុម្មុយនីស្តកម្ពុជា ។

[១៥:៥៩:១៧]

ចំណែកឯនគរបាលភូមិភាគផ្សេងទៀត ឧទាហរណ៍ នគរបាលភូមិភាគបស្ចឹមស្ថិតនៅក្រោមការគ្រប់គ្រងរបស់បង ស៊ី, ជូ ជេត ឈ្មោះដើម ជូ ជេត ។ ជូ ជេត គាត់ជាសមាជិកមជ្ឈិមពេញសិទ្ធិ ។ ឯចំណែកនគរបាលភូមិភាគពាយ័ព្យ នគរបាលភូមិភាគកណ្តាល នគរបាលភូមិភាគឦសាន នគរបាលភូមិភាគពាយព្យ សុទ្ធតែនៅក្រោមការគ្រប់គ្រងផ្ទាល់របស់លេខាភូមិភាគ ។

ដោយឡែក នគរបាលនៅហ្នឹងតំបន់ពិសេស ដូចយ៉ាងតំបន់កំពង់សោមស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ ប៉ុល ពត ។ ដូច្នេះ ទាំងអស់ នគរបាលទាំងអស់នេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកប្អូនក្រុមនុំង ។ ដូច្នេះ នគរបាល ស-២១ វាអត់អីពិសេសជាងគេ វាអត់ដើរតួជាកំពូលអីគេទេ ។

**ស៖** អ្វីដែលលោកលើកឡើងនៅទីនេះ មន្ទីរសន្តិសុខនីមួយៗ គឺត្រូវបានគ្រប់គ្រង ឬក៏ទទួលបង្គាប់បញ្ជាដោយសមាជិកមកពីគណៈអចិន្ត្រៃយ៍ ។ អ្វីដែលខ្ញុំចង់ដឹងនោះ គឺថាតើវាមានឋានានុក្រមនៅក្នុងចំណោមមន្ទីរសន្តិសុខទាំងអស់នោះដែរឬទេ? ហើយថាតើស-២១ មានតួនាទីជាក់លាក់ណាមួយនៅក្នុងរចនាសម្ព័ន្ធនៃមន្ទីរសន្តិសុខទាំងអស់នេះដែរឬទេ?

[១៦:០២:០១]

**ឆ៖** លោកចៅក្រមទីគោរព! សូមអរគុណលោកដែលបានលើកសំណួរនេះ។ ខ្ញុំមានប្រាថ្នាចង់ខ្ញុំមានប្រាថ្នានឹងបញ្ជាក់ជូនតុលាការយូរហើយ គ្មាន-- ខ្ញុំសូមបញ្ជាក់ថា មន្ទីរនគរបាលភូមិភាគនីមួយៗចំណុះឲ្យលេខាភូមិភាគ ។ លេខាភូមិភាគ ហើយមន្ទីរនគរបាលភូមិភាគនីមួយៗទាក់ទងគ្នាមិនបានទេផ្ទាល់មិនបានទេ ។ ស-២១ គ្មានសិទ្ធិទាក់ទងនឹងមន្ទីរនគរបាលភូមិភាគបូព៌ាទេ ដោយផ្ទាល់ទេ ។

ឯកសារដែលខ្ញុំបាទបានលើកបង្ហាញពីថ្ងៃមុន ជាភស្តុតាងស្រាប់ ។ ដំបូង ខ្ញុំសរសេរស៊ីញ៉េឯកសារនេះទៅជូនខាងលើ ជូនមេខ្ញុំ ។ ឯកសារនេះជាចម្លើយសារភាពរបស់ ឡុង មុយ ហៅ ជួន ដល់មេខ្ញុំអានហើយ សរសេរជូនទៅ ប៉ុល ពត ឲ្យគាត់សម្រេច ដល់ ប៉ុល ពត សម្រេចហើយបាន សុន សេន គាត់យកទៅចាត់ចែងឲ្យទៅបូព៌ា ។ ផ្ញើឯកសារហ្នឹងទៅបូព៌ា នេះឯកសារនោះ ខ្ញុំបានអនុញ្ញាតសុំលោកប្រធានបញ្ជាំងតាមអេក្រង់នេះ ។ នេះវាជាហេតុផលមួយបញ្ជាក់ថា ខ្ញុំ ស-២១ គ្មានសិទ្ធិទាក់ទងនឹងនគរបាលភូមិភាគបូព៌ាទេ ឯករាជ្យរៀងខ្លួន ដាច់ដោយឡែករៀងខ្លួន ។ ខ្ញុំក្រោមការគ្រប់គ្រងរបស់ សុន សេន គេក្រោមការគ្រប់គ្រងរបស់ សោ ភឹម ដាច់ដោយឡែកគ្នាស្រឡះ ។ កំពូលជួបគ្នា

គឺ ប៉ុល ពត តាមខ្សែរយៈបក្សពីក្រោមឡើងលើ ពីលើចុះក្រោម ។

[១៦:០៦:០៥]

ដោយហេតុនេះហើយបានជាខ្ញុំសូមបញ្ជាក់ថា ស-២១ មិនមែនជាអង្គការនយោបាយយោធាថ្នាក់មជ្ឈិមទេ ។ ជាអង្គការសន្តិបាលស្ថិតក្រោមការគ្រប់គ្រងរបស់មជ្ឈិមដូចគេដូចឯង ។ នគរបាលភូមិភាគបូព៌ាក៏មជ្ឈិមគ្រប់គ្រង នគរបាលភូមិភាគនិរតីក៏អចិន្ត្រៃយ៍គ្រប់គ្រង ទាំងអស់ នគរបាលទាំងអស់សុទ្ធតែម្ចាស់គេគ្រប់គ្រង ភូមិភាគគេគ្រប់គ្រង ។ ដូច្នេះខ្ញុំសូមសរុបមកវិញ គឺស-២១ មិនមែនជាអង្គការនយោបាយយោធាថ្នាក់មជ្ឈិមទេ តែជាអង្គការសន្តិបាលដែលមជ្ឈិមគ្រប់គ្រង ។

**ស៖** ថាតើ ស-២១ គឺវាផ្ទុយពីមន្ទីរសន្តិបាលផ្សេងទៀត ឬក៏យ៉ាងម៉េច? ឬក៏មន្ទីរសន្តិសុខមួយនេះ គឺយកចូលតែមនុស្សដែលមកពីគណៈអចិន្ត្រៃយ៍ ឬក៏មកពីអង្គការដឹកនាំរបស់បក្ស នៅពេលដែលអ្នកទាំងអស់នោះ ត្រូវបានកម្ទេច ថាតើនេះជាលក្ខណៈពិសេសរបស់ស-២១ ទៅនឹងចំណុចនេះ ឬយ៉ាងម៉េច? ហើយថាតើមន្ទីរសន្តិសុខផ្សេងៗទៀត គឺគេទទួលអ្នកទោសមកពីតាមភូមិភាគ ក្រៅពីខ្សែក្បត់ដែរឬទេ? ថាតើ ស-២១ ទទួលអ្នកទោសមកពីគ្រប់ទីកន្លែងទាំងអស់ ឬយ៉ាងម៉េច?

[១៦:០៩:១៨]

**ឆ៖** ស-២១ វាជាឧបករណ៍របស់មជ្ឈិម របស់អចិន្ត្រៃយ៍ៗ ។ ទីពីរ វាស្ថិតនៅភ្នំពេញ ទីតាំងរបស់ស-២១ ទៅទីស្នាក់មជ្ឈិមមិនដល់ប្រាំគីឡូទេ ខ្សែទូរស័ព្ទទាក់ទងគ្នាជាប់ ។ ដោយប្រការនេះហើយដែលអចិន្ត្រៃយ៍មជ្ឈិម គេឲ្យពួកសមាជិកមជ្ឈិមដែលត្រូវចាប់ចងមកនៅស-២១ ដើម្បីគេស្រួលណែនាំគេស្រួលបញ្ជា ស្រួលចាត់ចែង តាមគោលការណ៍ដែលមានចែងនៅក្នុងមាត្រាទី៨ នៃលក្ខន្តិកៈនេះស្រាប់ ។

ទីពីរ ចំពោះមនុស្សដែលគេប្រមូលពីភូមិភាគផ្សេងៗ មិនមែនប្រធានស-២១ សម្រេចសុំប្រមូល ឬក៏មន្ទីរមានសិទ្ធិទៅទារពីមន្ទីរនគរបាលផ្សេងៗមកចូល ស-២១ អត់មានទេ ។

ដូច្នេះ មន្ទីរស-២១ វាមានអ្នកទោសមកពីភូមិភាគផ្សេងទៀតមែន ពីព្រោះអំណាចរបស់អចិន្ត្រៃយ៍ វាធំគ្របដណ្តប់ទូទាំងប្រទេស ។ ដូច្នេះ វាៗប្រមូលអ្នកទោសពីភូមិភាគផ្សេងទៀត យកមកដាក់នៅទីនេះ ដើម្បីវត្ថុបំណងមួយច្បាស់លាស់របស់គេ ។ ដូច្នេះ អាអ្នកដែលចាប់សមាជិកមជ្ឈិមក៏មិនមែនស-២១ សម្រេចចាប់ ។ ហើយទីពីរ ដែលប្រមូលមនុស្សយកមកចូលស-២១ ហ្នឹងក៏មិនមែនស-២១ សម្រេចសុំ ។

សរុបមក លក្ខណៈពិសេសរបស់ស-២១ មកអំពីអចិន្ត្រៃយ៍មជ្ឈិមបក្ស វាជាកំពូលដឹកនាំកិច្ចការឧក្រិដ្ឋកម្មទាំងមូលនៅកម្ពុជា ។ ដូច្នេះ របស់ដែលវាប្រើឲ្យ ស-២១ ធ្វើវាមានលក្ខណៈប្លែកពីមន្ទីរនគរបាលផ្សេងទៀត ពីព្រោះតួនាទីរបស់វាជាកំពូល ។

សរុបមក មន្ទីរនគរបាលផ្សេងទៀតដឹកនាំដោយគណៈកម្មាធិការសាខាដូចគ្នា ។ ខ្ញុំលេខាគណៈកម្មាធិការមួយ គេលេខាគណៈកម្មាធិការមួយ នេះដែលដូចគ្នា ។ គ្មានអ្នកណាមានសិទ្ធិបញ្ជាឆ្លងគ្នាទៅវិញ ទៅមកបានទេ កំបុត-ក ។ ដូច្នេះ គ្មាន *អ៊ីយេរ៉ាស៊ី* រវាងមន្ទីរសន្តិបាលទាំងអស់ទូទាំងប្រទេសទេគ្មាន ។ គ្មានមន្ទីរនគរបាលណាមានសិទ្ធិទៅបញ្ជា មន្ទីរនគរបាលណាផ្សេងទៀតបានទេ ។

សូមរាយការណ៍បញ្ចប់ ជាការអធិប្បាយជូនលោកចៅក្រមតែប៉ុណ្ណោះ ។ សូមគោរព ។

[១៦:១៦:២០]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

គឺយើងដឹងច្បាស់ហើយ គឺគ្មានការទំនាក់ទំនងផ្ទាល់រវាងមន្ទីរសន្តិសុខនោះទេ ។ យើងយល់ហើយថាមន្ទីរសន្តិបាលទាំងឡាយ គឺស្ថិតនៅក្រោមការគ្រប់គ្រង់របស់គណៈអចិន្ត្រៃយ៍ ហើយតាមអ្វីដែលខ្ញុំយល់ត្រឹមត្រូវនោះ គឺវាមានលក្ខណៈជាក់លាក់ទៅនឹងទីតាំង និងភូមិសាស្ត្ររវាងស-២១ ហើយនឹងគណៈអចិន្ត្រៃយ ហើយភាពនៅជិតផ្នែកទីតាំងភូមិសាស្ត្រនេះ គឺបានកើតចេញជាតួនាទីពិសេសដែលមិនមាននៅក្នុងមន្ទីរសន្តិបាលផ្សេងៗទៀត ។

**ស៖** ដូច្នេះ ខ្ញុំចង់ឲ្យលោកជម្រាបប្រាប់ខ្ញុំថា តើលោកបានដឹងដែរឬទេ? ឧទាហរណ៍ថាមន្ទីរសន្តិសុខនៅភូមិភាគបូព៌ា ដែលគាត់មានអ្នកទោសយកមកពីមជ្ឈិម ឬក៏ឧត្តរ? ហើយតួនាទីពិសេសចំពោះ ស-២១ នោះ គឺដោយសារភាពនៅកៀកទីតាំងភូមិសាស្ត្រ?

[១៦:១៧:៤១]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! បើនិយាយអំពី *ស្ពេស៊ីហ្វិក* បើនិយាយអំពីលក្ខណៈជាដែលចៅក្រមមានប្រសាសន៍ហៅថា *ស្ពេស៊ីហ្វិក ស៊ីតេ* ហ្នឹង ។ ស-២១ វា មានលក្ខណៈប្លែកៗ ដោយវាបោះទីតាំងនៅជិតអចិន្ត្រៃយ៍មជ្ឈិម ហើយវាជាឧបករណ៍ផ្តាច់ការរបស់អចិន្ត្រៃយ៍មជ្ឈិម ដែលមានអំណាចប្រមូលមនុស្សយកមកឲ្យពីគ្រប់ភូមិភាគ ។

ដូច្នេះ វាជាសមត្ថភាពរបស់អចិន្ត្រៃយ៍ វាមិនមែនជាឋានៈ វាមិនមែនអំណាចរបស់ស-២១ ទេ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះ យើងនឹងបន្តការអានតទៀតនៅកថាខណ្ឌបន្ទាប់ ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតឲ្យក្រឡាបញ្ជីធ្វើការបន្តអានទៅលើកថាខណ្ឌបន្ទាប់នោះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលវេលា ដល់ពេលវេលាត្រូវសម្រាកពេលរសៀលហើយ ហើយកិច្ចការកថាខណ្ឌនៅជាច្រើន ដែលត្រូវអានទៀត ទោះបីយើងបន្តការអានទៀតក៏មិនចប់ដែរ ។ អ៊ីចឹងគឺ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ ។ ហើយសវនាការនឹងលើកទៅបន្ត នៅព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោងប្រាំបួនព្រឹក ។

ហើយទន្ទឹមនឹងនេះ ក៏អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគីផងដែរថា អង្គជំនុំជម្រះបានចេញសម្រេចកំណត់នូវកាលបរិច្ឆេទនៃដំណើរការសវនាការ ចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ រហូតដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ រួចហើយ ហើយបានដាក់បញ្ជូនទៅតាម*អាជ្រេស* តាម*អ៊ីម៉ែល* របស់ភាគីរួចហើយ ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនេះ នៅព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ឲ្យបានមុនម៉ោងប្រាំបួន ។ ហើយភាគីដូចគ្នា គឺសូមអញ្ជើញចូលរួមតាមកាលកំណត់ដូចបានជម្រាបជូន ៕

*[សវនាការផ្អាកនៅម៉ោង ១៦:២១ នាទី]*